ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# យុទ្ធសាស្ត្រជំរុញគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ

# Teacher-Professional Code Enhancing Strategies to Urge Lower Secondary School Teachers In Kampong Speu Keeping Their Duties In The Job Performances


ដោយ/by

ប៊ន តុលា

**BORN TOLA**


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ៨

ឯកទេស ៖ ការគ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២១

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# យុទ្ធសាស្ត្រជំរុញគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ

## Teacher-Professional Code Enhancing Strategies to Urge Lower Secondary School Teachers In Kampong Speu Keeping Their Duties In The Job Performances

ដោយ/by

ប៊ិន តុលា

BORN TOLA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦
ឯកទេស៖ គ្រប់គ្រងអប់រំ

សាស្ត្រាចារ្យដឹកនាំ ៖ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា
សាស្ត្រាចារ្យដឹកនាំ ៖ លោក ឡុច ចាន់ថន

ឆ្នាំសិក្សា ២០១៩-២០២១

វិទ្យាស្ថានជាតិអប់រំ ភ្នំពេញ កម្ពុជា
National Institute of Education (NIE)
Phnom Penh, Kingdom of Cambodia

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា សារណាស្រាវជ្រាវដែលមានចំណងជើងថា "**យុទ្ធសាស្រ្តជំរុញគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ ឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ**"សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំគឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬនៅសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយទេ។ លើសពីនេះទៅទៀតស្នាដៃនេះពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារណាមួយយកមកប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធឬចុះបញ្ជី ឯកសារឡើយ។ សារណាស្រាវជ្រាវនេះពិតជាស្រាវជ្រាវចងក្រងដោយខ្ញុំបាទផ្ទាល់ប្រាកដមែន។

ថ្ងៃ........................ខែ..............ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

**ហត្ថលេខាបេក្ខជន**

**ប៊ិន តុលា**

# លិខិតបញ្ជាក់

| | | |
|---|---|---|
| ឯកឧត្តមបណ្ឌិត | **សៀង សុវណ្ណា** | ជាសាស្ត្រាចារ្យដឹកនាំ |
| លោក | **ឡុច ចាន់ថន** | ជាសាស្ត្រាចារ្យដឹកនាំរង |

## សូមបញ្ជាក់ និងទទួលស្គាល់ថា៖

លោក **ចិន តុលា** ជានិស្សិតថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "យុទ្ធសាស្ត្រជំរុញគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន" ពិតប្រាកដមែន។

ថ្ងៃ ............................ ខែ ...................... ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ............ ខែ ................. ឆ្នាំ ២០២១

| | |
|---|---|
| ..................................................... | .................................................. |
| ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** | លោក **ឡុច ចាន់ថន** |
| នាយក | គ្រូឧទ្ទេស |
| វិទ្យាស្ថានជាតិអប់រំ | វិទ្យាស្ថានជាតិអប់រំ |

# សេចក្ដីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ និងក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំក៏ដូចជាផ្ដល់ឱកាសដល់ខ្ញុំបាទបានចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណ ចំពោះគណៈកម្មការគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលវេលាមកបង្ហាត់បង្រៀនដល់យើងខ្ញុំទាំងអស់គ្នា ដោយបានលះបង់ពេលវេលាដ៏មានតម្លៃ និងមិនគិតពីការនឿយហត់ឡើយ។

ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** ជាសាស្ត្រាចារ្យដឹកនាំ និងលោក **ឡុច ចាន់ថន** ជាសាស្ត្រាចារ្យដឹកនាំរង ដែលតែងចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីពន្យល់ណែនាំដល់ខ្ញុំបាទគ្រប់ជំហាន ទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទទទួលបានជោគជ័យ។

ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះមិត្តរួមថ្នាក់ជំនាន់ទី៨ទាំងអស់ ដែលតែងតែផ្ដល់ជាកម្លាំងចិត្តដល់ ខ្ញុំបាទតាមរយៈការចែករំលែកចំណេះដឹងបទពិសោធនិងព័ត៌មានទាំងឡាយដល់ខ្ញុំបាទ ដើម្បីឱ្យការស្រាវជ្រាវរបស់ខ្ញុំមានភាពងាយស្រួល។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណផងដែរ ចំពោះថ្នាក់ដឹកនាំមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ស្ពឺ ថ្នាក់ដឹកនាំការិយាល័យជំនាញនៃមន្ទីរអប់រំយុវជននិងកីឡាខេត្តកំពង់ស្ពឺ គណៈគ្រប់គ្រងអនុវិទ្យាល័យគោលដៅទាំង១៦ និងលោកគ្រូ-អ្នកគ្រូទាំងអស់ ដែលបានចូលរួមជួយសម្របសម្រួលនិងសហការ ក្នុងដំណើរការចុះប្រមូលទិន្នន័យ ដែលបានធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ខ្ញុំបាទសូមគោរពជូនពរចំពោះអ្នកទាំងអស់គ្នា សូមជួបប្រទះតែសេចក្ដីសុខចម្រើន និងទទួលបាននូវពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# សមាសភាពគណៈកម្មការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៧០៥ អយក. វ ១៥

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ិន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអោ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារុំម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ីងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃពុធ ៦កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

# មាតិកាចំណងជើង


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ...... i

លិខិតបញ្ជាក់ ...... ii

សេចក្តីថ្លែងអំណរគុណ ...... iii

សមាសភាពគណៈកម្មការការពារនិក្ខេបបទ ...... iv

មូលន័យសង្ខេប ...... xi

Abstract ...... xiii

ជំពូកទី១៖ សេចក្តីផ្តើម ...... 1

១. ១ លំនាំបញ្ហានៃការស្រាវជ្រាវ ...... 1

១. ២ ចំណោទបញ្ហានៃការស្រាវជ្រាវ ...... 3

១.៣ គោលបំណងនៃការស្រាវជ្រាវ ...... 4

១.៤ សារៈសំខាន់នៃការស្រាវជ្រាវ ...... 4

១.៥ សំណួរស្រាវជ្រាវ ...... 5

១.៦ ដែនកំណត់នៃការស្រាវជ្រាវ ...... 6

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ...... 7

ជំពូក២៖ រំលឹកទ្រឹស្តី ...... 9

២.១ និយមន័យពាក្យគន្លឹះ ...... 9

២.២ លក្ខណសម្បត្តិរបស់គ្រូបង្រៀននៅប្រទេសអាស៊ាន ...... 10

២.៣ លក្ខណសម្បត្តិរបស់គ្រូបង្រៀននៅកម្ពុជា ...... 10

២.៤ លក្ខណសម្បត្តិរបស់គ្រូបង្រៀនក្នុងសតវត្សទី២១ ...... 12

២.៥ ភារកិច្ចរបស់គ្រូបង្រៀន ...... 14

២.៦ សិទ្ធិ និងកាតព្វកិច្ចរបស់គ្រូបង្រៀន ...... 15

២.៧ កម្មវិធីកំណែទម្រង់ជាអាទិភាពសម្រាប់ឆ្នាំ២០១៤-២០១៨ ...... 16

២.៨ គោលនយោបាយស្តីពីគ្រូបង្រៀន(ផែនការសកម្មភាព) ...... 16

២.៩ ការលើកទឹកចិត្តដល់គ្រូបង្រៀន ...... 17

២.១០ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ...... 19

២.១១ អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ............................................. 20
ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ ........................................................................................ 22
៣.១. ភាគសំណាកនៃការស្រាវជ្រាវ........................................................................ 22
៣.២. ឧបករណ៍ស្រាវជ្រាវ .................................................................................... 23
៣.២.១ ការបង្កើតខ្លឹមសារ................................................................................ 23
៣.២.២ ទម្រង់កម្រងសំណួរ ................................................................................ 24
៣.៣ នីតិវិធី និងដំណើរការប្រមូលទិន្នន័យ........................................................... 25
៣.៤. ការវិភាគទិន្នន័យ ....................................................................................... 26
៣.៤.១ ឧបករណ៍វិភាគទិន្នន័យ........................................................................ 27
៣.៤.២ ដំណាក់កាលនៃការវិភាគទិន្នន័យ ........................................................... 27
៣.៤.៣ ការបកស្រាយទិន្នន័យ ......................................................................... 28
៣.៤.៤ ការវិភាគទិន្នន័យលើកម្រងសំណួរជាព័ត៌មានផ្ទាល់ខ្លួន ............................... 28
៣.៥ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ .............................................................. 29
ជំពូក៤៖ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា.............................................................. 31
៤.១ ការយល់ដឹងអំពីម៉ោងពេលបំពេញភារកិច្ចប្រចាំសប្តាហ៍របស់គ្រូបង្រៀន ................ 31
៤.១.១ ចំនួនម៉ោងបំពេញភារកិច្ចប្រចាំសប្តាហ៍ ..................................................... 31
៤.១.២ ចំនួនម៉ោងបង្រៀនក្នុងថ្នាក់..................................................................... 32
៤.១.៣ ចំនួនម៉ោងគាំទ្រការបង្រៀន ................................................................... 33
៤.១.៤ ចំនួនម៉ោងធ្វើការជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់............................ 34
៤.១.៥ ចំនួនម៉ោងកែកិច្ចការសិស្ស .................................................................. 35
៤.១.៦ ចំនួនម៉ោងរៀបចំកិច្ចតែងការបង្រៀន........................................................ 35
៤.១.៧ ចំនួនម៉ោងកសាងសំណួរតេស្ត................................................................ 36
៤.១.៨ ចំនួនម៉ោងស្រាវជ្រាវបន្ថែមលើមុខវិជ្ជាឯកទេស ........................................ 37
៤.១.៩ ចំនួនម៉ោងផលិតសម្ភារឧបទេស............................................................. 37
៤.១.១០ ចំនួនម៉ោងប្រជុំបច្ចេកទេស ................................................................. 38
៤.១.១១ ចំនួនម៉ោងបូក ស្រង់ពិន្ទុសិស្ស............................................................. 39

៤.១.១២ ចំនួនម៉ោងរៀបចំរដ្ឋបាលថ្នាក់ ឯកសារ និងកំណត់ត្រាផ្សេងៗ .................. 39
៤.១.១៣ ចំនួនម៉ោងចូលរួមសកម្មភាពក្រៅថ្នាក់ និងសង្គម .................................... 40
៤.១.១៤ ចំនួនម៉ោងទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស ................................ 41
៤.២ ការអនុវត្តជាក់ស្តែងនៃម៉ោងពេលបំពេញការងារប្រចាំសប្តាហ៍ ............................ 42
៤.២.១ ចំនួនម៉ោងបំពេញភារកិច្ចប្រចាំសប្តាហ៍ ........................................................ 42
៤.២.២ ចំនួនម៉ោងឡើងបង្រៀនក្នុងថ្នាក់ ................................................................ 43
៤.២.៣ ចំនួនម៉ោងគាំទ្រការបង្រៀន ....................................................................... 43
៤.២.៤ ចំនួនម៉ោងធ្វើការជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់ ............................ 44
៤.២.៥ ចំនួនម៉ោងកែកិច្ចការសិស្ស ....................................................................... 45
៤.២.៦ ចំនួនម៉ោងរៀបចំកិច្ចតែងការបង្រៀន ......................................................... 46
៤.២.៧ ចំនួនម៉ោងកសាងសំណួរតេស្ត ................................................................... 46
៤.២.៨ ចំនួនម៉ោងស្រាវជ្រាវបន្ថែមលើមុខវិជ្ជាឯកទេស ............................................ 47
៤.២.៩ ចំនួនម៉ោងផលិតសម្ភារឧបទេស ................................................................. 48
៤.២.១០ ចំនួនម៉ោងប្រជុំបច្ចេកទេស ..................................................................... 49
.................................................................................................................. 49
៤.២.១១ ចំនួនម៉ោងបូក ស្រង់ពិន្ទុសិស្ស ................................................................ 50
៤.២.១២ ម៉ោងរៀបចំរដ្ឋបាលថ្នាក់ ឯកសារ និងកំណត់ត្រាផ្សេងៗ ............................. 50
៤.២.១៣ ចំនួនម៉ោងចូលរួមសកម្មភាពក្រៅថ្នាក់ និងសង្គម .................................... 51
៤.២.១៤ ចំនួនម៉ោងទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស ................................ 52
៤. ៣ ការបំពេញភារកិច្ចតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន .......................................... 53
៤.៣.១ ចំណេះដឹងវិជ្ជាជីវៈ ................................................................................... 53
ក. ការស្គាល់សិស្ស ........................................................................................ 53
ខ.ការយល់ដឹងច្បាស់ពីប្រភេទគ្រួសារសិស្ស និងកត្តាផ្សេងៗ ................................. 54
គ.ការយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំ
ចំណេះទូទៅ ................................................................................................ 54
ឃ. ការយល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀន ....................................... 55

ង. ការយល់ដឹងពីក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងផែនការបង្រៀន........ 55
៤.៣.២ ការប្រតិបត្តិវិជ្ជាជីវៈ ........................................................................................ 56
ក. ការរៀបចំកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានត្រឹមត្រូវ និងមានប្រសិទ្ធភាព .................................................................. 56
ខ.ការរៀបចំសម្ភារបង្រៀន និងរៀនដើម្បីឱ្យការសិក្សាសម្រេចបានលទ្ធផលល្អ ........... 57
គ. ការប្រើប្រាស់វិធីសាស្ត្រសមស្របសម្បូរបែបសម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ......................................................................................................... 57
ឃ. ការផ្តល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាព...................................................................................................... 57
ង. ការជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន..................... 58
ច. ការប្រើប្រាស់វិធីបង្រៀនផ្សេងៗដើម្បីជួយការសិក្សារបស់សិស្សឱ្យសម្រេចតាមស្តង់ដាកម្មវិធីសិក្សា.............................................................................................. 58
ឆ.ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីធ្វើឱ្យការបង្រៀននិងរៀនកាន់តែមានប្រសិទ្ធភាព .................................................................................. 59
៤.៣.៣ ការសិក្សាវិជ្ជាជីវៈ ........................................................................................ 59
ក. ស្វ័យវាយតម្លៃលើការបង្រៀនរបស់ខ្លួនដើម្បីអភិវឌ្ឍសមត្ថភាពនៃការបង្រៀន......... 60
ខ. ការអភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មានវិទ្យា និងបំណិនសម្រាប់អនុវត្តក្នុងការបង្រៀន ....................................................................................................... 60
គ. ការអភិវឌ្ឍបំណិនទំនាក់ទំនងជាមួយមាតាបិតាសិស្ស មិត្តរួមអាជីព និងសហគមន៍.. 61
ឃ.ការស្រាវជ្រាវបន្ថែមអំពីវិជ្ជាជីវៈគ្រូបង្រៀនដើម្បីពង្រីកចំណេះដឹងឱ្យទូលំទូលាយ .... 61
ង. ការធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈ ........................... 61
៤.៣.៤ សីលធម៌វិជ្ជាជីវៈ ........................................................................................ 62
ក. ការបង្ហាញពីការយកចិត្តទុកដាក់ចំពោះប្រយោជន៍សិស្សជាធំ ............................. 62
ខ. ការបង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈប្រកបដោយស្មារតីទទួលខុសត្រូវ ..................................................................................................... 62
គ. ការបង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ជាមួយសិស្ស និងសហគមន៍ .......................................................................................................... 63
ឃ. ការប្រើប្រាស់ភាពយុត្តិធម៌ តម្លាភាពជាមួយសិស្ស និងសហសេវិក ...................... 63

៤.៤ ទស្សនៈអំពីការកំណត់អាទិភាពដើម្បីបង្កើតយុទ្ធសាស្ត្រជំរុញគ្រូបង្រៀនឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ ..................... 64
៤.៤.១ ទស្សនៈរួមរបស់បុគ្គលិកអប់រំ ..................... 64
៤.៤.២ ទស្សនៈរបស់បុគ្គលិកអប់រំប្រៀបធៀបតាមតំបន់ ..................... 69
៤.៤.៣ ទស្សនៈរបស់បុគ្គលិកអប់រំប្រៀបធៀបតាមភេទ ..................... 71
៤.៤.៣ ទស្សនៈរបស់បុគ្គលិកអប់រំប្រៀបធៀបតាមតួនាទី ..................... 73
៤.៤.៤ ទស្សនៈរបស់បុគ្គលិកអប់រំប្រៀបធៀបតាមបទពិសោធន៍ការងារ ..................... 78
ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ ..................... 86
៥.១ សេចក្តីសន្និដ្ឋាន ..................... 86
ក. ការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀននៅក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃ ..................... 86
ខ. យុទ្ធសាស្ត្រជំរុញគ្រូបង្រៀនឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ..................... 87
៥.២ សំណូមពរ ..................... 87
ឧបសម្ព័ន្ធ ..................... 91
ឧបសម្ព័ន្ធ «ក» ..................... 91
ឧបសម្ព័ន្ធ«ខ» ..................... 101
ឧបសម្ព័ន្ធ«គ» ..................... 104

# មូលន័យសង្ខេប

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែលម្អប្រព័ន្ធអប់រំ សំដៅធានាការអប់រំត្រូវបានទទួលស្គាល់ពីសហគមន៍ក្នុងតំបន់និងអន្តរជាតិ។ ទោះបីជាយើងទទួលបានលទ្ធផលជាវិជ្ជមានបន្តបន្ទាប់ក៏ដោយ យើងទទួលស្គាល់ថាបញ្ហាគុណភាពអប់រំ បញ្ហាអនាគតកុមារ ត្រូវមានការធានា និងការកែលម្អបន្ថែមទៀត ដើម្បីស្ថេរភាពនិងការអភិវឌ្ឍរបស់ប្រទេសជាតិ។គ្រូបង្រៀនជាកត្តាមួយនៃកត្តាសំខាន់ៗដទៃទៀតក្នុងការរួមចំណែកលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពអប់រំ។

ការសិក្សាស្រាវជ្រាវនេះចង់ដឹងពីស្ថានភាពនៃការអនុវត្ត ការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ ដើម្បីយុទ្ធសាស្ត្រជំរុញគ្រូបង្រៀនឱ្យបំពេញភារកិច្ចប្រកបដោយក្រសីលធម៌វិជ្ជាជីវៈ។ ការសិក្សាស្រាវជ្រាវនេះផ្អែកលើទ្រឹស្តី និងឯកសារមួយចំនួនរបស់ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា និងអ្នកស្រាវជ្រាវមុនៗ។ ចំណែកឯទិន្នន័យទទួលបានពីការប្រមូលនៅក្នុងអនុវិទ្យាល័យទាំងដប់ប្រាំមួយ ក្នុងខេតត្តកំពង់ស្ពឺ ដែលមានក្រុមគោលដៅចំនួនប្រាំមួយគឺៈ ថ្នាក់ដឹកនាំមន្ទីរអប់រំយុវជននិងកីឡាខេត្តកំពង់ស្ពឺចំនួន០៣នាក់ ថ្នាក់ដឹកនាំការិយាល័យមធ្យមសិក្សាចំណេះទូទៅចំនួន០៣នាក់ ថ្នាក់ដឹកនាំការិយាល័យបុគ្គលិកចំនួន០៣នាក់ ថ្នាក់ដឹកនាំការិយាល័យអធិការកិច្ចចំនួន០៣នាក់ គណៈគ្រប់គ្រងសាលាចំនួន២៣នាក់ និងគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិចំនួន១៩៧នាក់ ដើម្បីបំពេញកម្រងសំណួរ ដែលបានចងក្រងឡើងតាមបែបបរិមាណវិស័យ។ ទិន្នន័យដែលប្រមូលបាន ត្រូវបានបញ្ចូលទៅក្នុងកម្មវិធី SPSS ដើម្បីគណនាប្រេ្វកង់ ដោយបង្កើតគំនូសតាង ជាក្រាហ្វិក និងភាគរយ ដើម្បីធ្វើការប្រៀបធៀប ទាញសន្និដ្ឋាន និងវាយតម្លៃទៅលើលទ្ធផលដែលសម្រេចបាន។

លទ្ធផលដែលបានពីការស្រាវជ្រាវបង្ហាញឱ្យឃើញថា កម្រិតនៃការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនរបស់លោកគ្រូអ្នកគ្រូនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺត្រូវបាឆ្លុះបញ្ចាំងតាមរយៈការយល់ដឹង និងការអនុវត្តម៉ោងពេលបំពេញភារកិច្ចប្រចាំសប្តាហ៍របស់គ្រូបង្រៀន និងកម្រិតយល់ដឹងអំពីស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅមិនទាន់អនុវត្តបានល្អទាំងស្រុងនៅឡើយ ដោយផ្អែកលើបញ្ហាប្រឈមជាចម្បងមួយចំនួនគឺៈ គ្រូបង្រៀនមិនដឹងឱ្យប្រាកដអំពីម៉ោងពេលបំពេញការងារប្រចាំសប្តាហ៍ មិនបានបំពេញភារកិច្ចឱ្យបានត្រឹមត្រូវនៅក្នុងម៉ោងគាំទ្រការបង្រៀនប្រចាំសប្តាហ៍ មិនបានយល់ដឹងច្បាស់អំពីគោលនយោបាយអប់រំ ខ្វះចំណេះដឹងអំពីក្របខណ្ឌកម្មវិធី

សិក្សានិងស្តង់ដាកម្មវិធីសិក្សា គ្រូមួយចំនួនខ្វះចំណេះដឹងអំពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀន ហើយមិនបានរៀបចំកិច្ចតែងការបង្រៀនមុនពេលបង្រៀសិស្ស គ្រូបង្រៀនមួយចំនួនខកខានការចូលរួមប្រជុំបច្ចេកទេសញឹកញាប់ គ្រូបង្រៀនមិនបានទំនាក់ទំនងជាមួយមាតិបិតាសិស្សដើម្បីតាមដានការសិក្សារបស់សិស្ស គ្រូបង្រៀនមួយចំនួនមិនបានដឹងអំពីស្ថានភាពរស់នៅរបស់សិស្សធ្វើឱ្យបង្រៀនមិនស្របតាមតម្រូវការរបស់សិស្ស។

ជាយុទ្ធសាស្រ្ត ដើម្បីជំរុញគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីគ្រូបង្រៀ សូមក្រសួងអប់រំ យុវជន និងកីឡា និងភាគីពាក់ព័ន្ធទាំងអស់ គួរតែ (1)ដាក់ចេញនូវយន្តការដើម្បីគ្រប់គ្រងវត្តមាន ម៉ោងចូល និងម៉ោងចេញពីបង្រៀនតាមថ្នាក់នីមួយៗនៃគ្រូបង្រៀនម្នាក់ៗបានច្បាស់លាស់ និងយ៉ាងម៉ឺងម៉ាត់ជាប្រចាំ។ (2)គួរដាក់ចេញនូវវិធានការណ៍អោយបានម៉ឹងម៉ាត់ក្នុងការជំរុញគ្រូបង្រៀនអោយមកសាលារៀនអោយគ្រប់សែសិប(៤០) ម៉ោងក្នុងមួយសប្តាហ៍ដើម្បីអោយពួកគាត់បំពេញភារកិច្ចទាំងម៉ោងបង្រៀននៅតាមថ្នាក់នីមួយៗ និងម៉ោងគាំទ្រការបង្រៀនប្រចាំសប្តាហ៍។ (3)ពង្រឹងការប្រជុំបច្ចេកទេសនៅតាមអនុវិទ្យាល័យទាំងអស់ដោយផ្តោតសំខាន់ទៅលើប្រធានបទជាក់លាក់ដែលលើកកម្ពស់បច្ចេកនៃការបង្រៀនកាន់តែប្រសើរ ហើយតម្រូវគ្រូបង្រៀនទាំងអស់ចូលរួមប្រជុំយ៉ាងទៀងទាត់។ (៤)ដាក់ចេញនូវគោលការណ៍ដែលកំណត់អោយគ្រូបង្រៀនតាមមុខវិជ្ជានីមួយៗត្រូវតែធ្វើកិច្ចសន្យាជាមួយនាយកសាលានៅដើមឆ្នាំសិក្សាដើម្បីធានាលទ្ធផលសិក្សារបស់សិស្សចំពោះមុខវិជ្ជាដែលខ្លួនបង្រៀន។

# Abstract

Ministry of Education Youth and Sport has reformed the education system in order to get regional and international acknowledgements. Even the result has changed to positive, we still believe the issue of educational quality and the future of children must be ensured and upgraded for the stability and the development of our country. Teachers are one of the most significant factors that have participated in the effectiveness enhancement and the quality of education.

This research aimed to study and focus on the situation of teachers' professional ethics implementation reflected by weekly working hours in lower secondary school in Kampong Speu. Significantly, the study aimed to indicate the priority of the surveyed strategies to build a strong mechanism to urge lower secondary school teachers to practice the professional ethics in their job performance. This research based on the theories and some relevant documents from Ministry of Education Youth and Sport and other previous researches. The data of this research are from sixteen lower secondary schools in Kampong Speu and the participants from six main targets such as, 03 PoE leaders, 09 leaders of three offices in Kampong Speu PoE, 23 school directors, and 135 lower secondary school teachers by using quantitative questionnaires. The data have inserted in SPSS to find frequency and percentages. In this way, it enabled to create tables, graphics, and to compare, assume and evaluate the result.

Based on the result of this research we found that, the understandings and implementation of teachers' professional ethics in lower secondary schools in Kampong Speu is not completely acceptable. The absenteeism of working hour is sensitive impact affecting teacher professional code implementation. The finding discovered three top priority of teacher-urging strategies, including (1) strong controlling teacher attendances in daily working hour, (2) strengthening monthly teaching technical meeting, and (3) result-based teaching contraction between teachers and school directors.

For the suggestions, Ministry of Education Youth and Sport and relevant partners should reform the teacher-professional code enhancing strategies to urge lower secondary school teachers to keep their duties in the job performances.

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១៖ សេចក្តីផ្តើម

## ១. ១ លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការកសាងប្រទេសឱ្យក្លាយទៅជាប្រទេសអភិវឌ្ឍន៍ប្រកបដោយភាពរីកចម្រើនលើគ្រប់វិស័យ ជាពិសេសគឺវិស័យអាទិភាពដែលជំរុញដល់ការស្តារ និងកសាងប្រទេសឱ្យមានមុខមាត់ល្អត្រចះត្រចង់នៅលើឆាកអន្តរជាតិ។ វិស័យអប់រំពិតជាមានសារៈសំខាន់បំផុត ព្រោះវាជាកាតាលីករដែលអាចធ្វើឱ្យប្រទេសមួយគេចចេញពីភាពក្រីក្រ និងប្រែក្លាយជាប្រទេសរីកចម្រើន តាមរយៈមូលធនមនុស្សដ៏មានគុណភាព។ ដើម្បីឱ្យការអភិវឌ្ឍវិស័យអប់រំបានជោគជ័យ ទាមទារឱ្យមានការទទួលខុសត្រូវរួមពីបុគ្គលម្នាក់ៗ ព្រោះថាវឌ្ឍនភាពអាចកើតមានបានប្រកបដោយចីរភាព លុះត្រាតែមានការចូលរួម និងការខិតខំប្រឹងប្រែងពីសំណាក់ប្រជាពលរដ្ឋគ្រប់រូប។

ម៉្យាងវិញទៀត ការយកចិត្តទុកដាក់ជាពិសេសក្នុងការអភិវឌ្ឍវិស័យអប់រំនេះពិតជាបានឆ្លើយតបទៅតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងវិស័យអប់រំ (SDG4) ដែលជាគោលដៅមួយក្នុងចំណោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង១៧ចំណុច សម្រាប់ឆ្នាំ២០៣០។ រាជរដ្ឋាភិបាល សាលារៀន និងគ្រូបង្រៀន គឺជាអ្នកបំពេញតួនាទីជួរមុខគេ ដែលត្រូវធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធជាមួយសិស្សានុសិស្ស ព្រមទាំងមាតាបិតា និងអ្នកអាណាព្យាបាលរបស់ពួកគេ។ ដើម្បីជានានិរន្តរភាពក្នុងការអភិវឌ្ឍធនធានមនុស្ស ចាំបាច់ត្រូវធ្វើការអភិវឌ្ឍគ្រូបង្រៀនឱ្យមានសមត្ថភាពពេញលេញ សំដៅជំរុញតាមការអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ ឱ្យសម្រេចតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

គោលដៅរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺត្រូវផ្លាស់ប្តូរប្រទេសកម្ពុជា ពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ ២០៥០។ ដើម្បីឱ្យមានកំណើនសេដ្ឋកិច្ច និងប្រសិទ្ធភាពក្នុងការប្រកួតប្រជែងនានា ចាំបាច់ទាមទារឱ្យពលរដ្ឋដែលជាកម្លាំងស្នូលត្រូវតែមានចំណេះដឹង និងជំនាញពាក់ព័ន្ធសមស្របទៅនឹងតម្រូវការទីផ្សារការងារក្នុងស្រុក និងនៅក្រៅប្រទេស។ ដូចនេះ វិស័យអប់រំពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ ដោយសារតែការអប់រំ ត្រូវផ្តោតលើការកសាងជំនាញ និងផ្តល់ឱកាសដល់សិស្ស និស្សិតគ្រប់ៗរូបអាចទទួល

បាននូវជំនាញបច្ចេកទេសផ្សេងៗ ដើម្បីសម្រេចជោគជ័យនូវការអភិវឌ្ឍ ដែលផ្តល់អត្ថប្រយោជន៍ពេញលេញដល់ប្រជាពលរដ្ឋគ្រប់ៗគ្នាទាំងអស់។

រាជរដ្ឋាភិបាលបានផ្តល់អាទិភាពក្នុងការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សតាមរយៈការពង្រឹងគុណភាពវិស័យអប់រំដែលមានចែងក្នុងមុំទី១ នៃយុទ្ធសាស្ត្រចតុកោណ។ ច្បាប់ស្តីពីការអប់រំមានគោលបំណងអភិវឌ្ឍធនធានមនុស្ស លើកកម្ពស់គុណភាពអប់រំ កំណត់សិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលិកអប់រំដូចជាសិទ្ធិទទួលបានតម្លៃវិជ្ជាជីវៈ សិទ្ធិអភិវឌ្ឍន៍ខាងវិជ្ជាជីវៈ សិទ្ធិចូលរួមអភិវឌ្ឍន៍ស្តង់ដាអប់រំ សិទ្ធិទទួលសេវាអប់រំផ្សេងៗ ការគោរពក្រមសីលធម៌វិជ្ជាជីវៈ និងការបំពេញកាតព្វកិច្ចផ្សេងទៀត (ឯកសារគោលនយោបាយស្តីពីគ្រូបង្រៀន)។ ក្នុងន័យនេះ គ្រឹះស្ថានសិក្សាគ្រប់កម្រិតត្រូវមានរចនាសម្ព័ន្ធច្បាស់លាស់ មានការដឹកនាំនិងគ្រប់គ្រងត្រឹមត្រូវ មានសមត្ថភាពតម្លាភាព និងមានការចូលរួមគាំទ្រពីគ្រប់មជ្ឈដ្ឋាន។ *គោលនយោបាយអប់រំទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* ការផ្តល់សេវាអប់រំ នឹងត្រូវផ្តល់ឱ្យប្រកបដោយប្រសិទ្ធភាព។ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងវិជ្ជាជីវៈខ្ពស់នឹងផ្តល់នូវតម្លៃដ៏ល្អបំផុត (ផ្តោតលើលទ្ធផល) ទាន់ពេលវេលា ហើយវាពាក់ព័ន្ធទៅនឹងការពិនិត្យតាមដាន និងរបាយការណ៍នៃលទ្ធផលទាំងនោះជាមួយនឹងយោបល់ត្រឡប់ ព្រមទាំងយន្តការសម្រាប់កែលម្អគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធី។ ក្នុងនោះ គ្រូបង្រៀនត្រូវទទួលបានការបណ្តុះបណ្តាលមានមនសិការវិជ្ជាជីវៈ មានសមត្ថភាពក្នុងការបង្រៀន តាមជំនាញឯកទេសនីមួយៗ ស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែលមានចំនួនបួន (៤) គឺ ស្តង់ដាចំណេះដឹងវិជ្ជាជីវៈ ស្តង់ដាប្រតិបត្តិវិជ្ជាជីវៈ ស្តង់ដាការសិក្សាវិជ្ជាជីវៈ និងស្តង់ដាសីលធម៌វិជ្ជាជីវៈ (ឯកសារស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ឆ្នាំ ២០១០)។

បន្ថែមលើការងារសំខាន់ៗខាងលើ ក្រសួងក៏បានជ្រើសរើសគ្រូបង្រៀនបន្ថែមជាប្រចាំ ឱ្យចូលមកសិក្សានៅតាមសាលាគរុកោសល្យនានា មុននឹងចេញទៅបង្រៀននៅតាមមូលដ្ឋានដើម្បីលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ដែលជាអ្នកផ្តល់ការអប់រំ ដល់យុវជនជំនាន់ក្រោយឱ្យទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពិតប្រាកដ ស្របទៅតាមចតុស្តម្ភនៃការអប់រំទាំង ៤ គឺ "រៀនដើម្បីមានចំណេះដឹង រៀនដើម្បីមានចំណេះធ្វើ រៀនដើម្បីក្លាយជាពលរដ្ឋល្អ និងរៀនដើម្បីចេះរស់នៅជាមួយគ្នាដោយសុខដុមរមនា"។ បន្ថែមលើនេះទៅទៀត ក្រសួងក៏បានបណ្តុះបណ្តាលមន្ត្រីអប់រំគ្រប់កម្រិត ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ក្នុងវិស័យអប់រំ ។ ម៉្យាងវិញទៀតយន្តការធានាគុណភាពអប់រំត្រូវបានរៀបចំ និងកំពុងអនុវត្តជាជំហានៗ ដើម្បីពិនិត្យ និងវាយតម្លៃលើការសិក្សារបស់សិស្សានុសិស្ស និងការគ្រប់គ្រងនៅតាមគ្រឹះស្ថានសិក្សាទូទាំងប្រទេស។

កិច្ចការស្រាវជ្រាវនេះត្រូវធ្វើឡើង ដោយផ្ដោតសំខាន់លើទស្សនៈយល់ឃើញរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ ដើម្បីបង្កើតយុទ្ធសាស្ត្រជំរុញគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។ និក្ខេបបទនេះក៏និយាយផងដែរពីការពង្រឹងប្រសិទ្ធភាពនៃការបំពេញភារកិច្ចរបស់គ្រូបង្រៀនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងលើកជាសំណូមពរមួយចំនួនដោយសង្ឃឹមថា និក្ខេបបទនេះនឹងអាចរួមចំណែកជួយដល់ គណៈគ្រប់គ្រងសាលារៀនក្នុងការជំរុញគ្រូបង្រៀននៅអង្គភាពរបស់ខ្លួនឱ្យយកចិត្តទុកដាក់បំពេញភារកិច្ច ហើយក៏អាចជាជំនួយមួយផងដែរដល់មន្ទីរ និងក្រសួង ក្នុងការដាក់ចេញនូវយុទ្ធសាស្ត្រដើម្បីជំរុញគ្រូបង្រៀនឱ្យខិតខំបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ សំដៅធ្វើយ៉ាងណាឱ្យសិស្សទទួលលទ្ធផលសិក្សាខ្ពស់សមស្របទៅនឹងចក្ខុវិស័យនៃការអប់រំ។

## ១. ២ ចំណោទបញ្ហានៃការស្រាវជ្រាវ

គ្រូបង្រៀនគឺជាកត្តាគន្លឹះក្នុងការលើកកម្ពស់គុណភាពអប់រំប្រកបដោយប្រសិទ្ធភាព។ ការយកចិត្តទុកដាក់ខ្ពស់ក្នុងផ្ដល់សេវាអប់រំប្រកបដោយគុណភាពគឺជាការទទួលខុសត្រូវរបស់គ្រូបង្រៀនចំពោះសង្គមជាតិទាំងមូល។ ដើម្បីធានាឱ្យការបង្រៀន មានគុណភាព និងប្រសិទ្ធភាព គ្រូបង្រៀនត្រូវតែអនុវត្តនូវភារកិច្ចសំខាន់ៗ មួយចំនួនដែលរួមមាន ការរៀបចំនិងប្រើប្រាស់កិច្ចតែងការបង្រៀនជាប្រចាំ ការប្រើប្រាស់សម្ភារឧបទេសស្របតាមខ្លឹមសារមេរៀននីមួយៗ ការប្រកាន់ជំហរអព្យាក្រឹតចំពោះសិស្ស ការគោរពពេលវេលា និងការខិតខំព្យាយាមអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ។ ការរៀបចំកិច្ចតែងការបង្រៀនជាប្រចាំ ធ្វើឱ្យគ្រូបង្រៀនបានត្រៀមលក្ខណៈគ្រប់គ្រាន់ក្នុងការផ្ទេរចំណេះដឹងដល់សិស្សបានត្រឹមត្រូវ និងច្បាស់លាស់ដែលអាចបញ្ចៀសបាននូវកំហុសឆ្គងនានាក្នុងពេលបង្រៀន។ គ្រូបង្រៀនដែលបង្រៀនដោយមិនបានរៀបចំកិច្ចតែងការ និងមិនមានសម្ភារឧបទេសគឺប្រៀបដូចអ្នកដើរក្នុងព្រៃជ្រៅដែលមិនមានផែនទីបង្ហាញផ្លូវ។ ដោយឡែក គ្រូបង្រៀនគឺជាតួអង្គគម្រូ នៃភាពអព្យាក្រឹតចំពោះអ្នកសិក្សា ពោលគឺ ត្រូវយកចិត្តទុកដាក់ដល់សិស្សទាំងអស់គ្នាដោយគ្មានការប្រកាន់ និងរើសអើងចំពោះសិស្សណាមួយឡើយ ហើយត្រូវធានាឱ្យបាននូវការកសាងធនធានមនុស្សប្រកបគុណភាពសម្រាប់សង្គម។ ការប្រកាន់ខ្ជាប់វិន័យគឺជាគុណតម្លៃដ៏ប្រសើរសម្រាប់មនុស្សទូទៅ ជាពិសេសគ្រូបង្រៀនដែលជាបុគ្គលគម្រូក្នុងការអប់រំ។ យោងតាមរបាយការណ៍អធិការកិច្ចតាមកាលកំណត់ផ្នែកមធ្យមសិក្សាប្រចាំឆ្នាំ២០១៩(ឆ្នាំសិក្សា២០១៨-២០១៩) និងឆ្នាំ២០២០(ឆ្នាំសិក្សា២០១៩-២០២០) របស់ការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ បង្ហាញឱ្យឃើញនៅក្នុងផ្នែកការបង្រៀន និងរៀន ដែលមានសូចនាករធំៗ ចំនួនប្រាំ៖(១)ការបង្រៀន និងរៀនធ្វើឡើងស្របតាមកម្មវិធីសិក្សា គឺលោកគ្រូ អ្នកគ្រូអនុវត្តបានត្រឹមតែ

១៣% នៅឆ្នាំ២០១៩ និង៣៣% នៅឆ្នាំ២០២០ (២) មានការប្រើប្រាស់គរុកោសល្យ និងវិធីសាស្ត្រគ្រប់គ្រាន់ពាក់នឹងគោលបំណងនៃការបង្រៀនមេរៀន គឺលោកគ្រូ អ្នកគ្រូអនុវត្តបានត្រឹមតែ ១៣% ក្នុងឆ្នាំ២០១៩ និង ៣៣%ក្នុងឆ្នាំ២០២០ (៣) ការបង្រៀន និងរៀនស្របតាមតម្រូវការរបស់សិស្ស គឺលោកគ្រូ អ្នកគ្រូអនុវត្តបាន៧៥%ក្នុងឆ្នាំ២០១៩ ប៉ុន្តែធ្លាក់ចុះមកវិញត្រឹម៥០% ប៉ុណ្ណោះនៅឆ្នាំ២០២០ (៤) គ្រូបង្កើតបរិយាកាសលើកទឹកចិត្តសិស្សឱ្យខិតខំរៀន គឺលោកគ្រូអ្នកអនុវត្តបាន១០០%ទាំងឆ្នាំ២០១៩ និងឆ្នាំ២០២០ (៥) គ្រូបន្តកែលម្អការបង្រៀនរបស់ខ្លួន គឺលោកគ្រូ អ្នកគ្រូអនុវត្តបាន៨៧%នៅឆ្នាំ២០១៩ ប៉ុន្តែធ្លាក់ចុះមកវិញត្រឹម៦៧%នៅឆ្នាំ២០២០។ តាមរយៈរបាយការណ៍នេះយើងអាចដឹងយ៉ាងច្បាស់ថា ការបំពេញភារកិច្ចរបស់គ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺមិនទាន់ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈនៅឡើយទេហើយក៏មិនទាន់មានការចាត់វិធានការណ៍ជាក់លាក់ណាមួយចំពោះគ្រូបង្រៀនអសកម្មនៅឡើយ។ ដូច្នេះការបង្កើតយុទ្ធសាស្ត្រដ៏រឹងមាំគឺជាវិធានការណ៍អាទិភាពបំផុតពីព្រោះវានឹងជំរុញគ្រូបង្រៀឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួនជាប្រចាំ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណង៖

- សិក្សាពីស្ថានភាពនៃការអនុវត្តម៉ោងពេលបំពេញភារកិច្ចប្រចាំសប្តាហ៍ និងការយល់ដឹងអពីស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់បុគ្គលិកបង្រៀដើម្បីឆ្លុះបញ្ចាំងពីការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀននៅតាមគ្រឹះស្ថានមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ។
- ស្វែងរកយុទ្ធសាស្ត្រដើម្បីលើកកម្ពស់ក្នុងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀននៅគ្រឹះស្ថានមធ្យមសិក្សាបឋមភូមិ។

## ១.៤ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានសារៈសំខាន់ដូចតទៅ ៖

- ផ្តល់ជាព័ត៌មានសំខាន់ៗសម្រាប់អ្នកធ្វើគោលនយោបាយ ដើម្បីបង្កើតយុទ្ធសាស្ត្រជំរុញគ្រូនៅតាមអនុវិទ្យាល័យឱ្យប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈក្នុងអាជីពរបស់ខ្លួន។
- ផ្តល់ព័ត៌មានអំពីស្ថានភាពនៃការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀននៅគ្រឹះស្ថានមធ្យមសិក្សាបឋមភូមិ។
- ផ្តល់ជាចំណេះដឹង ដល់អ្នកពាក់ព័ន្ធក្នុងការកំណត់នូវយុទ្ធសាស្ត្រដើម្បីជំរុញគ្រូបង្រៀននៅតាមគ្រឹះស្ថានមធ្យសិក្សាបឋមភូមិឱ្យប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈសម្រាប់ការបំពេញភារកិច្ច ។

ការសិក្សាស្រាវជ្រាវ លើប្រធានបទ **យុទ្ធសាស្រ្តជំរុញគ្រូបង្រៀននៅតាមគ្រឹះស្ថានមធ្យសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ** ក្នុងគោលបំណងសិក្សាពីប្រសិទ្ធភាពនៃការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន និងប្រមូលព័ត៌មានពីគ្រូបង្រៀន បុគ្គលិកអប់រំ សិស្សានុសិស្ស និងមាតាបិតាសិស្សដែលមានកូនចៅរៀននៅតាមអនុវិទ្យាល័យ ដើម្បីផ្តល់ជាធាតុចូលសម្រាប់បង្កើតយុទ្ធសាស្រ្ត លើកកម្ពស់គ្រូបង្រៀនឱ្យបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងមានការទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនារបស់សិស្សានុសិស្ស។ ការសិក្សាពីកម្រិតនៃការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន នៅតាមគ្រឹះស្ថានមធ្យមសិក្សាបឋមភូមិសាធារណៈ និងលទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ ផ្តល់ជាយោបល់កែលម្អលើចំណុចខ្វះខាតក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃរបស់លោកគ្រូ អ្នកគ្រូ ព្រមទាំងចែករំលែកព័ត៌មាន និងបទពិសោធន៍ល្អៗដែលបានរកឃើញពីការសិក្សាស្រាវជ្រាវដល់គ្រឹះស្ថានសិក្សានានា។

ការរកឃើញពីស្ថានភាពជាក់ស្តែង នៃការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈក្នុងការបំពេញភារកិច្ចរបស់គ្រូបង្រៀន អាចជួយដល់អ្នកស្រាវជ្រាវ សំយោគបានមូលហេតុផ្សេងៗ ដើម្បីធ្វើការលើកឡើងជាសំណូមពរដល់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងភាគីពាក់ព័ន្ធដើម្បីដាក់ចេញជាយុទ្ធសាស្រ្តក្នុងការកែលម្អដល់ការបំពេញភារកិច្ចរបស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យឱ្យកាន់តែប្រសើរជាងមុន។

ក្នុងបរិបទនេះ អ្នកសិក្សាស្រាវជ្រាវបានធ្វើការពិនិត្យមើល លើកម្រិតនៃការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន ដែលកំពុងបម្រើការនៅតាមគ្រឹះស្ថានមធ្យមសិក្សាបឋមភូមិសាធារណៈ ដើម្បីរកឱ្យឃើញថា តើគ្រូបង្រៀនដែលកំពុងបម្រើការនៅតាមអនុវិទ្យាល័យសាធារណៈបានប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនត្រឹមកម្រិតណា ក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃធៀបនឹងច្បាប់សហលក្ខន្តិកៈមន្រ្តីរាជការ អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០០៨ និងឥទ្ធិពលយ៉ាងដូចម្តេចខ្លះទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស។

ដើម្បីឆ្លើយតបទៅនឹងគោលបំណងស្រាវជ្រាវ ការសិក្សាស្រាវជ្រាវនេះមានសំណួរស្រាវជ្រាវពីរដូចខាងក្រោម ដែលទាក់ទងទៅនឹងប្រធានបទ ៖

## ១.៥ សំណួរស្រាវជ្រាវ

១. តើការបំពេញភារៈកិច្ចរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺនាពេលបច្ចុប្បន្នឆ្លើយតបនឹងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនបានកម្រិតណា?

២.តើត្រូវមានយុទ្ធសាស្ត្រអ្វីខ្លះដើម្បីជំរុញគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ?

## ១.៦ ដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទ **យុទ្ធសាស្ត្រជំរុញគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ** (ករណីសិក្សា ៖ ខេត្តកំពង់ស្ពឺ) នេះត្រូវបានផ្តោតទៅលើតែគ្រូបង្រៀននៅអនុវិទ្យាល័យ។ ដែនកំណត់នៃការជ្រើសរើសសំណាកគឺអនុវិទ្យាល័យចំនួនដប់ប្រាំមួយ(១៦) ដែលស្ថិតនៅក្នុងស្រុក/ក្រុងទាំងប្រាំបី(០៨) នៃខេត្តកំពង់ស្ពឺរួមមាន៖ (1)ក្រុងច្បារមនមាន០២សាលា (2)ស្រុកសំរោងទងមាន០២សាលា (3)ស្រុកថ្ពងមាន ០២សាលា (4)ស្រុកឧត្តុង្គមាន០២សាលា (5)ស្រុកគងពិសីមាន០២សាលា (6)ស្រុកបរសេដ្ឋមាន០២សាលា (7)ស្រុកភ្នំស្រួចមាន០២សាលា និង(8)ស្រុកឱរ៉ាល់មាន០២សាលា។ ហើយខ្លឹមសារកម្រងសំណួរដែលត្រូវយកទៅសម្ភាសមុខសញ្ញាទាំងអស់គឺផ្តោតទៅទិដ្ឋភាពច្បាប់ជាគោលសំខាន់ អ្នកស្រាវជ្រាវមិនបានសិក្សាទៅលើកត្តាផ្សេងទៀតដែលជះឥទ្ធពលមកលើការបង្រៀនរបស់លោកគ្រូអ្នកគ្រូ។ ពីព្រោះគន្លងច្បាប់គឺជាបន្ទាត់ ឬជាខ្នាតជាក់លាក់ដែលអាចវាស់វែងបានយ៉ាងសុក្រឹតចំពោះការបំពេញភារៈកិច្ចរបស់គ្រូបង្រៀន ដោយឡែកកត្តាផ្សេងទៀត (សេដ្ឋកិច្ច សង្គម លាភការការផ្តល់គ្រឿងឥស្សរិយយស)ដែលយើងមិនបានសិក្សាជ្រាវជ្រាវទេគឺមកពីបញ្ហាទាំងនោះត្រូវបានដោះស្រាយរួចហើយបន្ទាប់ពីក្រសួងអប់រំបានធ្វើកំណែទម្រង់ស៊ីជម្រៅចាប់ឆ្នាំ២០១៤មកដល់បច្ចុប្បន្ន ប៉ុន្តែការបំពេញភារកិច្ចរបស់គ្រូបង្រៀននៅតាមគ្រឹះស្ថានមធ្យមសិក្សាបឋភូមិក្នុងខេត្តកំពង់ស្ពឺមិនមានការប្រែប្រួលទៅរកភាពល្អប្រសើរនៅឡើយទេ។ ការសិក្សាស្រាវជ្រាវនេះធ្វើឡើងរយៈពេលពីរសប្តាហ៍គឺចាប់ពីទទួលបានលិខិតឧទ្ទេសនាមពីក្រសួងអប់រំយុវជន និងកីឡា និងទទួលបានការអនុញ្ញាតិពីមន្ទីរអេយក កំពង់ស្ពឺ។ ការសិក្សាស្រាវជ្រាវនេះ ផ្តោតទៅលើកម្រិតនៃការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ ដោយផ្អែកលើច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០០៨ ក្នុងគោលបំណងបង្កើតយុទ្ធសាស្ត្រជំរុញគ្រូបង្រៀនឱ្យប្រកាន់ខ្ជាប់ក្រមសីលធម៌វិជ្ជាជីវៈក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដើម្បីលើកកម្ពស់គុណភាពនៃការសិក្សារបស់សិស្សនៅថ្នាក់មធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺតែប៉ុណ្ណោះ។ រាល់កម្រងសំណួរនិងខ្លឹមសារសម្ភាសន៍គឺផ្អែកលើក្របខណ្ឌច្បាប់ជាគោល។ អ្នកស្រាវជ្រាវមិនបានសួរ ឬសម្ភាសន៍ពីកត្តាផ្សេងៗដែលជះឥទ្ធិពលមកលើការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀននោះទេ។ ព័ត៌មានដែលទទួលបាន ត្រូវរក្សាទុកជាការ

សម្ងាត់ និងមិនបានយកឈ្មោះ ឬអ្វីដែលបញ្ជាក់អត្តសញ្ញាណរបស់ពួកគាត់ទេ។ ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដោយចង់ដឹងពីស្ថានភាពនិងការយល់ឃើញ ក៏ដូចជាបញ្ហាប្រឈមនៃ ការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន នៅតាមសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩)។ ម្យ៉ាងទៀតចំពោះតំបន់ដែលបានធ្វើការសិក្សាស្រាវជ្រាវ មានលក្ខណៈតូចនៅឡើយ ដូច្នេះមិនអាចតំណាងឱ្យតំបន់ឬខេត្តផ្សេងៗទៀតបាននោះទេ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា ៥ ជំពូកដូចខាងក្រោម ៖

**ជំពូកទី១ ៖ សេចក្តីផ្តើម**

បង្ហាញពីសារៈតារនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវព្រមទាំងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២ ៖ រំលឹកទ្រឹស្តី**

អ្នកស្រាវជ្រាវលើកឡើងនូវទ្រឹស្តីចាស់ៗ ពីអ្នកសិក្សាស្រាវជ្រាវមុនៗ ដែលមានខ្លឹមសារទាក់ទងនឹងចំណុចទាំងអស់ដែលបានចោទឡើងក្នុងចំណោទបញ្ហា ដើម្បីលើកយកមកបង្ហាញ និងការពារអំណះអំណាងនៅក្នុងនិក្ខេបបទសម្រាប់ការស្រាវជ្រាវនិងបង្កើតស្នាដៃថ្មីនេះឡើង។

**ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ**

បង្ហាញពីគម្រោងវិភាគ ឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រវិភាគទិន្នន័យ និងវិធីសាស្ត្រស្រាវជ្រាវដែលបញ្ជាក់ពីវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសគម្រូ និងប្រភេទគម្រូ ។

**ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា**

អ្នកស្រាវជ្រាវនឹងយកទិន្នន័យ ដែលប្រមូលបានមកវិភាគ និងបកស្រាយ ដើម្បីរកឱ្យឃើញនូវចំណុចទាំងអស់ដែលបានចោទសួរក្នុងចំណោទបញ្ហា។

**ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**

អ្នកស្រាវជ្រាវនឹងធ្វើការសន្និដ្ឋានលើគ្រប់ចំណុចដែលបានវិភាគមកខាងលើ ហើយផ្តល់ជាយោបល់ ធ្វើសំណូមពរទៅលើចំណុចមួយចំនួនដែលត្រូវកែលម្អ ដើម្បីជាការចូលរួមចំណែកក្នុងការអភិវឌ្ឍគ្រឹះស្ថានសិក្សាសាធារណៈ ឱ្យកាន់តែល្អប្រសើរឡើងថែមទៀ

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូក២៖ រំលឹកទ្រឹស្តី

## ២.១ និយមន័យពាក្យគន្លឹះ

យុទ្ធសាស្រ្ត គឺជាសំណុំនៃផែនការ សម្រាប់រៀបចំគម្រោងក្នុងគោលបំណងអ្វីមួយដើម្បីសម្រេចទិសដៅ។ ផែនការគឺជាមធ្យោបាយដែលមានលក្ខណៈជាប្រព័ន្ធ ក្នុងការដោះស្រាយបញ្ហានាពេលអនាគត។ មធ្យោបាយជាប្រព័ន្ធមានន័យថា ធ្វើជាជំហានៗ ដោយគិតគូរយ៉ាងប្រុងប្រយ័ត្នអំពីធនធាន និងពេលវេលាដែលមាន។ ក្រម គឺជាលំដាប់,ក្បួន,ឬបែប (វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ឆ្នាំ១៩៦៨)។ សីលធម៌ គឺជាដំបូន្មាន ដែលនាំឱ្យចៀសវាងអំពើអាក្រក់ ហើយឱ្យប្រព្រឹត្តតែអំពើល្អ ប្រកបដោយសីលធម៌ ប្រាស់ចាកអសីលធម៌ (វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ឆ្នាំ១៩៦៨)។ សីលធម៌សំដៅលើការប្រកាន់ខ្ជាប់នូវអាកប្បកិរិយាត្រឹមត្រូវ ស្គាល់ល្អ អាក្រក់ ហើយញ៉ាំងទឹកចិត្តមនុស្សឱ្យប្រព្រឹត្តិតែអំពើល្អ។ និយាយឱ្យចំ សីលធម៌គឺជា«គោលការណ៍នៃការសម្រេចចិត្ត និងចរិយាមាយាទដែលស្គាល់ខុសស្គាល់ត្រូវ»។ វិជ្ជាជីវៈ គឺជាមុខរបរសម្រាប់ចិញ្ចឹមជីវិត (វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ឆ្នាំ១៩៦៨)។ ក្រមសីលធម៌វិជ្ជាជីវៈ គឺជាឯកសារលាយលក្ខណ៍អក្សរដែលត្រូវបានផលិតឡើងដោយសមាគមវិជ្ជាជីវៈ គណៈកម្មការនិយ័តកម្មអាជីព ឬគណៈកម្មការវិជ្ជាជីវៈផ្សេងទៀត ដោយបង្ហាញពីគោលបំណងច្បាស់លាស់ដើម្បីចង្អុលបង្ហាញដល់អ្នកប្រតិបត្តិទាំងឡាយដែលជាសមាជិក និងដើម្បីការពារអ្នកទទួលសេវា ព្រមទាំងការពារកេរ្តិ៍ឈ្មោះរបស់អ្នកបំពេញវិជ្ជាជីវៈផងដែរ។

គ្រូបង្រៀន គឺជាអ្នកមានចិត្តធូន់និងគួរឱ្យគោរព និងជាអ្នកបង្ហាត់បង្រៀនចំណេះវិជ្ជាសិល្ប៍សាស្រ្តផ្សេងៗដល់សិស្ស (វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ឆ្នាំ១៩៦៨)។ តាមការយល់ឃើញនៃមតិភាគច្រើន គេបានចាត់ទុកថា គ្រូបង្រៀនគឺជាអាជីពពេញ២៤ម៉ោងរៀងរាល់ថ្ងៃ (teacher as teacher 24/7) ដែលមានន័យថាគ្រូបង្រៀនម្នាក់ គឺជាគ្រូបង្រៀនគ្រប់ពេល ហើយអាចត្រូវបានគេដាក់ទំនួលខុសត្រូវឱ្យអនុវត្តគ្រប់ពេលសម្រាប់ការសម្តែងអាកប្បកិរិយារបស់គាត់ទាំងក្នុង និងក្រៅសាលារៀន ដែលមានឥទ្ធិពលទៅលើការរៀនសូត្ររបស់សិស្ស ឬតួនាទីរបស់គ្រូបង្រៀន(Stewart, 2006)។ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន គឺជាសំណុំវិធានសីលធម៌ ឬជាច្បាប់សម្រាប់គ្រូបង្រៀនអនុវត្តក្នុងមុខវិជ្ជាជីវៈរបស់ខ្លួនឱ្យបានត្រឹមត្រូវ។

ដូចនេះ យុទ្ធសាស្រ្តជំរុញគ្រូបង្រៀនឱ្យប្រកាន់ខ្ជាប់នូវក្រសីលធម៌វិជ្ជាជីវៈក្នុងការបំពេញភារកិច្ចរបស់ខ្លួន គឺជាការកសាងផែនការបែបយុទ្ធសាស្រ្តដើម្បីធានាថា គ្រូបង្រៀននឹងអាចអនុវត្តបានយ៉ាងខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃរបស់ខ្លួន ដើម្បីធ្វើឱ្យការបង្រៀនឈានទៅសម្រេចបានតាមគោលដៅអប់រំក្នុងការកសាងពលរដ្ឋពេញលេញដែលប្រកបដោយសម្បទាធំៗទាំងបី។

## ២.២ លក្ខណសម្បត្តិរបស់គ្រូបង្រៀននៅប្រទេសអាស៊ាន

ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនសំដៅទៅលើការផ្សំបញ្ចូលគ្នានៃជំនាញវិជ្ជាជីវៈ ចំណេះដឹង ឥរិយាបថ និងអាកប្បកិរិយាដែលជួយដល់ការបំពេញការងារឱ្យកាន់តែប្រសើរនិងមានប្រសិទ្ធភាព។ ដោយការបង្រៀនគឺជាភារកិច្ចស្មុគស្មាញ ដូចនេះក្នុងនាមជាគ្រូបង្រៀនម្នាក់ត្រូវប្រើជំនាញវិជ្ជាជីវៈចម្រុះ ដើម្បីឆ្លើយតបទៅនឹងបរិបទអប់រំដែលកំពុងប្រែប្រួលឥតឈប់ឈរ។ ស្តង់ដាគ្រូបង្រៀនប្រទេសអាស៊ានមានជំនាញវិជ្ជាជីវៈស្នូលធំៗចំនួនបួន និងជំនាញវិជ្ជាជីវៈទូទៅចំនួនដប់ពីរ(១២) ដែលគ្រូបង្រៀនល្អនៅក្នុងតំបន់ត្រូវតែមាន។ ជំនាញវិជ្ជាជីវៈស្នូលទាំងបួននោះរួមមាន៖

ក. មានចំណេះដឹងច្បាស់លាស់ទៅលើជំនាញអ្វីដែលត្រូវបង្រៀន គឺជាសមត្ថភាពរបស់គ្រូបង្រៀនដែលពង្រីកចំណេះដឹងរបស់ពួកគាត់ឱ្យកាន់តែស៊ីជម្រៅពីអ្វីដែលត្រូវបង្រៀន យល់ដឹងពីនិន្នាការអប់រំ គោលនយោបាយអប់រំ និងកម្មវិធីសិក្សា ហើយព្យាយាមដើរឱ្យទាន់ការអភិវឌ្ឍក្នុងកម្រិតសហគមន៍ កម្រិតជាតិ កម្រិតតំបន់ និងកម្រិតសាកលលោក។

ខ. មានជំនាញក្នុងការជួយសិស្ស គឺជាសមត្ថភាពដើម្បីស្គាល់សិស្ស ហើយចេះប្រើប្រាស់យុទ្ធសាស្ត្របង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពបំផុត ព្រមទាំងចេះត្រួតពិនិត្យវាយតម្លៃហើយផ្តល់ព័ត៌ត្រឡប់ពីស្ថានភាពនៃការរៀនសូត្ររបស់សិស្ស។

គ. មានជំនាញក្នុងការទំនាក់ទំនងជាមួយសហគមន៍គឺជាសមត្ថភាពដើម្បីសហការជាមួយមាតាបិតាសិស្ស ឬអាណាព្យាបាលសិស្ស និងទាក់ទងជាមួយសហគមន៍ដើម្បីជួយដល់ការរៀនរបស់សិស្ស ព្រមទាំងជំរុញឱ្យការគោរពគ្នា និងការចេះរួមរស់ក្នុងវប្បធម៌ចម្រុះ។

ឃ. ជំនាញក្នុងអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ គឺជាសមត្ថភាពដើម្បីស្គាល់មនុស្សផ្សេងទៀត សមត្ថភាពក្នុងការប្រតិបត្តិអំពើល្អរបស់មនុស្ស និងសមត្ថភាពក្នុងការសិក្សាស្វែងយល់អំពីការអនុវត្តការបង្រៀនរបស់ខ្លួន។

## ២.៣ លក្ខណសម្បត្តិរបស់គ្រូបង្រៀននៅកម្ពុជា

គ្រូបង្រៀនជាអ្នកធ្វើការងារផ្ទាល់ជាមួយសិស្ស ជោគវាសនារបស់ពួកគេសង្ឃឹមលើគ្រូបង្រៀនទាំងស្រុង ដូចនេះគ្រូបង្រៀនគប្បីមានលក្ខណសម្បត្តិដូចខាងក្រោម៖

ក.ចំណេះដឹងវិជ្ជាជីវៈ៖ គ្រូបង្រៀនត្រូវមានចំណេះដឹងវិជ្ជាជីវៈទូលំទូលាយ ស្គាល់តម្រូវការសិក្សា សមត្ថភាពសិក្សា ប្រវត្តិសិក្សា និងឥរិយាបថរបស់សិស្សគ្រប់ៗគ្នា ហើយក៏ត្រូវយល់ដឹងផងដែរពីស្ថានភាពគ្រួសារ និងកត្តាផ្សេងៗដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស(យេនឌ័រ ពិការភាព ក្រុមជនជាតិដើមភាគតិច...)។ គ្រូបង្រៀនត្រូវយល់ដឹងពីគោលនយោបាយអប់រំ ជាពិសេសគោលដៅអប់រំជាតិ និងគោល

បំណាងអប់រំចំណេះទូទៅហើយពេញចិត្តក្នុងការអនុវត្តនៅសាលារៀន យល់ពីទ្រឹស្តីក្នុងការរៀបចំកិច្ចតែងការបង្រៀន យល់ពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់មេរៀនបានច្បាស់លាស់ និងយល់ពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយផ្សេងទៀត សំដៅធ្វើឱ្យសិស្សកាន់តែមានចិត្តចង់រៀន។ គ្រូបង្រៀនត្រូវយល់ពីបរិស្ថានអប់រំក្នុងថ្នាក់រៀន និងក្នុងសហគមន៍ ពិសេសយល់ពីរបៀបរៀនរបស់សិស្ស ភាពខុសគ្នារវាងទេពកោសល្យ ល្បឿន និងរបៀបសិក្សាដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស។

ខ.ការប្រត្តិបត្តិវិជ្ជាជីវៈ៖ គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនឱ្យបានច្បាស់លាស់ប្រកបដោយប្រសិទ្ធភាពស្របតាមកម្មវិធីសិក្សាដោយផ្អែកលើសៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារសិក្សាផ្សេងៗទៀតដែលអាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀនត្រូវរៀបចំសម្ភារបង្រៀន និងរៀនសំដៅរិះរកមធ្យោបាយសម្រេចការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព។ គ្រូបង្រៀនក៏ ត្រូវប្រើប្រាស់វិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សាផ្សេងៗគ្នាដែលស្របទៅតាមតម្រូវការ និងទេពកោសល្យរបស់សិស្ស។ គ្រូបង្រៀនត្រូវបញ្ជូនព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតាសិស្ស ឬអាណាព្យាបាលសិស្ស អំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស។ គ្រូបង្រៀនផ្តល់ឱ្យសិស្សគ្រប់រូបនូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យមានការប្រឹងប្រែងអស់ពីសមត្ថភាព ហើយលើកទឹកចិត្តសិស្សឱ្យកាន់តែមានការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន។ គ្រូបង្រៀនត្រូវចូលរួមក្នុងការអភិវឌ្ឍសាលារៀនដើម្បីគាំទ្រការសិក្សា និងសុខុមាលភាពរបស់សិស្ស និងគ្រូបង្រៀនផ្សេងទៀត ហើយត្រូវចេះប្រើប្រាស់វិធីបង្រៀនសម្បូរណ៍បែបដើម្បីសម្រួលដល់ការសិក្សារបស់សិស្ស និងសម្រេចតាមវត្ថុបំណងមេរៀន។

គ.ការសិក្សាវិជ្ជាជីវៈ៖ គ្រូបង្រៀនគឺជាអ្នកលើកទឹកចិត្ត និងជាអ្នកធានាឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សា។ គ្រូបង្រៀនត្រូវតែធ្វើស្វ័យវាយតម្លៃការបង្រៀនដើម្បីអភិវឌ្ឍខ្លួនឯង ព្រមទាំងព្យាយាមស្រាវជ្រាវបន្ថែមអំពីជំនាញឯកទេសរបស់ខ្លួនសំដៅអភិវឌ្ឍគុណវុឌ្ឍិឱ្យកាន់តែប្រសើរជាងមុន។ គ្រូបង្រៀនត្រូវអភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន ហើយធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយសិស្ស មាតាបិតាសិស្ស និងគ្រប់ភាគីពាក់ព័ន្ធផ្សេងៗ។

ឃ. សីលធម៌វិជ្ជាជីវៈ៖ គឺពាក់ព័ន្ធទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងវិជ្ជាជីវៈគ្រូបង្រៀនដែលមានការប្តេជ្ញាចិត្តបង្រៀនសិស្ស ប្រើប្រាស់មនសិការវិជ្ជាជីវៈប្រកបដោយគតិបណ្ឌិត និងមានចំណេះដឹងគ្រប់គ្រាន់តាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ។

គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ច មានវត្តមានជាប្រចាំនៅក្នុងសាលារៀន មានសម្លៀកបំពាក់សមរម្យ និងមានឥរិយាបថថ្លៃថ្នូរ។ គ្រូបង្រៀនគួរតែចូលរួមគ្រប់សកម្មភាពទាំងក្នុងសាលារៀន និង

ក្នុងសហគមន៍ដើម្បីមានទំនាក់ទំនងកាន់តែល្អរវាងគ្រូបង្រៀនក្នុងសាលារៀនជាមួយគ្នា ហើយយល់ដឹងកាន់តែច្រើនបន្ថែមទៀតពីស្ថានភាពរស់នៅជាក់ស្តែងរបស់សិស្សនៅក្នុងសហគមន៍។ គ្រូបង្រៀនដែលប្រកបដោយគុណភាព គឺមិនរើសអើងសិស្សទោះបីក្នុងកាលៈទេសៈណាក៏ ដោយ ដូចជាបញ្ហាយេនឌ័រ ពិការភាព វប្បធម៌ ដើមកំណើត ស្ថានភាពជីវភាពរស់នៅ ហើយត្រូវយកចិត្តទុកដាក់បង្រៀនឱ្យបានស្មើគ្នា។ គ្រូបង្រៀនត្រូវប្រកាន់ចរិយាសម្បត្តិមានសុជីវធម៌ និងអកប្បកិរិយាថ្លៃថ្នូរសម្រាប់សហការជាមួយសហការី និងមាតាបិតាសិស្សដើម្បីផលប្រយោជន៍សិស្ស លើសពីនេះគ្រូបង្រៀនត្រូវធ្វើជាគំរូដល់សិស្សក្នុងការរស់នៅ និងការរៀនសូត្របានល្អ ជាពិសេសចេះលើកកម្ពស់ស្មារតីសិស្សឱ្យរឹងប៉ឹង និងវិជ្ជមានហើយបង្កើតស្មារតីលះបង់ក្នុងការរួមចំណែកចំពោះសហគមន៍ទាំងមូល។

## ២.៤ លក្ខណសម្បត្តិរបស់គ្រូបង្រៀនក្នុងសតវត្សទី២១

បើយោងតាមការវិវត្តនៃពិភពលោក តាមរយៈការធ្វើឱ្យមាននូវសាកលភាវូបនីយកម្មលើគ្រប់ផ្នែកទាំងបច្ចេកវិទ្យា ពាណិជ្ជកម្ម និងការអប់រំក្នុងសម័យបច្ចេកវិទ្យានេះផងដែរនោះ គ្រូបង្រៀនគប្បី ប្រកបទៅដោយលក្ខណៈសម្បត្តិពិសេសចាំបាច់ដូចខាងក្រោម៖

*ក. ចំណេះដឹងឯកទេសវិជ្ជាជីវៈ*

គ្រូបង្រៀនគឺជាជនដែលនៅផ្ទាល់ជាមួយសិស្ស ជាអ្នកផ្ទេរចំណេះដឹងដល់សិស្ស និងជាអ្នកកសាងធនធានមនុស្សសម្រាប់បម្រើឱ្យសេចក្តីត្រូវការរបស់សង្គម ក្នុងការអភិវឌ្ឍសង្គមជាតិមួយដែលពោរពេញទៅដោយសុខសន្តិភាព និងរីកចម្រើនប្រកបដោយចីរភាព។ ចំណេះដឹងច្បាស់លាស់លើមុខវិជ្ជាឯកទេសមានសារៈសំខាន់ណាស់ ក្នុងការធ្វើឱ្យសិស្សទទួលបាននូវសមត្ថភាពពិតប្រាកដ និងមានលក្ខណៈវិទ្យាសាស្ត្រ ដែលអាចជំរុញការសិក្សារបស់សិស្ស ឱ្យទទួលបានជោគជ័យតាមរយៈសកម្មភាពសិក្សាយ៉ាងសកម្ម និងសម្រេចតាមវត្ថុបំណង ឬស្តង់ដាកម្មវិធីសិក្សាដែលបានកំណត់។

*ខ. ចំណេះដឹងទូលំទូលាយ (ក្រៅពីមុខវិជ្ជាឯកទេស)*

គ្រូបង្រៀនទាមទារឱ្យមាននូវចំណេះដឹងទូទៅទូលំទូលាយដែលទាក់ទងទៅនឹងការបំពេញការងារប្រចាំថ្ងៃក្នុងការបង្រៀន។ ពិតណាស់ ការបង្រៀនត្រូវផ្សារភ្ជាប់នូវការអនុវត្តជាក់ស្តែងឬឧទាហរណ៍ផ្សេងៗដែលមានប្រយោជន៍ដល់ការអភិវឌ្ឍបញ្ញា និងស្មារតីរបស់សិស្សដែលជាជំនួយក្នុងការចងចាំទ្រឹស្តីមេរៀនបានល្អនិងយូរអង្វែង។ ចំណេះដឹងទូទៅទាក់ទងនឹងបរិបទសង្គម ជីវភាពប្រចាំថ្ងៃ ពិតជាមានសារប្រយោជន៍សម្រាប់សិស្សក្នុងការពង្រឹងពុទ្ធិ ដើម្បីធ្វើស្វ័យអភិវឌ្ឍបំណិនផ្សេងៗក្នុងការត្រិះរិះពិចារណាប្រកបដោយភាពស៊ីជម្រៅ និងជាមូលដ្ឋានគ្រឹះក្នុងការសម្រេចចិត្តបានត្រឹមត្រូវថែមទៀត។

*គ. បំណិនក្នុងការប្រើវិធីសាស្ត្របង្រៀន*

ការបង្រៀនក្នុងថ្នាក់មួយ គឺតែងតែជួបប្រទះបញ្ហាផ្សេងៗជាក់ជាមិនខាន ដូចជាភាពចម្រុះនៃវប្បធម៌របស់សិស្ស ស្ថានភាពគ្រួសាររបស់សិស្ស និងសមត្ថភាពសិស្សមិនស្មើគ្នាជាដើម។ ក្នុងនោះសមត្ថភាពមិនស្មើគ្នារបស់សិស្សគឺជាបញ្ហាចម្បងជាងគេដែលគ្រូបង្រៀនត្រូវមានវិធីក្នុងការដោះស្រាយដើម្បីឱ្យសិស្សទទួលបានចំណេះដឹងដូចៗគ្នា។ ក្នុងន័យនេះគ្រូបង្រៀនត្រូវដឹងអំពីសមត្ថភាពរបស់សិស្សម្នាក់ៗ ព្រមទាំងចេះប្រើវិធីសាស្រ្តបង្រៀនចម្រុះក្នុងការសម្រេចបានវត្ថុបំណងមេរៀន។ ការប្រើប្រាស់វិធីសាស្រ្តឬយុទ្ធវិធីក្នុងការបង្រៀនទាមទារឱ្យគ្រូបង្រៀនមានចំណេះដឹងច្បាស់លាស់អំពីវិធីសាស្រ្តបង្រៀនភាពប៉ិនប្រសប់ និងហ័សរហួនក្នុងការបត់បែន ដើម្បីធានាបានថាវិធីសាស្រ្តបង្រៀនដែលគាត់បានប្រើ ក្នុងការបង្រៀនមេរៀននោះអាចធ្វើឱ្យសិស្សទាំងអស់ទទួលបានចំណេះដឹងពីការបង្រៀនរបស់គាត់។

ឃ. ចំណេះដឹងលើកម្មវិធីសិក្សា

ការអនុវត្តកម្មវិធីសិក្សា មានសារៈសំខាន់ណាស់ដើម្បីឱ្យការរៀន និងបង្រៀនសម្រេចបានតាមស្តង់ដាកំណត់នៃមុខវិជ្ជានីមួយៗតាមកម្រិតថ្នាក់។ គ្រូបង្រៀនចាំបាច់ត្រូវស្គាល់កម្មវិធីសិក្សា និងគោលបំណងនៃកម្មវិធីសិក្សាព្រមទាំងកត់សម្គាល់នូវចំណុចអវិជ្ជមាន ឬបញ្ហាប្រឈមផ្សេងៗដែលបានជួបប្រទះក្នុងការអនុវត្តកម្មវិធីសិក្សា ដើម្បីធ្វើការកែលម្អកម្មវិធីសិក្សានោះឱ្យមានគុណភាពជាងមុន និងមានភាពឆ្លើយតបចំពោះការបង្រៀននិងរៀនកាន់តែប្រសើរឡើង។

*ង. ចំណេះដឹងក្នុងការកសាងតេស្តវាយតម្លៃ*

ការវាស់ស្ទង់ចំណេះដឹងរបស់សិស្សជាប្រចាំ គឺជាភារកិច្ចរបស់គ្រូបង្រៀន ដើម្បីដឹងអំពីប្រសិទ្ធភាពនៃការបង្រៀន ដឹងអំពីកម្រិតនៃការទទួលបានចំណេះដឹងរបស់សិស្ស និងដើម្បីធ្វើការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សម្នាក់ៗឱ្យបានត្រឹមត្រូវពិតប្រាកដ។ គ្រូបង្រៀនត្រូវមានបំណិនក្នុងការកសាងតេស្ត និងកម្រិតវិញ្ញាសាប្រឡងសម្រាប់សិស្សប្រកបដោយលក្ខណៈវិទ្យាសាស្រ្តដោយផ្អែកលើស្តង់ដាកម្មវិធីសិក្សាដែលបានកំណត់ និងសមស្របទៅតាមទ្រឹស្តីរបស់ប្លូម (Bloom Taxonomy) ដោយមានតាំងពីកម្រិតទាប (កម្រិតចងចាំ) រហូតដល់កម្រិតខ្ពស់ (កម្រិតនៃការបង្កើតថ្មី)។ ចៀសវាងការកសាងតេស្តដោយមិនមានភាពត្រឹមត្រូវសមស្របទៅនឹងសមត្ថភាពរបស់សិស្ស។

*ច. ចំណេះដឹងភាសាបរទេស និងព័ត៌មានវិទ្យា ICT*

នៅក្នុងសម័យបដិវត្តឧស្សាហកម្ម៤.0 ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT)មានសារៈសំខាន់ណាស់សម្រាប់បម្រើឱ្យការរស់នៅរបស់មនុស្ស។ ចំពោះការសិក្សាស្រាវជ្រាវ ភាសាអង់គ្លេស និង ICT បានដើរតួនាទីចម្បងសម្រាប់ការស្វែងរកព័ត៌មានជុំវិញពិភពលោកពីប្រភពឯកសារផ្សេងៗដែលបានធ្វើទំនើបកម្មនៅក្នុងបណ្តាញអ៊ិនធឺណិត (Internet)។ គ្រូបង្រៀនទាមទារឱ្យធ្វើការសិក្សាស្រាវជ្រាវជាប្រចាំ ដើម្បី

អភិវឌ្ឍសមត្ថភាពទៅលើចំណេះដឹងឯកទេសរបស់ខ្លួន និងចំណេះដឹងទូទៅឱ្យសមស្របទៅនឹងការវិវត្តនៃបរិបទអប់រំក្នុងពេលបច្ចុប្បន្ន។

*ឆ. បំណិនក្នុងការប្រាស្រ័យទាក់ទង និងការដោះស្រាយបញ្ហា*

ការប្រាស្រ័យទាក់ទងជាមួយអ្នកនៅជុំវិញខ្លួនគឺជាផ្នែកមួយយ៉ាងសំខាន់ដើម្បីទទួលបានការគាំទ្រពីសហគមន៍ និងមាតាបិតាសិស្ស ដែលលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ។ គ្រូបង្រៀនក៏ទាមទារឱ្យមាននូវបំណិនក្នុងការដោះស្រាយបញ្ហាផងដែរ ដែលបានកើតឡើងក្នុងពេលបង្រៀន ដោយឈរលើស្មារតីសាមគ្គីភាព សមធម៌ និងតម្លាភាព។

ម៉ែនឡី ខាស៊ីមៀ និង ភីដុក (Manley-Casimir and Piddocke, 1991) បានរកឃើញទំនាក់ទំនង១១យ៉ាងដែលជាប់ពាក់ព័ន្ធជាមួយគ្រូបង្រៀន៖(១)ទំនាក់ទំនងជាមួយសិស្សដែលជាទំនាក់ទំនងដំបូងបង្អស់ក្នុងនាមជាគ្រូបង្រៀន(២)ទំនាក់ទំនងជាមួយមាតាបិតាឬអ្នកអាណាព្យាបាលសិស្ស(៣)អ្នករួមអាជីពបង្រៀននៅក្នុងសាលារៀនជាមួយគ្នា (៤)ទំនាក់ទំនងជាមួយបុគ្គលិកផ្សេងទៀតដែលបម្រើការងារក្នុងសាលារៀនជាមួយគ្នា (៥)ទំនាក់ទំនងជាមួយគណៈគ្រប់គ្រងសាលារៀន មានដូចជា នាយកសាលារៀន នាយករង (៦)ទំនាក់ទំនងជាមួយក្រុមប្រឹក្សាភិបាលសាលារៀន ឬគណៈកម្មការគ្រប់គ្រងសាលារៀន (៧)ទំនាក់ទំនងជាមួយសហគមន៍ក្នុងតំបន់របស់សាលារៀន (៨)ទំនាក់ទំនងជាមួយតំបន់នានាដែលសិស្សរស់នៅ (៩)ទំនាក់ទំនងជាមួយរដ្ឋដែលរៀបចំគោលនយោបាយ និងកម្មវិធីសិក្សា ហើយផ្តល់មូលនិធិគាំទ្រតាមរយៈក្រសួងដែលទទួលខុសត្រូវលើវិស័យអប់រំ (១០)ទំនាក់ទំនងជាមួយអ្នកដែលមានអាជីពជាគ្រូបង្រៀនទាំងអស់ (១១)ទំនាក់ទំនងជាមួយគ្រូបង្រៀនផ្ទាល់របស់ខ្លួននៅតាមដេប៉ាតឺម៉ង់ពេលដែលពួកគេរៀននៅសាកលវិទ្យាល័យ ឬគ្រឹះស្ថានអប់រំមុនពេលដែលពួកគេក្លាយជាគ្រូបង្រៀន។ តាមការរកឃើញរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍(OECD) បានកំណត់ថាគ្រូបង្រៀនល្អត្រូវផ្អែកលើកត្តាធំៗចំនួន៥គឺ៖ (១)ចំណេះដឹងលើជំនាញឯកទេស (២)ជំនាញគរុកោសល្យ (៣)ការឆ្លុះបញ្ចាំងអំពីសកម្មភាពបំពេញការងាររបស់ខ្លួន(ស្វ័យវាយតម្លៃលើការបង្រៀនរបស់ខ្លួន) (៤) ការយល់ចិត្ត និងការប្តេជ្ញាចិត្តដើម្បីទទួលស្គាល់ភាពថ្លៃថ្នូររបស់អ្នកដទៃ (៥)សមត្ថភាពនៃការគ្រប់គ្រងដឹកនាំ ចំពោះការងារប្រចាំថ្ងៃរបស់ខ្លួន ទាំងក្នុងនិងក្រៅសាលារៀន។

## ២.៥ ភារកិច្ចរបស់គ្រូបង្រៀន

គ្រូបង្រៀនមានភារកិច្ច ៖(១)បង្រៀនសិស្សដោយផ្ទាល់ឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា (២) រៀបចំផែនការបង្រៀនប្រចាំឆ្នាំ ឆមាស និងខែ តាមមុខវិជ្ជានីមួយៗ(៣) រៀបចំកិច្ចតែងការបង្រៀនជាប្រចាំមុនពេលចូលបង្រៀន(៤) ប្រើប្រាស់វិធីសាស្ត្របង្រៀន ឱ្យសម្រេចវត្ថុបំណងបង្រៀននៃមេរៀន(៥) ផលិតសម្ភារឧបទេស និងដឹកនាំសិស្សឱ្យផលិតសម្ភារឧបទេសសម្រាប់ការ

បង្រៀន និងរៀន(៦) ធ្វើការស្រាវជ្រាវឯកសារដែលទាក់ទងនឹងវិធីសាស្ត្របង្រៀនឱ្យបានច្រើន(៧) ដឹកនាំ និងសម្របសម្រួលការបង្រៀននិងរៀនដើម្បីឱ្យសម្រេចបានទៅតាមការគ្រោងទុក (៨) ចេះប្រើប្រាស់សិល្បៈក្នុងការបង្រៀនដើម្បីទាក់ទាញបម្រុងប្រយ័ត្នសិស្សមកលើមេរៀនជាប្រចាំនិង (៩)ទទួលខុសត្រូវក្នុងការបញ្ចប់កម្មវិធីសិក្សាប្រកបដោយគុណភាព។

ជាមួយគ្នានេះដែរ នៅក្នុងឯកសាររបស់វិទ្យាស្ថានជាតិអប់រំស្ដីអំពីសីលធម៌វិជ្ជាជីវៈ(វិទ្យាស្ថានជាតិអប់រំ សីលធម៌វិជ្ជាជីវៈ ២០០៦ ទំព័រ១៩) បានកំណត់ នូវភារកិច្ចរបស់គ្រូបង្រៀនមានបួនយ៉ាងគឺ៖ (១) មុនពេលបង្រៀនៈ គ្រូបង្រៀនត្រូវស្រាវជ្រាវឯកសារនានាដែលទាក់ទងទៅនឹងមេរៀនដែលត្រូវបង្រៀន បន្ទាប់មកធ្វើកិច្ចតែងការបង្រៀន និងរកវិធីសាស្ត្រថ្មីៗសម្រាប់ត្រៀមបម្រុងទុកពន្យល់សិស្ស (២)ការដឹកនាំបង្រៀនៈ គ្រូបង្រៀនត្រូវបង្ហាញអ្វីដែលថ្មី ចេះធ្វើឱ្យសិស្សចាប់អារម្មណ៍ និងផ្ដោតការគិតទៅលើអ្វីដែលគ្រូពន្យល់។ គ្រូត្រូវពន្យល់សិស្សដោយប្រើសម្ដីច្បាស់ៗ ខ្លីៗ និងត្រូវកំណត់ គោលដៅ ឬវត្ថុបំណង និងអ្វីៗដែលយើងចង់បានឱ្យជាក់លាក់។ ការដឹកនាំការបង្រៀនត្រូវអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល ដែលជាគោលការណ៍មួយទាក់ទងទៅនឹងការរៀន និងការបង្រៀនដោយយកសិស្សជាកត្តាសំខាន់។ (៣)ការលើកទឹកចិត្តសិស្សៈ កុមារក៏ដូចជាសិស្សានុសិស្សដែរ ជាភាវៈមួយដ៏ល្អផូរផង់ពីកំណើត ដែលងាយចាប់យកនូវអ្វីដែលបានឃើញ ឬបានលឺ ទោះជាវត្ថុនោះល្អ ឬអាក្រក់ក៏ដោយ ប៉ុន្តែពួកគេ ត្រូវការការសរសើរ ឬការលើកទឹកចិត្តផងដែរ នូវរាល់សកម្មភាពដែលពួកគេបានធ្វើ ឬរាល់ចម្លើយដែលបានឆ្លើយ (៤)វង្វាយតម្លៃៈ គ្រប់ភារកិច្ចទាំងអស់ ឬរាល់ចម្លើយរបស់សិស្ស គ្រូបង្រៀនត្រូវផ្ដល់ការវាយតម្លៃដ៏ជាក់លាក់មួយ។ វង្វាយតម្លៃនេះបានផ្ដល់នូវភាពយុត្តិធម៌ និងភាពសុចរិតដល់សិស្ស។ នៅពេលដែលសិស្សឆ្លើយនឹងសំណួរ ឬធ្វើការងារអ្វីមួយបានសម្រេច គ្រូត្រូវវាយតម្លៃដោយពាក្យសរសើរ ឬវាយតម្លៃជាពិន្ទុលើកិច្ចការរបស់សិស្ស ដោយភ្ជាប់ជាមួយនូវមូលវិចារជាលាយលក្ខណ៍អក្សរផងដែរ។

## ២.៦ សិទ្ធិ និងភាតព្វកិច្ចរបស់គ្រូបង្រៀន

យោងតាមព្រះរាជក្រម លេខនស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការអប់រំ ត្រង់មាត្រា៣៧បានចែងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់គ្រូបង្រៀនដូចតទៅ ៖

***សិទ្ធិរបស់គ្រូបង្រៀនមានដូចតទៅ៖***(1) សិទ្ធិទទួលបានតម្លៃវិជ្ជាជីវៈ សេចក្ដីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ខ្ពស់ពីសង្គម (2)សិទ្ធិអភិវឌ្ឍខាងវិជ្ជាជីវៈ (3)សិទ្ធិបង្កើត ឬចូលរួមក្នុងសមាគមបុគ្គលិកអប់រំ ឬសមាគមវិជ្ជាជីវៈ ផ្សេងទៀត តាមច្បាប់កំណត់ជាធរមាន(5)សិទ្ធិរៀបចំការប្រជុំលើការងារអប់រំ ជាសាធារណៈ (6)សិទ្ធិចូលរួមនៅក្នុងកិច្ចការនយោបាយតាមច្បាប់កំណត់ (7)សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដោយផ្ទាល់ឬតាមរយៈតំណាងរបស់

ខ្លួន (8) សិទ្ធិទទួលបានសេវាអប់រំផ្សេងទៀត ប្រកបដោយសមធម៌ និងសិទ្ធិផ្សេងទៀត ស្របតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។

***កាតព្វកិច្ចរបស់គ្រូបង្រៀនមានដូចតទៅ៖*** (1) គោរពក្រមសីលធម៌វិជ្ជាជីវៈ (2)បំពេញកាតព្វកិច្ចផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ជាធរមាន និង (3)អនុវត្ត និងអភិវឌ្ឍការងាររបស់ខ្លួនដោយយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់។

## ២.៧ កម្មវិធីកំណែទម្រង់ជាអាទិភាពសម្រាប់ឆ្នាំ២០១៤-២០១៨

ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់កម្មវិធីកំណែទម្រង់ជាអាទិភាពចំនួន១៥ចំណុច ដើម្បីកែលម្អវិស័យអប់រំឱ្យមានភាពប្រសើរឡើងវិញ អាចទទួលយកបាននូវលទ្ធផលល្អ និងអាចប្រកួតប្រជែងក្នុងបណ្តាប្រទេសក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ។ កំណែទម្រង់ជាអាទិភាពទាំង១៥ចំណុចរួមមាន ៖ (1). កំណែទម្រង់ការគ្រប់គ្រងបុគ្គលិក (2) ការពង្រាយគ្រូបង្រៀន (3) កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន (4) ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (5) ការងារអធិការកិច្ច (6)ការវាយតម្លៃលទ្ធផលសិក្សា (7) កំណែទម្រង់ការប្រឡងគ្រប់ប្រភេទ (8) កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល (9)ការសាងសង់អគារសិក្សា និងការជួសជុល (10) ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា (11) ការលើកកម្ពស់វិស័យកីឡា (12) ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន (13) ការអប់រំបច្ចេកទេស (14) ការបង្កើតសាលារៀនជំនាន់ថ្មី (15)ការរៀបចំគន្លងអាជីព និងការបណ្តុះបណ្តាលនាយកសាលា(ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨)។

## ២.៨ គោលនយោបាយស្តីពីគ្រូបង្រៀន(ផែនការសកម្មភាព)

គោលនយោបាយស្តីពីគ្រូបង្រៀន(ឆ្នាំ២០១៣) បានដាក់ចេញនូវចក្ខុវិស័យកសាងគ្រូបង្រៀនឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈដោយមានការទទួលស្គាល់ពីសង្គម ក្នុងគោលបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ ដើម្បីសម្រេចគោលដៅក្នុងការ៖ (1) ទាក់ទាញនិងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន (2)ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន (3)ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារជាប់ជាប្រចាំ និង (4) ធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។

ដើម្បីសម្រេចគោលដៅនៃគោលនយោបាយស្តីពីគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗចំនួន៩ និងយុទ្ធសាស្ត្ររងចំនួន៣៤។ យុទ្ធសាស្ត្រទាំង៩នោះរួមមាន៖ (1).កសាងលិខិតបទដ្ឋានគតិយុត្ត និងយន្តការ (2)ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈគ្រូ

បង្រៀន (3) កំណត់ស្តង់ដាបណ្តុះបណ្តាលគ្រូបង្រៀន (4) អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន (5) ជ្រើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា (6) អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ (7) លើកទឹកចិត្តនិងរក្សាទុកគ្រូបង្រៀន (8) ពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន (9) ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃគ្រូបង្រៀនព្រមទាំងដាក់ចេញនូវផែនការសកម្មភាពដូចជា៖(1) លើកកម្ពស់ជីវភាពតម្លៃវិជ្ជាជីវៈសេចក្តីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ពីសង្គម (2)លើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន (3)កំណត់លក្ខណវិនិច្ឆ័យ និងលក្ខខណ្ឌតតម្រូវខាងវិជ្ជាជីវៈ (4) ធ្វើទំនើបកម្មស្តង់ដាកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ជាតិ និងការប្រកួតប្រជែងក្នុងតំបន់និងសកលលោក(យុទ្ធសាស្រ្តទី២)(5)បណ្តុះវប្បធម៌រៀនពេញមួយជីវិត ដោយចេះចែករំលែកបទពិសោធន៍ជាមួយបណ្តាញក្រុមអ្នកអប់រំ (6) រៀបចំយន្តការប្រកបដោយប្រសិទ្ធភាពដើម្បីគាំទ្រគ្រូបង្រៀននៅនឹងកន្លែងធ្វើការ (7) រៀបចំគោលការណ៍ណែនាំស្តីពីតម្រូវការ និងផលប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈ(យុទ្ធសាស្រ្តទី៦) (8)លើកកម្ពស់លក្ខខណ្ឌធ្វើការងារ និងរស់នៅរបស់គ្រូបង្រៀន តាមរយៈការផ្តល់បៀវត្ស លាភការ សុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅពេលចូលនិវត្តន៍ ជាពិសេសអ្នកគ្រូ និងគ្រូបង្រៀនបម្រើការងារនៅតំបន់ ដាច់ស្រយាលនិងតំបន់ជួបការលំបាក (9) ទទួលស្គាល់នឹងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ (10)លើកកម្ពស់ភាពរីកចម្រើននៃអាជីពស្វ័យភាពនិងការសម្រេចចិត្តក្នុងវិជ្ជាជីវៈរបស់គ្រូបង្រៀនដែលកំណត់ក្នុងច្បាប់ សំដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស (យុទ្ធសាស្រ្តទី៧)។

## ២.៩ ការលើកទឹកចិត្តដល់គ្រូបង្រៀន

ការផ្តល់រង្វាន់លើកទឹកចិត្ត រាប់តាំងពីការសរសើរផ្ទាល់មាត់ ការផ្តល់ប័ណ្ណសរសើរ ការផ្តល់រង្វាន់ការអនុញ្ញាតឱ្យឈប់សម្រាកជាពិសេស ។ល។ លោក Blase (២០០០) បានលើកឡើងថា ការសរសើរពិតជាមានសារៈសំខាន់ណាស់សម្រាប់គ្រូបង្រៀន ពីព្រោះវាជួយលើកទឹកចិត្តបង្កើនការពេញចិត្តចំពោះខ្លួនឯង បង្កើនប្រសិទ្ធភាពការងារ និងជំរុញគ្រូឱ្យមានទម្លាប់ក្នុងការឆ្លុះបញ្ចាំងខ្លួនឯង។ ការសរសើរបានចូលរួមក្នុងការពង្រឹងយុទ្ធសាស្រ្តបង្រៀនឱ្យមានប្រសិទ្ធភាព ព្រោះវាធ្វើឱ្យគ្រូម្នាក់ៗហ៊ានសាកល្បងនូវវិធីសាស្រ្តថ្មី និងមានគំនិតច្នៃប្រឌិតក្នុងការបង្កើតអ្វីដែលប្លែកសម្រាប់ការបង្រៀន។ ការផ្តល់ប័ណ្ណសរសើរឬការផ្តល់រង្វាន់ទោះតិចក្តីច្រើនក្តី ក៏នៅតែជាកម្លាំងជំរុញពីខាងក្រៅដ៏សំខាន់មួយចំពោះលោកគ្រូ-អ្នកគ្រូ ព្រោះវាយ៉ាងហោចណាស់ក៏បានបង្ហាញដល់ពួកគាត់ទាំងនោះថាការខិតខំ របស់គាត់កំពុងតែទទួលបានការគាំទ្រពីសំណាក់ថ្នាក់ដឹកនាំព្រមទាំងសមាជិករួមអាជីព ហើយការធ្វើបែបនេះក៏ជាសញ្ញា

បញ្ជាក់ប្រាប់អ្នកដទៃទៀតថា ពួកគាត់ក៏អាចមានឱកាសទទួលបានការសរសើរដែរ ប្រសិនបើគាត់ខិតខំបំពេញការងារដោយយកចិត្តទុកដាក់ និងប្រកបដោយវិជ្ជាជីវៈ។

យោងប្រកាសលេខ ៧៦១អយក.ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការកំណត់ គោលការណ៍ លក្ខណវិនិច្ឆ័យនិងនីតិវិធីនៃការវាយតម្លៃនាយក នាយិកាសាលារៀនល្អនិងគ្រូបង្រៀន ល្អ សម្រាប់ផ្តល់ពានរង្វាន់ និងថវិកាអមពានរង្វាន់ លើកទឹកចិត្តក្នុងសន្និបាតអប់រំ។ ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលិកអប់រំ និងមានគោលដៅផ្តល់ពានរង្វាន់ និងផ្តល់ថវិកាអមពានរង្វាន់ ដល់ជ័យលាភីនាយក នាយិកាសាលារៀនល្អ និងគ្រូបង្រៀនល្អប្រចាំឆ្នាំសិក្សានីមួយៗ និងលើកទឹកចិត្ត បុគ្គលិកអប់រំដែលមានស្នាដៃជានាយក នាយិកាសាលារៀនល្អ និងគ្រូបង្រៀនល្អ ដើម្បីពង្រឹងការគ្រប់គ្រង និងការបង្រៀនឱ្យមានគុណភាពនិងប្រសិទ្ធភាព។ នៅក្នុងជំពូកទី៣នៃប្រកាសនេះផងដែរ ក៏បានលើកឡើងអំពីការផ្តល់ពានរង្វាន់ និងថវិកាអមពានរង្វាន់លើកទឹកចិត្ត ក្នុងនោះសម្រាប់គ្រូបង្រៀនល្អដែលត្រូវទទួលបានពាន់រង្វានជ័យលាភីពីចំណាត់ថ្នាក់លេខ១ ដល់លេខ៥ មានថវិកា អមពានរង្វាន់ដូចខាងក្រោមៈ

-គ្រូបង្រៀនល្អទទួលពានរង្វាន់លេខ១ ត្រូវទទួលថវិកាចំនួន ៥ ០០០ ០០០ រៀល

-គ្រូបង្រៀនល្អទទួលពានរង្វាន់លេខ២ ត្រូវទទួលថវិកាចំនួន ៤ ០០០ ០០០ រៀល

-គ្រូបង្រៀនល្អទទួលពានរង្វាន់លេខ៣ ត្រូវទទួលថវិកាចំនួន ៣ ០០០ ០០០ រៀល

-គ្រូបង្រៀនល្អទទួលពានរង្វាន់លេខ៤ ត្រូវទទួលថវិកាចំនួន ៣ ០០០ ០០០ រៀល

-គ្រូបង្រៀនល្អទទួលពានរង្វាន់លេខ៥ ត្រូវទទួលថវិកាចំនួន ៣ ០០០ ០០០ រៀល

លើសពីនេះ គ្រូបង្រៀនល្អដែលត្រូវទទួលបានពាន់រង្វាន់ជ័យលាភី និងថវិកាអមពានរង្វាន់ ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងសន្និបាតអប់រំ យុវជន និងកីឡា។ ចំណែកឯគ្រូបង្រៀនចំនួនប្រាំរូប ដែលមិនបានជាប់ជ័យលាភីក្នុងការវាយតម្លៃចុងក្រោយបំផុត នឹងត្រូវបានការលើកទឹកចិត្តផ្តល់ជូនជាប័ណ្ណសរសើរ និងចូលរួមក្នុងសន្និបាតអប់រំ យុវជន និងកីឡា។

ចំពោះការលើកទឹកចិត្តនេះផងដែរ ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់ ដោយបានបង្កើតសកម្មភាពនានា ដូចជាការប្រារព្ធពិធីទិវាគ្រូបង្រៀនកម្ពុជាជាដើម ដែលពិធីនេះធ្វើឡើងដើម្បីសម្តែងនូវការកោតសរសើរ រំលឹកដឹងគុណ លើកតម្លៃ និងលើកទឹកចិត្តដល់គ្រូបង្រៀន ដែលបានធ្វើពលិកម្មនៅក្នុងសមរភូមិបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព ហើយទិវានេះតែងប្រារព្ធស្របគ្នានឹងកាលបរិច្ឆេទនៃទិវាគ្រូបង្រៀនពិភពលោកផងដែរ គឺនៅរៀងរាល់ថ្ងៃទី០៥ ខែតុលា។

## ២.១០ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

យោងតាមព្រះរាជក្រម លេខ ៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើប្រាស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រង់ជំពូកទី៥ បានចែងអំពីវិន័យ និងការដាក់ទណ្ឌកម្មចំពោះអ្នករាជការគឺ៖

មាត្រា៣៣៖ អ្នករាជការរាល់រូប ត្រូវតែគោរពអនុវត្តច្បាប់និងបទបញ្ជា និងការណែនាំថ្នាក់លើរបស់ខ្លួន។ អ្នករាជការត្រូវទទួលខុសត្រូវចំពោះថ្នាក់លើអំពីកិច្ចការរបស់ខ្លួន និងអំពើដែលអាចប៉ះពាល់ទៅដល់សេចក្តីថ្លៃថ្នូរ និងកិត្តិយសរបស់ខ្លួន។ មាត្រា៣៤៖ អ្នករាជការទាំងឡាយមិនអាចឈប់ធ្វើការដោយគ្មានបានទទួលការអនុញ្ញាតជាមុនពីថ្នាក់លើរបស់ខ្លួន ឬដោយគ្មានមូលហេតុត្រឹមត្រូវ។ ការឈប់ធ្វើការ ឬការខានទៅធ្វើការដោយគ្មានការអនុញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវ អាចបង្ខំឱ្យអ្នករាជការនោះនៅទំនេរគ្មានបៀវត្ស ឬត្រូវផ្អាកបៀវត្ស អ្នករាជការនោះអាចនឹងត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា៤០។ នៅក្នុងមាត្រា៣៥ បានលើកឡើងអំពីការហាមឃាត់ជាដាច់ខាត ដល់អ្នករាជការនូវប្រការដូចខាងក្រោម៖

១.យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត

២.យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុត គំរាមកំហែង បំពានសិទ្ធិរបស់ប្រជាពលរដ្ឋ

៣.ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ

៤.ចូលជាសមាជិកក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល

៥.បោះពុម្ព ផ្សាយ ឬធ្វើការផ្សព្វផ្សាយព័ត៌មានដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័នដែលសាមីខ្លួននៅក្រោមឱវាទ

៦.ប្រកបមុខរបរបន្ថែមគ្រួតពីលើមុខងាររបស់ខ្លួនជាអ្នករាជការ ក្នុងករណីដែលលក្ខន្តិក ដោយឡែកនៃអង្គនីមួយៗហាមឃាត់។

នៅពេលដែលអ្នករាជការមានកំហុសត្រូវទទួលទណ្ឌកម្មខាងវិន័យដូចតទៅ៖

១.ទណ្ឌកម្មថ្នាក់ទី១

-ស្តីបន្ទោស

-ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន

-ផ្លាស់ដោយបង្ខំតាមវិធានការវិន័យ

-លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តឬថ្នាក់

២.ទណ្ឌកម្មថ្នាក់ទី២

-ស្តីបន្ទោសជាទម្ងន់បណ្តាលឱ្យលុបចេញពីតារាងឡើងឋានន្តរស័ក្កឬថ្នាក់

-ដាក់ឱ្យនៅទំនេរគ្មានបៀវត្សមិន ឱ្យលើសពីមួយឆ្នាំ

-បន្ថយ ឋានន្តរស័ក្ក ឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់

-ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ ពីការងារដោយបង្ខំ

-បណ្តេញចេញពីមុខតំណែងរាជការ (ជំពូកទី៥ មាត្រា៤០/ ទំព័រទី១១និង១២/ ១៩៩៤)

មាត្រ៣៨៖ អ្នករាជការទាំងអស់ត្រូវបង្ហាញឱ្យឃើញថា ខ្លួនមានសមត្ថភាពវិជ្ជាជីវៈជាដរាបក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន។ អ្នករាជការទាំងត្រូវទទួលខុសត្រូវពីកំហុស និងការផ្គាំផ្គងក្នុងវិជ្ជាជីវៈព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងមុខងាររបស់ខ្លួន។

## ២.១១ អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

នៅក្នុងមាត្រា២នៃអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០០៨ មានគោលបំណង៖ (1)លើកកម្ពស់សីលធម៌របស់គ្រូបង្រៀន (2) លើកកម្ពស់សេចក្តីថ្លៃថ្នូររបស់គ្រូបង្រៀន (3)លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំ។ ហើយនៅក្នុងមាត្រា៤៖ បុគ្គលិកអប់រំនៅក្នុងអនុក្រឹត្យនេះសំដៅដល់បុគ្គលិកបង្រៀននៃបុគ្គលិកអប់រំ នៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ និងគ្រឹះស្ថានសិក្សាឯកជនដែលមានអាជ្ញាប័ណ្ណអប់រំ។ មាត្រា៨៖ គ្រូបង្រៀនប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ។ គ្រូបង្រៀនមានករណីយកិច្ចរៀបចំកិច្ចតែងការបង្រៀន និងកំណត់ពន្យល់សំដៅជានាគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន។ មាត្រា៩៖ គ្រូបង្រៀនត្រូវស្វ័យសិក្សា និងស្រាវជ្រាវសម្រិតសម្រាំងបង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមគ្រប់សកម្មភាពបណ្តុះបណ្តាលជាប្រចាំ។ គ្រូបង្រៀនត្រូវធ្វើការស្វ័យវាយតម្លៃ និងវាយតម្លៃលើការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣៖ វិធីសាស្រ្តស្រាវជ្រាវ

## ៣.១. ភាគសំណាកនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះ យើងបានប្រើប្រាស់វិធីសាស្រ្តជ្រើសរើសសំណាកមិនចៃដន្យ(Non-probability sampling) គឺជាវិធីសាស្រ្តស្រាវជ្រាវដែលធ្វើទៅតាមបំណងរបស់អ្នកស្រាវជ្រា(Purposive sampling) ដើម្បីប្រមូលភាគសំណាក។ អ្នកស្រាវជ្រាវបានជ្រើសរើសយកសំណាក១៩៧ ដែលក្នុងនោះ ថ្នាក់ដឹកនាំស្ថាប័នអប់រំថ្នាក់ខេត្ត និងគណៈគ្រប់គ្រងសាលាត្រូវបំពេញកម្រងសំណួរតែពីរផ្នែកប៉ុណ្ណោះគឺ ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន និងផ្នែកទី៥ ទស្សនៈយល់ឃើញអំពីយុទ្ធសាស្រ្តជំរុញគ្រូបង្រៀនឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ។ ថ្នាក់ដឹកនាំស្ថាប័នអប់រំថ្នាក់ខេត្តដែលចូលរួមបំពេញកម្រងសំណួររួមមាន៖ ថ្នាក់ដឹកនាំមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ស្ពឺចំនួន០៤នាក់ ថ្នាក់ដឹកនាំការិយាល័យមធ្យមសិក្សាចំណេះទូទៅចំនួន០៣នាក់ ថ្នាក់ដឹកនាំការិយាល័យបុគ្គលិកចំនួន០៣នាក់ ថ្នាក់ដឹកនាំការិយាល័យអធិការកិច្ចចំនួន០៣នាក់ លោក លោកស្រីជានាយក នាយិកា និងនាយករង/នាយិការងចំនួន២៤នាក់ និង បុគ្គលិកបង្រៀនចំនួន១៦០នាក់ ក្នុងចំណោមបុគ្គលិកបង្រៀនសរុបចំនួន៨៦៤នាក់នៃអនុវិទ្យាល័យទាំង៧១ក្នុងក្រុង/ស្រុកទាំងប្រាំបី។ ក្នុងចំណោមអនុវិទ្យាល័យចំនួនដប់ប្រាំមួយនោះ មានអនុវិទ្យាល័យប្រាំបីស្ថិតនៅទីប្រជុំជន និងអនុវិទ្យាល័យប្រាំបីទៀតស្ថិតនៅជនបទ។ ភាគសំណាកដែលជាបុគ្គលិកបង្រៀនត្រូវបំពេញកម្រងសំណួរដែលមានប្រាំផ្នែកគឺ ផ្នែកទី១ព័ត៌មានផ្ទាល់ខ្លួន ផ្នែកទី២ចំណេះដឹងអំពីម៉ោងពេលបំពេញការងារប្រចាំសប្តាហ៍របស់គ្រូបង្រៀន ផ្នែកទី៣ ការអនុវត្តជាក់ស្តែងនៃម៉ោងពេលបំពេញការងារប្រចាំសប្តាហ៍របស់គ្រូបង្រៀន ផ្នែកទី៤ការបំពេញភារកិច្ចតាមស្តង់ដាវិជ្ជាគ្រូបង្រៀន និងផ្នែកទី៥ ទស្សនៈយល់ឃើញអំពីយុទ្ធសាស្រ្តជំរុញគ្រូបង្រៀនឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ។ ក្នុងនោះភាគសំណាគចំនួន៨០ត្រូវបានជ្រើសរើសចេញពីអនុវិទ្យាល័យដែលស្ថិតនៅទីប្រជុំជននៃក្រុង/ស្រុកទាំងប្រាំបី និងភាគសំណាកចំនួន៨០ទៀតត្រូវបានជ្រើសរើសចេញពីអនុវិទ្យាល័យដែលស្ថិតនៅតំបន់ជនបទនៃក្រុង/ស្រុកដដែល។ ការជ្រើសរើសភាគសំណាកតាមវិធីនេះអាចធ្វើជាតំណាងនៃក្រុង/ស្រុកនីមួយៗប្រកបដោយភាពជឿជាក់ ពីព្រោះភាគសំណាកដែលជ្រើសរើសយកគឺដើម្បីតំណាងឱ្យតំបន់ទាំងមូល។

តារាងចំនួនសំណាកដែលបានជ្រើសរើសនៅតាមគោលដៅ៖

| **ចំនួនភាគសំណាកសរុប ១៩៧** | | | | | |
|---|---|---|---|---|---|
| **ល.រ** | **ក្រុមគោលដៅ** | **ក្រុង/ស្រុក** | **មុខសញ្ញាត្រូវសម្ភាសន៍** | | **សរុប** |
| ក | កម្រិតមន្ទីរអយក.ខេត្ត | | ថ្នាក់ដឹកនាំមន្ទីរអេយក | ថ្នាក់ដឹកនាំការិយាល័យ | សរុប |
| ១ | មន្ទីរអេយក.កំពង់ស្ពឺ | ច្បារមន | ៤ | ៩ | ១៣ |
| ខ | កម្រិតអនុវិទ្យាល័យ | | នាយក/នាយករង | គ្រូបង្រៀន | សរុប |
| ១ | អនុវិ.ទីរួមខេត្ត | ច្បារមន | ១ | ១០ | ២០ |

| | | | | | |
|---|---|---|---|---|---|
| ២ | អនុវិ.ម្រុំខាងត្បូង | | ១ | ១០ | |
| ៣ | អនុវិ.ហស សំរោងទង | សំរោងទង | ១ | ១០ | ២០ |
| ៤ | អនុវិ.អង្គខ្មៅ | | ២ | ១០ | |
| ៥ | អនុវិ.មហាសាំង | ភ្នំស្រួច | ២ | ១០ | ២០ |
| ៦ | អនុវិ.ព្រៃក្មេង | | ១ | ១០ | |
| ៧ | អនុវិ.សង្គមសិក្សា | ឧដុង្គ | ១ | ១០ | ២០ |
| ៨ | អនុវិ.បន្ទាយខ្មែរ | | ១ | ១០ | |
| ៩ | អនុវិ.ស្រង់ | គងពិសី | ២ | ១០ | ២០ |
| ១០ | អនុវិ.សែនទាវ | | ២ | ១០ | |
| ១១ | អនុវិ.ហ.ស បរសេដ្ឋ | បរសេដ្ឋ | ១ | ១០ | ២០ |
| ១២ | អនុវិ.អង្គលំទង | | ២ | ១០ | |
| ១៣ | អនុវិ.វត្តត្បែង | ថ្ពង | ២ | ១០ | ២០ |
| ១៤ | អនុវិ. អមលាំង | | ២ | ១០ | |
| ១៥ | អនុវិ.បន្ទាយប្រណាក | ឱរ៉ាល់ | ២ | ១០ | ២០ |
| ១៦ | អនុវិ. រ៉ូតារី | | ១ | ១០ | |
| សរុបរួម | | | ២៤ | ១៦០ | ១៩៧ |

## ៣.២. ឧបករណ៍ស្រាវជ្រាវ

### ៣.២.១ ការបង្កើតខ្លឹមសារ

ចំពោះឧបករណ៍ស្រាវជ្រាវវិញ អ្នកស្រាវជ្រាវបានរៀបចំបង្កើតកម្រងសំណួរជាពីរប្រភេទៈកម្រងសំណួរប្រភេទទី១មានពីរផ្នែកដែលត្រូវចំណាយពេលពី២០ ទៅ៣០នាទី សម្រាប់ធ្វើការចុះសម្ភាសន៍ជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ ថ្នាក់ដឹកនាំការិយាល័យមធ្យមសិក្សាចំណេះទូទៅ ថ្នាក់ដឹកនាំការិយាល័យបុគ្គលិក ថ្នាក់ដឹកនាំការិយាល័យអធិការកិច្ច និងគណៈគ្រប់គ្រងសាលា និងកម្រងសំណួរប្រភេទទី២ មានប្រាំផ្នែកសម្រាប់ លោកគ្រូ-អ្នកគ្រូ( បុគ្គលិកបង្រៀន ) ធ្វើការបំពេញដែលចំណាយពេលប្រមាណពី៤៥ ទៅ៦០នាទី។ វិធីសាស្ត្រដែលបានជ្រើសរើសនៅក្នុងការសិក្សាស្រាវជ្រាវនេះគឺជាការស្ទង់មតិ ដើម្បីសិក្សាពីស្ថានភាពនៃការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀននិងដើម្បីសិក្សាពីយុទ្ធសាស្ត្រជំរុញគ្រូបង្រៀននៅកម្រិតមធ្យសិក្សាបឋមភូមិឱ្យប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈក្នុងការបំពេញភារកិច្ចបង្រៀនប្រចាំថ្ងៃរបស់ខ្លួន។ កម្រងសំណួរទាំងពីរប្រភេទនេះត្រូវបានរៀបចំឡើងតាម Google forms។ តំណនៃកម្រងសំណួរទាំងពីរប្រភេទនេះត្រូវបានបញ្ជូនទៅកាន់អ្នកពាក់ព័ន្ធទាំងអស់តាមរយៈតេឡេក្រាមដែលយើងខ្ញុំបានភ្ជាប់ជាមួយពួកគាត់។

ក្នុងការបង្កើតកម្រងសំណួរទាំងនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់ឯកសារជំនួយខ្លះៗ ហើយបានកែសម្រួលខ្លឹមសារមួយចំនួនដើម្បីឱ្យស្របទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា។ ឯកសារជំនួយដែលត្រូវបានប្រើប្រាស់សម្រាប់ការបង្កើតកម្រងសំណួរនេះមានប្រភពផ្សេងៗគ្នាដូចជា៖ (១)ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០០៨ ដូចមានចែងក្នុងអនុក្រឹត្យ១២៦.អនក្រ.បក (២)ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៤ (៣)ម៉ោងពេលបំពេញភារកិច្ចប្រចាំសប្តាហ៍របស់បុគ្គលិកអប់រំ (៤)លក្ខណៈសម្បត្តិរបស់គ្រូបង្រៀនប្រទេសអាស៊ាន (៥)លក្ខណៈវិជ្ជាជីគ្រូបង្រៀនកម្ពុជាឆ្នាំ២០១០ (៦)គន្លងអាជីពគ្រូបង្រៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា (៧)ផែនការយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំឆ្នាំ២០១៤-២០១៨។

## ៣.២.២ ទម្រង់កម្រងសំណួរ

**ផ្នែកទី១** ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន៤សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងអំពី ទីតាំងអនុវិទ្យាល័យ តួនាទី ភេទ និងបទពិសោធន៍បំពេញការងារក្នុងវិស័យអប់រំរបស់បុគ្គលិកអប់រំ។

**ផ្នែកទី២** ចំណេះដឹងអំពីម៉ោងពេលបំពេញការងារប្រចាំសប្តាហ៍របស់គ្រូបង្រៀន ដែលមាន១៤សំណួរ។ អ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញនូវកម្រិតយល់ដឹងរបស់គ្រូបង្រៀនដែលចូលរួមបំពេញកម្រងសំណួរ ចំពោះម៉ោងពេលបំពេញភារកិច្ចប្រចាំសប្តាហ៍របស់គ្រូបង្រៀនដែលកំណត់ដោយច្បាប់។

**ផ្នែកទី៣** ការអនុវត្តជាក់ស្តែងនៃម៉ោងពេលបំពេញការងារប្រចាំសប្តាហ៍របស់ខ្លួនដែលមាន១៤សំណួរដូចផ្នែកទី២ដែរ។ អ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញពីម៉ោងពេលបំពេញភារកិច្ចជាក់ស្តែងរបស់គ្រូបង្រៀន ដែលបានចូលរួមបំពេញកម្រងសំណួរដោយផ្អែកតាមបំណែងចែកភារកិច្ចប្រចាំឆ្នាំ របស់គ្រឹះស្ថានមធ្យមសិក្សាដែលខ្លួនកំពុងបំពេញភារកិច្ច។

**ផ្នែកទី៤** ការបំពេញភារកិច្ចតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ដែលមាន២០សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងអំពីកម្រិតនៃការបំពេញភារកិច្ចប្រចាំថ្ងៃរបស់គ្រូបង្រៀនដែលបានចូលរួមបំពេញកម្រងសំណួរផ្អែកតាមសមាសភាគទាំងបួននៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនគឺចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ។

**ផ្នែកទី៥៖** ទស្សនៈអំពីយុទ្ធសាស្ត្រជំរុញគ្រូបង្រៀនឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ ដែលមាន១១ចំណុច។ អ្នកស្រាវជ្រាវចង់ស្វែងយល់អំពីមតិយោបល់របស់អ្នកចូលរួមបំពេញកម្រងសំណួរដើម្បីកំណត់អាទិភាពចាំបាច់ចំនួនបី និងអាទិភាពបន្ទាប់ចំនួនបីក្នុងចំណោមសូចនាករទាំង១១ចំណុចដែលមាននៅក្នុងកម្រងសំណួរ។ សមាសភាពដែលត្រូវចូលបំពេញកម្រងសំណួរផ្នែកទី៥នេះ រួមមាន៖ (១)ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ (២)ថ្នាក់ដឹកនាំការិយាល័យមធ្យមសិក្សាចំណេះទូទៅ (៣)ថ្នាក់

ដឹកនាំការិយាល័យបុគ្គលិក (៤)ថ្នាក់ដឹកនាំការិយាល័យអធិការកិច្ច (៥)គណៈគ្រប់គ្រងនៃអនុវិទ្យាល័យគោលដៅទាំង១៦ និង(៦)គ្រូបង្រៀន(បុគ្គលិកបង្រៀន) នៃអនុវិទ្យាល័យទាំង១៦។

## ៣.៣ នីតិវិធី និងដំណើរការប្រមូលទិន្នន័យ

ក្រៅពីទ្រឹស្តី និងទិន្នន័យដែលមានស្រាប់ យើងក៏បានបញ្ជូនកម្រងសំណួរតាមប្រព័ន្ធអនឡាយដើម្បីប្រមូលទិន្នន័យជាក់ស្តែងនៅតាមគោលដៅនានា ដើម្បីទទួលបានទិន្នន័យបឋមសម្រាប់យកមកវិភាគក្នុងការសិក្សាស្រាវជ្រាវនេះ។ នៅក្នុងការប្រមូលទិន្នន័យនេះដែរ គឺយើងបានប្រើប្រាស់រយៈពេល២សប្តាហ៍ ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ ហើយយើងងបានទំនាក់ទំនងជាមួយថ្នាក់ដឹកនាំមន្ទីរ ថ្នាក់ដឹកនាំការិយាល័យជុំវិញមន្ទីរ នាយកអនុវិទ្យាល័យ ដើម្បីបញ្ជូនលិខិតបទដ្ឋាននៃការចុះប្រមូលទិន្នន័យនៅតាមគោលដៅនីមួយៗ បន្ទាប់មកយើងក៏ បានបញ្ជូនតំណនៃកម្រងសំណួរដែលបានរៀបចំឡើងតាមហ្គោកហ្គលហ្វម(Google forms)ទៅកាន់អនុវិទ្យាល័យគោលដៅចំនួន១៦នៅស្រុក/ក្រុងទាំង៨ ពោលគឺចុះសិក្សាស្រាវជ្រាវនៅគ្រប់ស្រុក/ក្រុងទាំងអស់នៃខេត្តកំពង់ស្ពឺ ក្នុងនោះ ក្រុងច្បារមនមាន០២អនុ វិទ្យាល័យ ស្រុកសំរោងទងមាន០២វិទ្យាល័យ ស្រុកភ្នំស្រួចមាន០២អនុវិទ្យាល័យ ស្រុកឧដុង្គមាន០២អនុវិទ្យាល័យ ស្រុកគងពិសីមាន០២អនុវិទ្យាល័យ ស្រុកបរសេដ្ឋមាន០២អនុវិទ្យាល័យ ស្រុកថ្ពងមាន០២អនុវិទ្យាល័យ និងស្រុកឱរ៉ាល់មាន០២អនុវិទ្យាល័យ។ ការជ្រើសរើសចំនួនអនុវិទ្យាល័យពីក្នុង ក្រុង ស្រុកនីមួយៗដោយកំណត់យកអនុវិទ្យាល័យមួយស្ថិតក្នុងតំបន់ទីប្រជុំជន និងអនុវិទ្យាល័យមួយទៀតស្ថិតក្នុងតំបន់ជនបទនៃក្រុង ស្រុកទាំងនោះដើម្បីធ្វើជាតំណាងក្រុងស្រុកទាំងអស់នោះ។

មុនពេលបញ្ជូនកម្រងសំណួរនេះដល់អ្នកចូលរួមផ្តល់ព័ត៌មាន ជាដំបូងយើងបានយកលិខិតដែលចេញដោយវិទ្យាស្ថានជាតិអប់រំ លេខ២៤០អយក.វជអ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ដើម្បីធ្វើសំណើបន្ត ទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ ដើម្បីសុំការអនុញ្ញាតចុះប្រមូលទិន្នន័យ។ បន្ទាប់ពីបានលិខិតអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារួចមក អ្នកស្រាវជ្រាវក៏បានយកលិខិតស្នើសុំនោះទៅប្រគល់ជូនលោក លោកស្រី ជាថ្នាក់ដឹកនាំមន្ទីរ ថ្នាក់ដឹកនាំការិយាល័យ និងនាយក នាយិកា តាមតេឡេក្រាម។ បន្ទាប់មក យើងបានជួបជាមួយនាយក នាយិកាសាលាដើម្បីជម្រាបពួកគាត់ពីគោលបំណងនៃការចុះសិក្សាស្រាវជ្រាវ ក្រមសីលធម៌នៃការស្រាវជ្រាវ និងប្រយោជន៍ដើម្បីទទួលបានការចូលរួម ព្រមទាំងសុំការអនុញ្ញាតដើម្បីឱ្យគាត់ជួយផ្តល់បទសម្ភាសន៍ ក៏ដូចជាសាកសួរព័ត៌មានអំពីលោកគ្រូ អ្នកគ្រូដែលត្រូវបំពេញកម្រងសំណួរ។ បន្ទាប់មកទៀតយើងខ្ញុំក៏បានបញ្ជូនកម្រងសំណួរដែលមាននៅក្នុងតំណតាមរយៈតេឡេក្រាមផ្ទាល់ខ្លួនរបស់នាយក នាយិកា និងគ្រុបតេឡេក្រាមរបស់សាលារៀននីមួយៗទៅដល់អ្នកចូលរួមទាំងអស់ចំនួន១៦០នាក់។ ប៉ុន្តែពេលបឆ្លើយមកវិញបានតែ១៣៥នាក់ប៉ុណ្ណោះ ដោយអ្នកចូលរួមឆ្លើយចំនួន២៥នាក់មិនបានបញ្ជូនកម្រងសំណួររបស់ខ្លួនត្រឡប់មកវិញទេ។ ក្នុងនោះអនុវិទ្យាល័យទី

រួមខេត្តបានឆ្លើយតបមកវិញចំនួន០៩នាក់ អនុវិទ្យាល័យម្រុំខាងត្បូងបានឆ្លើយតបមកវិញចំនួន០៥នាក់ អនុវិទ្យាល័យហ៊ុនសែនសំរោងទងបានឆ្លើយតបមកវិញចំនួន០៨នាក់ អនុវិទ្យាល័យអង្គខ្មៅបានឆ្លើយតបមកវិញចំនួន១០នាក់ អនុវិទ្យាល័យមហាសាំងបានឆ្លើយតបមកវិញចំនួន១០នាក់ អនុវិទ្យាល័យព្រៃក្មេងបានឆ្លើយតបមកវិញចំនួន០៩នាក់ អនុវិទ្យាល័យសង្គមសិក្សាបានឆ្លើយតបមកវិញចំនួន០៥នាក់ អនុវិទ្យាល័យបន្ទាយខ្មែរបានឆ្លើយតបមកវិញចំនួន០៩នាក់ អនុវិទ្យាល័យស្រង់បានចំនួន០៩នាក់ អនុវិទ្យាល័យសែនទាវបានចំនួន០៨នាក់ អនុវិទ្យាល័យហ៊ុនសែនបរសេដ្ឋបានចំនួន១០នាក់ អនុវិទ្យាល័យអង្គលំទងបានចំនួន១០នាក់ អនុវិទ្យាល័យវត្តត្បែងបានចំនួន០៦នាក់ អនុវិទ្យាល័យអមលាំងបានចំនួន០៨នាក់ អនុវិទ្យាល័យបន្ទាយប្រណាកបាន១០នាក់ អនុវិទ្យាល័យរ៉ូតារីបាន០៦នាក់។ ចំពោះថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា ថ្នាក់ដឹកនាំការិយាល័យ និងនាយក នាយករង សរុបចំនួន៣៧នាក់ដែលត្រូវបំពេញកម្រងសំណួរអំពីទស្សនៈយល់ឃើញអំពីការបង្កើតយុទ្ធសាស្ត្រដើម្បីជំរុញគ្រូបង្រៀននៅអនុវិទ្យាល័យឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ គឺបានឆ្លើយមកវិញចំនួន៣៥នាក់ គឺបានអនុប្រធានមន្ទីរ០១នាក់ និងនាយកឬនាយករង០១នាក់។ ក្នុងការបំពេញកម្រងសំណួរទាំងនេះ យើងខ្ញុំបានអនុញ្ញាតឱ្យពួកគាត់បំពេញកម្រងសំណួរនៅពេលណាក៏បានអាស្រ័យលើពេលវេលានិងលទ្ធភាព(សេវាអ៊ិនធឺណិត) របស់ពួកគាត់ហើយយើងខ្ញុំបានទំនាក់ទំនងជាមួយពួកគាត់គ្រប់ពេលតាមតេឡេក្រាមដើម្បីពន្យល់នូវចំណុចទាំងឡាយណាដែលពួកគាត់ចង់សាកសួរព័ត៌មានបន្ថែមក្នុងករណីមានសំណួរ ឬចម្ងល់។ យើងខ្ញុំយកចិត្តទុកដាក់ក្នុងការសម្របសម្រួល និងសហការជាមួយក្រុមគោលដៅទាំងអស់ ដើម្បីទទួលបានព័ត៌មានមួយអាចជឿទុកចិត្តបានសម្រាប់យកទៅវិភាគក្នុងការសិក្សាស្រាវជ្រាវ។ ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ ថ្នាក់ដឹកនាំការិយាល័យមធ្យសិក្សាចំណេះទូទៅ ថ្នាក់ដឹកនាំការិយាល័យបុគ្គលិក ថ្នាក់ដឹកនាំការិយាល័យអធិការកិច្ច និងគណៈគ្រប់គ្រងសាលា បានផ្តល់កម្រងសំណួរត្រឡប់មកវិញគ្រប់ចំនួន ប៉ុន្តែលោកគ្រូអ្នកគ្រូដែលបានចូលរួមបំពេញកម្រងសំណួរទាំង១៦០នាក់ បានបញ្ជូនកម្រងសំណួររបស់ខ្លួនត្រឡប់មកវិញបានត្រឹមតែ១៣៥នាក់ប៉ុណ្ណោះ គឺបាត់២៥នាក់។ សម្រាប់ចំនួន២៥នាក់ដែលបានបាត់នេះអាចបណ្តាលមកពីបញ្ហាបច្ចេកទេស គឺប្រហែលពួកគាត់ឆ្លើយរំលងសំណួរណាមួយដែលជាមូលហេតុធ្វើឱ្យបញ្ជូនកម្រងសំណួររបស់ខ្លួនត្រឡប់មកវិញមិនបានជោគជ័យ។ ម្យ៉ាងទៀតនៅតំបន់ខ្លះមិនមានសេវាអ៊ីនធឺនែត និងមួយចំនួនទៀតមិនបានបំពេញតែម្តងអាចមកពីពួកគាត់មិនសូវយល់ពីការចូលតាមរយៈតំណ ហើយមួយចំនួនទៀតអាចគេចវេសន៍មិនចូលរួមបំពេញកម្រងសំណួរ។

### ៣.៤. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យដែលទទួលបាន តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវប្រើប្រាស់កម្មវិធីSPSS ដើម្បីវិភាគតាមបែបបរិមាណវិស័យ និងកម្មវិធី Ms. Excel ដើម្បីបង្កើតក្រាហ្វិក។ ដូច្នេះនៅក្នុង

ការវិភាគចម្លើយ ចំពោះរាល់សំណួរទាំងអស់ត្រូវបានធ្វើការវិភាគ គឺអាស្រ័យទៅលើប្រភេទសំណួរ ។ ចំពោះការវិភាគនេះអ្នកសិក្សាស្រាវជ្រាវបានវិភាគលើចំណុចសំខាន់មួយចំនួន ដូចជា៖ កម្រិតនៃការយល់ដឹងពីខ្លឹមសារ និងសកម្មភាពនៅក្នុងការបំពេញភារៈកិច្ចទៅតាមម៉ោងពេលដែលបានកំណត់ដោយច្បាប់ កម្រិតនៃការពេញចិត្តចំពោះការបំពេញភារៈកិច្ចដោយផ្អែកលើលក្ខណៈសម្បត្តិគ្រូបង្រៀនកម្ពុជា សិក្សាប្រៀបធៀបបញ្ហាប្រឈមសំខាន់ៗដែលអនុវិទ្យាល័យនៅតំបន់ប្រជុំជន និងតំបន់ជនបទនៃក្រុងស្រុកនីមួយៗជួបប្រទះ និងទស្សនៈយល់ឃើញដើម្បីបង្កើតយុសាស្ត្រជំរុញគ្រូបង្រៀនឱ្យប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈបានខ្ជាប់ខ្ជួនក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃរបស់ខ្លួនដែលគិតជាហ្រ្វេកង់ និងគិតជាភាគរយ។

រាល់ទិន្នន័យទាំងអស់ដែលបានធ្វើការវិភាគរួច នឹងត្រូវបានទាញចេញមកបង្ហាញទៅតាមគោលបំណងសំខាន់ៗទាំងពីរនៃការសិក្សាស្រាវជ្រាវ ដើម្បីងាយស្រួលក្នុងការបង្ហាញ និងធ្វើសេចក្តីសន្និដ្ឋានពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ។ បន្ទាប់ពីទទួលបានលទ្ធផលហើយ យើងនឹងទាញសេចក្តីសន្និដ្ឋានព្រមទាំងធ្វើការផ្ទៀងផ្ទាត់ជាមួយចំណោទបញ្ហាដែលបានលើកឡើងជាសំណួរស្រាវជ្រាវ និងគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ ហើយធ្វើការវាយតម្លៃទៅលើស្ថានភាពនៃការបង្កើយុទ្ធសាស្ត្រដើម្បីជំរុញគ្រូបង្រៀនកម្រិតមធ្យសិក្សាបឋមភូមិឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។ ជាចុងក្រោយបន្ទាប់ពីកំណត់បាននូវបញ្ហាប្រឈមក្នុងការក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃរបស់លោកគ្រូអ្នកគ្រូ យើងនឹងផ្តល់អនុសាសន៍មួយចំនួនដល់ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាក្នុងការបង្កើតយុទ្ធសាស្ត្រជំរុញគ្រូបង្រៀនឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

### ៣.៤.១ ឧបករណ៍វិភាគទិន្នន័យ

ដើម្បីវិភាគទិន្នន័យ យើងប្រើកម្មវិធីSPSS ពីព្រោះទិន្នន័យទាំងអស់ដែលទទួលបានកម្រងសំណួរនៃការស្រាវជ្រាវនេះ គឺជាទិន្នន័យបែបបរិមាណវិស័យ។ កម្មវិធីSPSS ត្រូវបានប្រើប្រាស់សម្រាប់បញ្ចូលទិន្នន័យ និងវិភាគ ដើម្បីស្វែងរកកម្រិតយល់ដឹង កម្រិតអនុវត្តម៉ោងពេលបំពេញភារកិច្ចប្រចាំសប្តាហ៍របស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ កម្រិតយល់ដឹងអំពីស្តង់ដាវិជ្ជាជីវៈ និងកម្រិតយល់ឃើញនៃការកំណត់អាទិភាពក្នុងការបង្កើតយុទ្ធសាស្ត្រជំរុញគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិអោយបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ដែលគិតជាហ្រ្វេកង់ និងគិតជាភាគរយ។

### ៣.៤.២ ដំណាក់កាលនៃការវិភាគទិន្នន័យ

នៅក្នុងដំណាក់កាលនៃការវិភាគទិន្នន័យ អ្នកសិក្សាស្រាវជ្រាវធ្វើការវិភាគទិន្នន័យដែលប្រមូលបានតាមរយៈការបំពេញកម្រងសំណួរពីអ្នកចូលរួមនានា។ ការវិភាគកម្រងសំណួរមានគោលបំណងស្វែងរកឲ្យឃើញ ពីកម្រិតនៃការយល់ដឹងរបស់ពួកគាត់ទាក់ទងនឹងម៉ោងពេលបំពេញភារកិច្ចប្រចាំសប្តាហ៍

របស់គ្រូបង្រៀន។ ការបំពេញភារកិច្ចតាមបំណែងចែកភារកិច្ចរបស់អនុវិទ្យាល័យដែលពួកគាត់កំពុងបំពេញការងារ ការយល់ដឹងអំពីស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងទស្សនៈយល់ឃើញរបស់ថ្នាក់ដឹកនាំមន្ទីរ ថ្នាក់ដឹកនាំការិយាល័យជំនាញ និងការិយាល័យពាក់ព័ន្ធ នាយក នាយករង និងលោកគ្រូ អ្នកគ្រូក្នុងការបង្កើតយុទ្ធសាស្រ្តដើម្បីជំរុញគ្រូបង្រៀនឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

### ៣.៤.៣ ការបកស្រាយទិន្នន័យ

ទិន្នន័យលើកម្រងសំណួរសម្រាប់អ្នកពាក់ព័ន្ធនានាដូចជា៖ ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ ថ្នាក់ដឹកនាំការិយាល័យមធ្យមសិក្សាចំណេះទូទៅ ថ្នាក់ដឹកនាំការិយាល័យបុគ្គលិក ថ្នាក់ដឹកនាំការិយាល័យអធិការកិច្ច នាយក/នាយិកា នាយករង/នាយិការង និងលោកគ្រូ អ្នកគ្រូ ត្រូវបានវិភាគរួមគ្នាតែម្តង ហើយយើងក៏ធ្វើការបែងចែកការវិភាគផងដែរទៅតាមស្រុក/ក្រុងដែលអនុវិទ្យាល័យនីមួយៗស្ថិតនៅ ដើម្បីឆ្លុះបញ្ចាំងលក្ខណៈដោយឡែករបស់តំបន់នីមួយៗលើចំណុចមួយចំនួន ព្រមទាំងធ្វើការវិភាគ និងវាយតម្លៃសម្រាប់កម្រិតខេត្តទាំងមូល។

### ៣.៤.៤ ការវិភាគទិន្នន័យលើកម្រងសំណួរជាព័ត៌មានផ្ទាល់ខ្លួន

ការសិក្សាស្រាវជ្រាវនេះ យើងបានបែងចែកទៅតាមភេទ តួនាទី បទពិសោធន៍ និងតំបន់របស់អ្នកចូលរួម ដែលមានន័យថាអ្នកចូលរួមទាំងអស់ ជាក្រុមគោលដៅ ហើយត្រូវទៅតាមលក្ខខណ្ឌកំណត់នៅក្នុងគម្រូជ្រើសរើសដូចជា៖ នាយក/នាយិកា និងនាយករង/នាយិការង និងលោកគ្រូ-អ្នកគ្រូដែលបង្រៀននៅតាមអនុវិទ្យាល័យគោលដៅទាំងអស់ នឹងត្រូវជ្រើសរើសជាគម្រូសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។ ដូច្នេះការវិភាគនេះផ្តោតលើភាគរយនៃផលធៀបភេទ តួនាទី បទពិសោធន៍ និងតំបន់របស់អ្នកចូលរួម។ ជាលទ្ធផលយើងទទួលបានអ្នកចូលរួមសរុបចំនួន១៧០នាក់ដែលរួមមាន ថ្នាក់ដឹកនាំមន្ទីរ ចំនួន០៣នាក់ ថ្នាក់ដឹកនាំការិយាល័យមធ្យមសិក្សាចំណេះទូទៅចំនួន០៣នាក់ ថ្នាក់ដឹកនាំការិយាល័យបុគ្គលិកចំនួន០៣នាក់ ថ្នាក់ដឹកនាំការិយាល័យអធិការកិច្ចចំនួន០៣នាក់ និង នាយក នាយករង/នាយិកា នាយិការងចំនួន២៣នាក់ និងលោកគ្រូ-អ្នកគ្រូចំនួន១៣៥នាក់។ កម្រងសំណួរទាំងអស់ត្រូវបានរៀបចំតាម Google forms ហើយចែកជូនដល់អ្នកពាក់ព័ន្ធតាមក្រុមតេឡេក្រាមនៃអនុវិទ្យាល័យគោលដៅចំនួន១៦ក្នុងចំណោមអនុវិទ្យាល័យទាំង៧១នៅទូទាំងខេត្តកំពង់ស្ពឺ។

ដូច្នេះ ចំនួនសំណាកនៅតាមស្រុក/ក្រុងគោលដៅនីមួយៗដែលបង្ហាញនៅក្នុងក្រាហ្វិកខាងក្រោម គឺ តំណាងតំបន់ទីប្រជុំជន និងតំបន់ជនបទនៃអនុវិទ្យាល័យទាំងដប់ប្រាំមួយក្នុងក្រុង/ស្រុកទាំងប្រាំបី និងចំនួនបុគ្គលិកអប់រំនៅតាមស្រុក/ក្រុងនីមួយៗ ព្រមទាំងផ្អែកតាមចំនួនសំណាកដែលអ្នកចូលរួមបានប្រគល់ត្រឡប់មកវិញ។

## ៣.៥ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

ដើម្បីរក្សាក្រមសីលធម៌ក្នុងការសិក្សាស្រាវជ្រាវ យើងបានធ្វើការណែនាំខ្លួន និងប្រាប់ពីគោលបំណង រយៈពេលសុំសម្ភាសន៍ ការសន្យាលើលក្ខខណ្ឌមួយចំនួនដូចជា រក្សាការសម្ងាត់ជូនគាត់ ព័ត៌មានដែលទទួលបានមិនត្រូវបានយកទៅប្រើប្រាស់ ក្នុងគោលបំណងផ្សេងទៀតឡើយ ហើយសម្រាប់ការសម្ភាសត្រូវបានសុំការអនុញ្ញាត និងមានការឯកភាពពីអ្នកត្រូវសម្ភាសន៍ផងដែរ។ ក្នុងដំណើរការសម្ភាសគឺបានជ្រើសរើសកន្លែងដែលមានសេវាអ៊ិនធឺនែត និងមិនមានការរំខានពីមជ្ឈដ្ឋានខាងក្រៅ។ អ្នកសម្ភាសន៍បានភ្ជាប់ទំនាក់ទំនងជានិច្ចតាមប្រព័ន្ធតេលេក្រាមដើម្បីសម្របសម្រួលរាល់បញ្ហាទាំងឡាយដូចជាការបញ្ជូនតំណទៅកាន់អ្នកចូលរួមផ្សេងទៀត ការចូលទៅកាន់កម្រងសំណួរតាមរយៈតំណដែលបានផ្តល់ជូន និងបង្ហាញនូវភាពស្និទ្ធស្នាល ដោយតបជាប្រចាំនៅពេលដែលអ្នកចូលរួមបំពេញកម្រងសំណួរមានចម្ងល់ណាមួយ ជាពិសេសអ្នកសិក្សាស្រាវជ្រាវមិនធ្វើការផ្តល់យោបល់ ឬអនុសាសន៍ផ្សេងៗដល់អ្នកត្រូវសម្ភាសន៍ជាដាច់ខាត។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

# ជំពូក៤៖ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

ក្នុងជំពូកទី៤នេះ យើងនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយ និងពិភាក្សានូវអ្វីដែលត្រូវបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ និងការសម្ភាសលើក្រុមគោលដៅដែលពាក់ព័ន្ធ រួមមាន ថ្នាក់ដឹកនាំមន្ទីរ ថ្នាក់ដឹកនាំការិយាល័យមធ្យមសិក្សាចំណេះទូទៅ ការិយាល័យបុគ្គលិក ការិល័យអធិការកិច្ច គណៈគ្រប់គ្រងសាលា និងលោកគ្រូ-អ្នកគ្រូ។ រាល់ចំណុចសំខាន់ៗមួយចំនួនដែលទាក់ទងក្នុងការបំពេញភារកិច្ចរបស់លោកគ្រូ-អ្នកគ្រូផ្អែកតាមស្តង់វិជ្ជាជីវៈគ្រូបង្រៀន និងទស្សនៈអំពីការបង្កើតយុទ្ធសាស្ត្រដើម្បីជំរុញគ្រូបង្រៀនឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ត្រូវបានលើកយកមកបកស្រាយ។

## ៤.១ ការយល់ដឹងអំពីម៉ោងពេលបំពេញភារកិច្ចប្រចាំសប្តាហ៍របស់គ្រូបង្រៀន

### ៤.១.១ ចំនួនម៉ោងបំពេញភារកិច្ចប្រចាំសប្តាហ៍



រូបភាពទី៤.១.១ ម៉ោងបំពេញភារកិច្ចប្រចាំសប្តាហ៍របស់គ្រូបង្រៀន

យោងតាមរូបភាព៤.១.១.១ ម៉ោងបំពេញភារកិច្ចប្រចាំសប្ដាហ៍របស់គ្រូបង្រៀន បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺ គ្រូបង្រៀនចំនួន៣៧នាក់ស្មើនឹង២៧.៤% បានឆ្លើយថា១៦ម៉ោង គ្រូបង្រៀនចំនួន៧៨នាក់ស្មើនឹង៥៧.៨%បានឆ្លើយថា១៨ម៉ោង គ្រូបង្រៀនចំនួន១៤នាក់ ស្មើនឹង១០.៤%បានឆ្លើយថា២០ម៉ោង គ្រូបង្រៀនចំនួន៦នាក់ស្មើនឹង៤.៤% បានឆ្លើយថា៤០ម៉ោង។ តាមរយៈទិន្នន័យនៅក្នុងរូប៤.១.១.១ គ្រូបង្រៀនត្រឹមតែ៤.៤%ប៉ុណ្ណោះដែលបានដឹងអំពីចំនួនម៉ោងដែលបំពេញភារកិច្ចប្រចាំសប្ដាហ៍តាមនិយាមកំណត់។ ដោយឡែកគ្រូបង្រៀនរហូតដល់ទៅ៩៥.៦%មិនបានដឹងប្រាកដអំពីចំនួនម៉ោងបំពេញភារកិច្ចប្រចាំសប្ដាហ៍តាមនិយាមកំណត់នោះទេ ដោយយល់ច្រឡំម៉ោងបំពេញភារកិច្ចប្រចាំសប្ដាហ៍ជាមួយម៉ោងបង្រៀនប្រចាំសប្ដាហ៍ បើយោងនិយាមម៉ោងបំពេញភារកិច្ចរបស់មន្ត្រីរាជការស៊ីវិលគ្រប់ប្រភេទគឺសែសិបម៉ោងក្នុងមួយសប្ដាហ៍។

### ៤.១.២ ចំនួនម៉ោងបង្រៀនក្នុងថ្នាក់

រូបភាពទី៤.១.២ ចំនួនម៉ោងបង្រៀនក្នុងថ្នាក់



យោងតាមរូបភាព៤.១.១.២ ម៉ោងបង្រៀនប្រចាំសប្តាហ៍សម្រាប់គ្រូបង្រៀននៅអនុវិទ្យាល័យ បានបង្ហាញថា ក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន៥៦នាក់ស្មើនឹង៤១.៥%បានឆ្លើយថា១៦ម៉ោង គ្រូបង្រៀនចំនួន៦៧នាក់ស្មើនឹង៤៩.៦% បានឆ្លើយថា១៨ម៉ោង គ្រូបង្រៀនចំនួន៧នាក់ស្មើនឹង៥%បានឆ្លើយថា២០ម៉ោង គ្រូបង្រៀនចំនួន៥នាក់ស្មើនឹង៣.៧%បានឆ្លើយថា២២ម៉ោង។ តាមរយៈលទ្ធផលនេះមានន័យថា គ្រូបង្រៀន៤៩.៦%បានយល់ច្បាស់អំពីចំនួនម៉ោងបង្រៀនប្រចាំសប្តាហ៍តាមនិយាមកំណត់ ហើយគ្រូបង្រៀនដល់ទៅ៥០.៤%ដែលជាអ្នកចូលរួមឆ្លើយ មិនបានយល់ច្បាស់អំពីចំនួនម៉ោងបង្រៀនតាមនិយាមកំណត់ ដោយនិយាមម៉ោងបង្រៀនប្រចាំសប្តហ៍នៅអនុវិទ្យាល័យគឺដប់ប្រាំបី(១៨)ម៉ោងក្នុងមួយសប្តាហ៍។

## ៤.១.៣ ចំនួនម៉ោងគាំទ្រការបង្រៀន

រូបភាព៤.១.៣ ចំនួនម៉ោងគាំទ្រការបង្រៀន




យោងតាមរូបភាព៤.១.៣ ម៉ោងគាំទ្រការបង្រៀនប្រចាំសប្តាហ៍ បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០%គឺគ្រូបង្រៀនចំនួន៥៨នាក់ស្មើនឹង៤៣% បានឆ្លើយថា១៦ម៉ោង គ្រូបង្រៀនចំនួន៦២នាក់ស្មើនឹង៤៥.៩%បានឆ្លើយថា១៨ម៉ោង គ្រូបង្រៀនចំនួន៨នាក់ស្មើនឹង៥.៩%បានឆ្លើយថា២០ម៉ោង គ្រូបង្រៀនចំនួន៧នាក់ស្មើនឹង៥.២%បានឆ្លើយថា ២២ម៉ោង។ តាមរយៈលទ្ធផលនេះមានន័យថា គ្រូបង្រៀនត្រឹមតែ៤%ប៉ុណ្ណោះបានយល់ច្បាស់អំពីចំនួនម៉ោងតាម

និយាមកំណត់ដែលត្រូវបំពេញភារកិច្ចដើម្បីគាំទ្រដល់ការបង្រៀន។ គ្រូបង្រៀនរហូតដល់ទៅ៩៦%មិនបានយល់ដឹងអំពីចំនួនម៉ោងត្រូវបំពេញភារកិច្ចដើម្បីគាំទ្រដល់ការបង្រៀនប្រចាំសប្តាហ៍។ យោងតាមនិយាមដែលកំណត់ចំនួនម៉ោង គឺគ្រូបង្រៀននៅអនុវិទ្យាល័យត្រូវបំពេញភារកិច្ច២២ម៉ោងក្នុងមួយសប្តាហ៍នៅក្នុងម៉ោងគាំទ្រការបង្រៀន។ នេះមានន័យថាគ្រូបង្រៀនរហូតដល់ទៅ៩៦%មិនបានធ្វើការត្រឹមត្រូវនៅក្នុងម៉ោងគាំទ្រដល់ការបង្រៀននោះទេ គឺពួកគាត់គ្រាន់តែបំពេញភារកិច្ចទៅតាមម៉ោងដែលត្រូវឡើងបង្រៀននៅក្នុងថ្នាក់តែប៉ុណ្ណោះ។

### ៤.១.៤ ចំនួនម៉ោងធ្វើការជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់




យោងតាមរូបភាព៤.១.៤ ម៉ោងធ្វើការជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់ប្រចាំសប្តាហ៍ បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០%គឺគ្រូបង្រៀនចំនួន៣៦នាក់ស្មើនឹង២៦.៧%បានឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៦៨នាក់ស្មើនឹង៥០.៤%បានឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១៤នាក់ស្មើនឹង១០.៤%បានឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១៧នាក់ស្មើនឹង១២.៦%បានឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈទិន្នន័យក្នុងរូបភាព៤.១.៤មានន័យថាគ្រូបង្រៀនចំនួន២៦.៧% បានយល់ដឹងអំពីម៉ោងដែលត្រូវធ្វើការជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់។ បើផ្អែកតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍ គឺ

គ្រូបង្រៀនត្រូវធ្វើការចំនួនមួយម៉ោងក្នុងមួយសប្តាហ៍ជាមួយសិស្សក្រៅពីម៉ោងបង្រៀននៅក្នុងថ្នាក់ នេះមានន័យថាគ្រូបង្រៀន៧៣.៣%ដែលមិនដឹងអំពីម៉ោងដែលត្រូវធ្វើការក្រៅថ្នាក់ជាមួយសិស្ស។

### ៤.១.៥ ចំនួនម៉ោងកែកិច្ចការសិស្ស



រូបភាព៤.១.៥ ចំនួនម៉ោងដែលត្រូវកែកិច្ចការសិស្ស

យោងតាមរូបភាព៤.១.៥៖ម៉ោងដើម្បីកែកិច្ចការសិស្សប្រចាំសប្តាហ៍ បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០%គឺគ្រូបង្រៀនចំនួន៤៣នាក់ស្មើនឹ៣១.៩% បានឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៣៩នាក់ស្មើនឹង២៥.២%បានឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៣៨នាក់ស្មើនឹង២៨.១%បានឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២០នាក់ស្មើនឹង១៤.៨%បានឆ្លើយថា៥ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀន៣១.៩% បានយល់ដឹងអពីចំនួនម៉ោងដើម្បីកែកិច្ចការសិស្ស។ យោងតាមនិយាមម៉ោងបំពេញភារកិច្ចរបស់គ្រូបង្រៀនប្រចាំសប្តាហ៍គឺគ្រូបង្រៀននៅអនុវិទ្យាល័យត្រូវចំណាយពេលពីរម៉ោងក្នុងមួយសប្តាហ៍ដើម្បីកែកិច្ចការសិស្ស នេះមានន័យថាគ្រូបង្រៀន៦៨.១%មិនទាន់យល់ច្បាស់អំពីចំនួនម៉ោងដែលពួកគាត់ត្រូវកែកិច្ចការសិស្សប្រចាំសប្តាហ៍។

### ៤.១.៦ ចំនួនម៉ោងរៀបចំកិច្ចតែងការបង្រៀន



រូបភាព៤.១.៦ ចំនួនម៉ោងសរសេកិច្ចតែងការបង្រៀន

យោងតាមរូបភាព៤.១.៣ ម៉ោងរៀបចំកិច្ចតែងការបង្រៀនប្រចាំសប្តាហ៍ បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០%គឺគ្រូបង្រៀនចំនួន២៦នាក់ស្មើនឹង១៩.៣%បានឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៤៨នាក់ស្មើនឹង៣៥.៦%បានឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៤០នាក់ស្មើនឹង២៩.៦%បានឆ្លើយថា៦ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២១នាក់ស្មើនឹង១៥.៦%បានឆ្លើយថា៨ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនត្រឹម២៩.៦%បានយល់ច្បាស់អំពីចំនួនម៉ោងដែលត្រូវសរសេរកិច្ចតែងការបង្រៀន យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើប្រាំមួយម៉ោងក្នុងមួយសប្តាហ៍ដើម្បីសរសេរកិច្ចតែងការបង្រៀន។

## ៤.១.៧ ចំនួនម៉ោងកសាងសំណួរតេស្ត




យោងតាមរូបភាព៤.១.៣ ម៉ោងកសាងសំណួរតេស្តប្រចាំសប្តាហ៍ បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០%គឺគ្រូបង្រៀនចំនួន២៦នាក់ស្មើនឹង១៩.៣%បានឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៦១នាក់ស្មើនឹង៤៥.២%បានឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២៨នាក់ស្មើនឹង២០.៧%បានឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២០នាក់ស្មើនឹង១៤.៨%បានឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈទិន្នន័យក្នុងរូបភាព៤.១.៣ មានន័យថាគ្រូបង្រៀន៤៥.២%បានយល់ច្បាស់អំពីចំនួនម៉ោងត្រូវកសាងសំណួរតេស្តប្រចាំសប្តាហ៍ ហើយ គ្រូបង្រៀនចំនួន៥៤.៨%មិនយល់ដឹងច្បាស់អំពីចំនួនម៉ោងដែលត្រូវកសាងសំណួរតេស្តនោះទេ។

### ៤.១.៨ ចំនួនម៉ោងស្រាវជ្រាវបន្ថែមលើមុខវិជ្ជាឯកទេស




យោងតាមរូបភាព៤.១.៨ ម៉ោងស្រាវជ្រាវឯកទេសរបស់ខ្លួន បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០%គឺគ្រូបង្រៀនចំនួន២០នាក់ស្មើនឹង១៤.៨%ឆ្លើយថា១ម៉ោងក្នុងមួយសប្ដាហ៍ គ្រូបង្រៀនចំនួន៦២នាក់ស្មើនឹង៤៥.៩%ឆ្លើយថា២ម៉ោងក្នុងមួយសប្ដាហ៍ គ្រូបង្រៀនចំនួន២៤នាក់ស្មើនឹង១៧.៨%ឆ្លើយថា៣ម៉ោងក្នុងមួយសប្ដាហ៍ គ្រូបង្រៀនចំនួន២៩នាក់ស្មើនឹង២១.៥%ឆ្លើយថា៤ម៉ោងក្នុងមួយសប្ដាហ៍។ តាមរយៈទិន្នន័យនេះមានន័យថាគ្រូបង្រៀន៤៥.៩%យល់ដឹងច្បាស់អំពីចំនួនម៉ោងដែលពួកគាត់ត្រូវស្រាវជ្រាវបន្ថែមលើមុខវិជ្ជាឯកទេសរបស់ខ្លួន។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្ដាហ៍គឺគ្រូបង្រៀនត្រូវប្រើពីរម៉ោងក្នុងមួយសប្ដាហ៍ដើម្បីស្រាវជ្រាវបន្ថែមលើមុខវិជ្ជាឯកទេសរបស់ខ្លួន នេះមានន័យថាគ្រូបង្រៀ៥៤.១%មិនបានយល់ច្បាស់អំពីចំនួនម៉ោងប្រចាំសប្ដាហ៍ដែលត្រូវស្រាវជ្រាវបន្ថែមលើមុខវិជ្ជាឯកទេសរបស់ខ្លួននោះទេ។

### ៤.១.៩ ចំនួនម៉ោងផលិតសម្ភារឧបទេស



យោងតាមរូបភាព៤.១.៩ ម៉ោងផលិតសម្ភារឧបទេស បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០%គឺគ្រូបង្រៀនចំនួន៣៦នាក់ស្មើនឹង២៦.៧%បានឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៥៧នាក់ស្មើនឹង៤២.២%បានឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២៨នាក់ស្មើនឹង២០.៧%បានឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១៤នាក់ស្មើនឹង១០.៤%បានឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈទិន្នន័យក្នុងរូបភាព៤.១.៩ មានន័យថាគ្រូបង្រៀន៤២.២%បានយល់ច្បាស់អំពីចំនួនម៉ោងប្រចាំសប្តាហ៍ដែលត្រូវផលិតសម្ភារឧបទេស។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើពីរម៉ោងក្នុងមួយសប្តាហ៍ដើម្បីផលិតសម្ភារឧបទេស នេះមានន័យថាគ្រូ៥៧.៨%មិនបានយល់ច្បាស់អំពីចំនួនម៉ោងដែលត្រូវផលិតសម្ភារឧបទេស។

### ៤.១.១០ ចំនួនម៉ោងប្រជុំបច្ចេកទេស




យោងតាមរូបភាព៤.១.១០ ចំនួនម៉ោងប្រជុំបច្ចេកទេស បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០%គឺគ្រូបង្រៀនចំនួន៥៦នាក់ស្មើនឹង៤១.៥%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៤៦នាក់ស្មើនឹង៣៤.១%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១២នាក់ស្មើនឹង៨.៩%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២១នាក់ស្មើនឹង១៥.៦%បានឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈទិន្នន័យក្នុងរូបភាព៤.១.១០ មានន័យថាគ្រូបង្រៀន៤១.៥%បានយល់ច្បាស់អំពីចំនួនម៉ោងប្រចាំសប្តាហ៍ដែលត្រូវចូលរួមប្រជុំបច្ចេកទេស។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើមួយម៉ោងក្នុងមួយសប្តាហ៍ឬបួនម៉ោងក្នុងមួយខែដើម្បីចូលរួមប្រជុំបច្ចេកទេស នេះមានន័យថាគ្រូ៥៨.៥%មិនបានយល់ច្បាស់អំពីចំនួនម៉ោងដែលចូលរួមប្រជុំបច្ចេកទេស។

### ៤.១.១១ ចំនួនម៉ោងបូក ស្រង់ពិន្ទុសិស្ស




យោងតាមរូបភាព៤.១.១១ ចំនួនម៉ោងបូកស្រង់ពិន្ទុសិស្ស បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៩នាក់ស្មើនឹង១០០%គឺគ្រូបង្រៀនចំនួន១៦នាក់ស្មើនឹង១១.៩%ឆ្លើយថា១ម៉ោងក្នុងមួយសប្ដាហ៍ គ្រូបង្រៀនចំនួន៦០នាក់ស្មើនឹង៤៤.៤%ឆ្លើយថា២ម៉ោងក្នុងមួយសប្ដាហ៍ គ្រូបង្រៀនចំនួន២៦នាក់ស្មើនឹង១៩.៣%ឆ្លើយថា៣ម៉ោងក្នុងមួយសប្ដាហ៍ គ្រូបង្រៀនចំនួន៣៣នាក់ស្មើនឹង២៤.៤%បានឆ្លើយថា៤ម៉ោងក្នុងមួយសប្ដាហ៍។ តាមរយៈទិន្នន័យក្នុងរូបភាព៤.១.១១ មានន័យថាគ្រូបង្រៀន៤៤.៤%បានយល់ច្បាស់អំពីចំនួនម៉ោងប្រចាំសប្ដាហ៍ដែលត្រូវបូកស្រង់ពិន្ទុសិស្ស។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្ដាហ៍គឺគ្រូបង្រៀនត្រូវប្រើពីរម៉ោងក្នុងមួយសប្ដាហ៍ ដើម្បីបូកស្រង់ពិន្ទុសិស្ស នេះមានន័យថាគ្រូ៥៥.៦%មិនបានយល់ច្បាស់អំពីចំនួនម៉ោងដែលត្រូវបូកស្រង់ពិន្ទុសិស្ស។

### ៤.១.១២ ចំនួនម៉ោងរៀបចំរដ្ឋបាលថ្នាក់ ឯកសារ និងកំណត់ត្រាផ្សេងៗ



យោងតាមរូបភាព៤.១.១២ ចំនួនម៉ោងរៀបចំរដ្ឋបាលថ្នាក់ ឯកសារ និងកំណត់ត្រាផ្សេងៗ បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន៤៣នាក់ ស្មើនឹង៣១.៩%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៥៧នាក់ស្មើនឹង៤២.២%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១៨នាក់ស្មើនឹង១៣.៣%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១៧នាក់ស្មើនឹង១២.៦%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈទិន្នន័យក្នុងរូបភាព៤.១.១២ មានន័យថាគ្រូបង្រៀន៣១.៩%បានយល់ច្បាស់អំពីចំនួនម៉ោងប្រចាំសប្តាហ៍ដែលត្រូវរៀបចំរដ្ឋបាលថ្នាក់ ឯកសារ និងកំណត់ត្រាផ្សេងៗ។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើមួយម៉ោងក្នុងមួយសប្តាហ៍ ដើម្បីរៀបចំរដ្ឋបាលថ្នាក់ ឯកសារ និងកំណត់ត្រាផ្សេងៗ នេះមានន័យថាគ្រូ៦៨.១%មិនបានយល់ច្បាស់អំពីចំនួនម៉ោងដែលត្រូវរៀបចំរដ្ឋបាលថ្នាក់។

### ៤.១.១៣ ចំនួនម៉ោងចូលរួមសកម្មភាពក្រៅថ្នាក់ និងសង្គម




យោងតាមរូបភាព៤.១.១៣ ចំនួនម៉ោងចូលរួមសកម្មភាពក្រៅថ្នាក់និងសង្គម បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន៥៥នាក់ស្មើនឹង៤០.៧%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៥៩នាក់ស្មើនឹង៤៣.៧%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១៧នាក់ស្មើនឹង១២.៦%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៤នាក់ស្មើនឹង៣%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈទិន្នន័យក្នុងរូបភាព៤.១.១៣ មានន័យថាគ្រូបង្រៀន៤០.៧%បានយល់ច្បាស់អំពីចំនួនម៉ោងប្រចាំសប្តាហ៍ដែលត្រូវចូលរួមសកម្មភាពក្រៅថ្នាក់ និង

សង្គម។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើមួយម៉ោងក្នុងមួយសប្តាហ៍ ដើម្បីចូលរួមសកម្មភាពក្រៅថ្នាក់ និងសង្គម នេះមានន័យថាគ្រូ៥៩.៣%មិនបានយល់ច្បាស់អំពីចំនួនម៉ោងដែលត្រូវចូលរួមសកម្មភាពក្រៅថ្នាក់ និងសង្គម។

### ៤.១.១៤ ចំនួនម៉ោងទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស

ក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺត្រូវបានបង្ហាញទិន្នន័យនៅក្នុងរូបភាព៤.២.២ អំពីម៉ោងទំនាក់ទំនងជាមួយអាណាព្យាបាលសិស្សដូចតទៅៈ




គ្រូបង្រៀនចំនួន៧៩នាក់ស្មើនឹង៥៨.៥%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៣៦នាក់ស្មើនឹង២៦.៧%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១២នាក់ស្មើនឹង៨.៩%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនឆ្លើយចំនួន៨នាក់ស្មើនឹង៥.៩%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈទិន្នន័យនេះ មានន័យថាគ្រូបង្រៀន៥៨.៥%បានយល់ច្បាស់អំពីចំនួនម៉ោងប្រចាំសប្តាហ៍ដែលត្រូវទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើមួយម៉ោងក្នុងមួយសប្តាហ៍ ដើម្បីទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស នេះមានន័យថាគ្រូ៤១.៥%មិនបានយល់ច្បាស់អំពីចំនួនម៉ោងដែលត្រូវទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស។

**សន្និដ្ឋានរួម** ឆាគរយគ្រូបង្រៀនដែលបំពេញភារកិច្ចត្រឹមត្រូវតាមចំនួនម៉ោងដែលនិយាមកំណត់

តាមរយៈទិន្នន័យលម្អិតខាងលើនេះយើងអាចសន្និដ្ឋានជារួមបានថា គ្រូបង្រៀន(បុគ្គលិកបង្រៀន) យ៉ាងច្រើនលើសលប់មិនបានយល់ដឹងអំពីម៉ោងពេលបំពេញភារកិច្ចរបស់ខ្លួន គឺពួកគាត់ផ្តោតទៅលើតែម៉ោង

ដែលត្រូវឡើងបង្រៀននៅក្នុងថ្នាក់របស់ខ្លួនតែប៉ុណ្ណោះ នេះអាចមានន័យថាពួកគាត់គ្រាន់តែទៅបង្រៀនអោយគ្រប់១៨ម៉ោងក្នុងមួយសប្តាហ៍។ លទ្ធផលនេះក៏បង្ហាញអោយឃើញផងដែរថាគ្រូបង្រៀនមិនបានបំពេញភារកិច្ចរបស់ខ្លួនស្របតាមក្រមសីលធម៌វិជ្ជាជីវៈនោះឡើយដោយពួកគាត់មិនបំពេញការងាររបស់ខ្លួនអោយគ្រប់តាមម៉ោងដែលច្បាប់បានកំណត់នោះឡើយ នេះគឺជាមូលហេតុដែលធ្វើអោយគុណភាពអប់រំកម្ពុជាបច្ចុប្បន្នបានធ្លាក់ចុះបើធៀបទៅនឹងប្រទេសផ្សេងទៀតទាំងនៅក្នុងតំបន់ និងសាកលលោក។

## ៤.២ ការអនុវត្តជាក់ស្តែងនៃម៉ោងពេលបំពេញការងារប្រចាំសប្តាហ៍

### ៤.២.១ ចំនួនម៉ោងបំពេញភារកិច្ចប្រចាំសប្តាហ៍




យោងតាមរូបភាព៤.២.១ ចំនួនម៉ោងបំពេញភារកិច្ចប្រចាំសប្តាហ៍របស់គ្រូបង្រៀន បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន៥២នាក់ស្មើនឹង៣៨.៥% ឆ្លើយថា១៦ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៦៣នាក់ស្មើនឹង៤៦.៧%ឆ្លើយថា១៨ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៨នាក់ស្មើនឹង៦%ឆ្លើយថា២០ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១២នាក់ស្មើនឹង៩%ឆ្លើយថា៤០ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈទិន្នន័យក្នុងរូបភាព ៤.២.១ មានន័យថាគ្រូបង្រៀន៩%ប៉ុណ្ណោះដែលបានបំពេញភារកិច្ចត្រឹមត្រូវតាមនិយាម។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវធ្វើការ៤០ម៉ោងក្នុងមួយសប្តាហ៍នេះមានន័យថាគ្រូបង្រៀនរហូតដល់ទៅ៩១% មិនបានបំពេញភារកិច្ចគ្រប់ចំនួនម៉ោងដែលនិយាមបានកំណត់នោះឡើយ។

## ៤.២.២ ចំនួនម៉ោងឡើងបង្រៀនក្នុងថ្នាក់




រូបភាព៤.២.២ ចំនួនម៉ោងដែលត្រូវឡើងបង្រៀន

យោងតាមរូបភាព៤.២.២ អំពីម៉ោងឡើងបង្រៀនក្នុងថ្នាក់ប្រចាំសប្តាហ៍របស់លោកគ្រូ-អ្នកគ្រូ បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន ៤៤ នាក់ស្មើនឹង៣២.៦%បានបង្រៀនចន្លោះពី១២ម៉ោងទៅ១៤ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួ៨០ នាក់ស្មើនឹង៥៩%បានបង្រៀនចន្លោះពី១៥ទៅ១៨ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៤នាក់ស្មើនឹង ៣%បានបង្រៀនចន្លោះពី១៩ទៅ២២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៧នាក់ ស្មើនឹង៥%បានបង្រៀនលើស២២ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈទិន្នន័យក្នុងរូបភាព៤.២.២ មានន័យថាគ្រូបង្រៀន ៥៩% បានប្រើប្រាស់ម៉ោងបង្រៀនត្រឹមត្រូវតាមនិយាម។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវឡើងបង្រៀនក្នុងថ្នាក់ចំនួន១៨ម៉ោងក្នុងមួយសប្តាហ៍ បើគ្រូបង្រៀនទទួលបន្ទុកថ្នាក់គឺត្រូវឡើងបង្រៀនក្នុងថ្នាក់១៤ម៉ោងក្នុងមួយសប្តាហ៍ បើគ្រូបង្រៀនមានតួនាទីជាប្រធានក្រុមបច្ចេកទេសគឺត្រូវឡើងបង្រៀនក្នុងថ្នាក់១៦ម៉ោងក្នុងមួយសប្តាហ៍ នេះមានន័យថាគ្រូបង្រៀនចំនួន ៣២.៦% មិនបានបង្រៀនគ្រប់ចំនួនម៉ោងដែលនិយាមបានកំណត់នោះឡើយ ហើយគ្រូបង្រៀនចំនួន ៨%បានបង្រៀនលើសម៉ោងដែលនិយាមបានកំណត់។

## ៤.២.៣ ចំនួនម៉ោងគាំទ្រការបង្រៀន

ក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺត្រូវបានបង្ហាញទិន្នន័យនៅក្នុងរូបភាព៤.២.៣ អំពីការបំពេញភារកិច្ចក្នុងម៉ោងគាំទ្រការបង្រៀន ដូចតទៅនេះ៖



រូបភាព៤.២.៣ ការបំពេញភារកិច្ចក្នុងម៉ោងគាំទ្រការបង្រៀន

គ្រូបង្រៀនចំនួន៥៦នាក់ស្មើនឹង៤១.៥%ឆ្លើយថា១៦ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៣៣នាក់ស្មើនឹង២៤.៤%ឆ្លើយថា១៨ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៣៤នាក់ស្មើនឹង២៥.១%ឆ្លើយថា២០ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២នាក់ ស្មើនឹង១%ឆ្លើយថា២២ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថា គ្រូបង្រៀនតែ១%ប៉ុណ្ណោះដែលបានបំពេញភារកិច្ចត្រឹមត្រូវទៅតាមចំនួនម៉ោងដែលនិយាមកំណត់នៅក្នុងម៉ោងគាំទ្រការបង្រៀន។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវធ្វើការក្នុងម៉ោងគាំទ្រការបង្រៀនចំនួន២២ម៉ោងក្នុងមួយសប្តាហ៍ នេះមានន័យថាគ្រូបង្រៀន ស្ទើរតែទាំងអស់(រហូតដល់ទៅ៩៩% ) មិនបានបំពេញភារកិច្ចក្នុងម៉ោងគាំទ្រដល់ការបង្រៀនប្រចាំសប្តាហ៍គ្រប់ទៅតាមនិយាមដែលបានកំណត់នោះឡើយ។

### ៤.២.៤ ចំនួនម៉ោងធ្វើការជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់



រូបភាព៤.២.៤ ចំនួនម៉ោងធ្វើការជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់

យោងតាមរូបភាព៤.២.៤ ចំនួនម៉ោងធ្វើការជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់ បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន៣នាក់ស្មើនឹង២.២%មិនធ្លាប់ធ្វើការជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់ គ្រូបង្រៀនចំនួន៦៦នាក់ស្មើនឹង៤៨.៩%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៥០នាក់ស្មើនឹង៣៧%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៧នាក់ស្មើនឹង៥.២%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៩នាក់ស្មើនឹង៦.៧%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន៤៨.៩%បានធ្វើការជាមួយសិស្សក្រៅម៉ោងបង្រៀនក្នុងថ្នាក់ត្រឹមត្រូវទៅតាមចំនួនម៉ោងដែលនិយាមកំណត់។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវធ្វើការជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់ចំនួន០១ម៉ោងក្នុងមួយសប្តាហ៍ នេះមានន័យថាគ្រូបង្រៀនចំនួន៤៨.៩%មិនបានធ្វើការជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់បានត្រឹមត្រូវទៅតាមនិយាមដែលបានកំណត់នោះឡើយ ហើយគ្រូបង្រៀនចំនួន២.២%មិនដែលបានធ្វើជាមួយសិស្សក្រៅពីការបង្រៀនក្នុងថ្នាក់ទាល់តែសោះ។

### ៤.២.៥ ចំនួនម៉ោងកែកិច្ចការសិស្ស

រូបភាព៤.២.៥ ចំនួនម៉ោងដែលត្រូវកែកិច្ចការសិស្ស




យោងតាមរូបភាព៤.២.៥ ចំនួនម៉ោងដើម្បីកែកិច្ចការសិស្ស បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន៧៣នាក់ស្មើនឹង៥៤%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៣០នាក់ស្មើនឹង២២.២%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២១នាក់ស្មើនឹង១៥.៦%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១១នាក់ស្មើនឹង៨.២%ឆ្លើយថា៥ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន២២.២%បានចំណាយបីម៉ោងក្នុងមួយសប្តាហ៍ដើម្បីកែកិច្ចការសិស្សគឺត្រឹមត្រូវទៅតាមចំនួនម៉ោងដែលនិយាមបានកំណត់។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើរយៈពេលបី

ម៉ោងក្នុងមួយសប្តាហ៍ដើម្បីកែកិច្ចការសិស្ស  នេះមានន័យថាគ្រូបង្រៀនចំនួន៧៧.៨%មិនបានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវប្រចាំសប្តាហ៍ដើម្បីកែកិច្ចការសិស្សទៅតាមនិយាមដែលបានកំណត់នោះឡើយ។

### ៤.២.៦ ចំនួនម៉ោងរៀបចំកិច្ចតែងការបង្រៀន



រូបភាព៤.២.៦ ចំនួនម៉ោងសរសេរកិច្ចតែងការបង្រៀន

យោងតាមរូបភាព៤.២.៦ ចំនួនម៉ោងរៀបចំកិច្ចតែងការបង្រៀន បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន៥៤នាក់ស្មើនឹង៤០%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៤៩នាក់ស្មើនឹង៣៦.៣%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២១នាក់ស្មើនឹង១៥.៦%ឆ្លើយថា៦ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១១នាក់ស្មើនឹង៨.១%ឆ្លើយថា៨ម៉ោងក្នុងមួយសប្តាហ៍។ នេះមានន័យថាគ្រូបង្រៀនត្រឹមតែ១៥.៦%បានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវតាមនិយាមកំណត់ដើម្បីសរសេរកិច្ចតែងការបង្រៀន។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើរយៈពេលប្រាំមួយម៉ោងក្នុងមួយសប្តាហ៍ដើម្បីរៀបចំកិច្ចតែងការបង្រៀន នេះមានន័យថាគ្រូបង្រៀនចំនួន៨៤.៤%មិនបានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវប្រចាំសប្តាហ៍ដើម្បីរៀបចំកិច្ចតែងការបង្រៀនទៅតាមនិយាមដែលបានកំណត់នោះឡើយ។

### ៤.២.៧ ចំនួនម៉ោងកសាងសំណួរតេស្ត

ក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺត្រូវបានបង្ហាញទិន្នន័យនៅក្នុងរូបភាព៤.២.៧ អំពីចំនួនម៉ោងកសាងសំណួរតេស្ត ដូចតទៅនេះ៖



រូបភាព៤.២.៧ ចំនួនម៉ោងកសាងសំណួរតេស្ត

គ្រូបង្រៀនចំនួន៤៧នាក់ស្មើនឹង៣៤.៨%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៥៧នាក់ស្មើនឹង៤២.២%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២១នាក់ស្មើនឹង១៥.៦%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១០នាក់ស្មើនឹង៧.៤%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថា គ្រូបង្រៀនចំនួន៤២.២%បានប្រើប្រាស់ពេលវេលាត្រឹមត្រូវតាមនិយាមដើម្បីកសាងសំណួរតេស្ត។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើរយៈពេលពីរម៉ោងក្នុងមួយសប្តាហ៍ដើម្បីកសាងសំណួរតេស្ត នេះមានន័យថាគ្រូបង្រៀនចំនួន៥៧.៨%មិនបានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវតាមនិយាមកំណត់ដើម្បីកសាងសំណួរតេស្តនោះឡើយ។

### ៤.២.៨ ចំនួនម៉ោងស្រាវជ្រាវបន្ថែមលើមុខវិជ្ជាឯកទេស



រូបភាព៤.២.៨ ចំនួនម៉ោងស្រាវជ្រាវ

យោងតាមរូបភាព៤.២.៨ ចំនួនម៉ោងស្រាវជ្រាវបន្ថែមលើមុខវិជ្ជាឯកទេស បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន៣២នាក់ស្មើនឹង២៣.៧%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៥៧នាក់ស្មើនឹង៤២.២%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២០នាក់ស្មើនឹង១៤.៨%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២៦នាក់ស្មើនឹង១៩.៣%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន៤២.២%បានប្រើប្រាស់រយៈពេលត្រឹមត្រូវតាមនិយាមកំណត់ ដើម្បីស្រាវ ជ្រាវបន្ថែមលើមុខវិជ្ជាឯកទេសរបស់ខ្លួន។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើរយៈពេលពីរម៉ោងក្នុងមួយសប្តាហ៍ដើម្បីកស្រាវជ្រាវបន្ថែមលើមុខវិជ្ជាឯកទេស នេះមានន័យថាគ្រូបង្រៀនចំនួន៥៧.៨%មិនបានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវតាមនិយាមកំណត់ដើម្បីស្រាវជ្រាវបន្ថែមលើមុខវិជ្ជាឯកទេសនោះឡើយ។

### ៤.២.៩ ចំនួនម៉ោងផលិតសម្ភារឧបទេស




យោងតាមរូបភាព៤.២.៩ ចំនួនម៉ោងផលិតសម្ភារឧបទេស បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន០១នាក់ស្មើនឹង0.៧%ឆ្លើយថាសូន្យម៉ោង គ្រូបង្រៀនចំនួន៤៤នាក់ស្មើនឹង៣២.៦%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៦០

នាក់ស្មើនឹង៤៤.៤%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១៨នាក់ស្មើនឹង១៣.៣%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១២នាក់ស្មើនឹង៨.៩%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន៤៤.៤%បានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវទៅតាមនិយាមកំណត់។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើរយៈពេលពីរម៉ោងក្នុងមួយសប្តាហ៍ដើម្បីផលិតសម្ភារឧបទេស នេះមានន័យថាគ្រូបង្រៀនចំនួន៥៤.៩%មិនបានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវតាមនិយាមកំណត់ដើម្បីផលិតសម្ភារឧបទេសនោះឡើយ ហើយគ្រូបង្រៀនចំនួន០.៧%មិនដែលបានចំណាយពេលផលិតសម្ភារឧបទេសទាល់តែសោះ។

### ៤.២.១០ ចំនួនម៉ោងប្រជុំបច្ចេកទេស




យោងតាមរូបភាព៤.២.១០ ចំនួនម៉ោងចូលរួមប្រជុំបច្ចេកទេស បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន៥៥នាក់ស្មើនឹង៤០.៧%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ ឬ៤ម៉ោងក្នុងមួយខែ គ្រូបង្រៀនចំនួន៥០នាក់ស្មើនឹង៣៧%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១១នាក់ស្មើនឹង៨.១%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១៩នាក់ស្មើនឹង១៤.១%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនជាង៤០.៧%បានចូលរួមប្រជុំបច្ចេកទេសទៀងទាត់រៀងរាល់ខែ។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើរយៈពេលមួយម៉ោងក្នុងមួយសប្តាហ៍ ឬបួនម៉ោងក្នុងមួយខែដើម្បីចូលរួមប្រជុំបច្ចេកទេស នេះមានន័យថាគ្រូបង្រៀនចំនួន៦១.៣%មិនបានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវតាមនិយាមកំណត់ដើម្បីចូលរួមប្រជុំបច្ចេកទេសនោះទេ ឬអាចមានន័យថាពួកគាត់មិនបានចូលរួមប្រជុំបច្ចេកឱ្យបានទៀងទាត់នោះទេ។

## ៤.២.១១ ចំនួនម៉ោងបូក ស្រង់ពិន្ទុសិស្ស




យោងតាមរូបភាព៤.២.១១ ចំនួនម៉ោងបូកស្រង់ពិន្ទុសិស្ស បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន១៨នាក់ស្មើនឹង១៣.៣%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៦៧នាក់ស្មើនឹង៤៩.៦%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២០នាក់ស្មើនឹង១៤.៨%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៣០នាក់ស្មើនឹង២២.២%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈទិន្នន័យនេះមានន័យថាគ្រូបង្រៀន៤៩.៦បានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវតាមនិយាមកំណត់ដើម្បីបូកស្រង់ពិន្ទុសិស្ស។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើរយៈពេលពីរម៉ោងក្នុងមួយសប្តាហ៍ ដើម្បីបូកស្រង់ពិន្ទុសិស្ស នេះមានន័យថាគ្រូបង្រៀនចំនួន៥០.៤%មិនបានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវតាមនិយាមកំណត់ដើម្បីបូកស្រង់ពិន្ទុសិស្សនោះទេ។

## ៤.២.១២ ម៉ោងរៀបចំរដ្ឋបាលថ្នាក់ ឯកសារ និងកំណត់ត្រាផ្សេងៗ



យោងតាមរូបភាព៤.២.១១ ចំនួនម៉ោងរៀបចំរដ្ឋបាលថ្នាក់ ឯកសារ និងកំណត់ត្រាផ្សេងៗ បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន៤៤នាក់ស្មើនឹង៣២.៦%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៤៨នាក់ស្មើនឹង៣៥.៦%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន២៦នាក់ស្មើនឹង១៩.៣%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១៧នាក់ស្មើនឹង១២.៦%បានឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន៣២.៦%បានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវតាមនិយាមកំណត់ ដើម្បីរៀបចំរដ្ឋបាលថ្នាក់ ឯកសារ និងកំណត់ត្រាផ្សេងៗ។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍គឺគ្រូបង្រៀនត្រូវប្រើរយៈពេលមួយម៉ោងក្នុងមួយសប្តាហ៍ដើម្បីរៀបចំរដ្ឋបាលថ្នាក់ ឯកសារ និងកំណត់ត្រាផ្សេងៗ នេះមានន័យថាគ្រូបង្រៀនចំនួន៦៧.៤%មិនបានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវតាមនិយាមកំណត់ដើម្បីរៀបចំរដ្ឋបាលថ្នាក់ ឯកសារ និងកំណត់ត្រាផ្សេងៗនោះទេ។

### ៤.២.១៣ ចំនួនម៉ោងចូលរួមសកម្មភាពក្រៅថ្នាក់ និងសង្គម




យោងតាមរូបភាព៤.២.១៣ ចំនួនម៉ោងចូលរួមសកម្មភាពក្រៅថ្នាក់ និងសង្គម បានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន៤នាក់ស្មើនឹង៣%ឆ្លើយថាសូន្យម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៦៥នាក់ស្មើនឹង៤៨.១%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៤៥នាក់ស្មើនឹង៣៣.៣%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន១៥នាក់ស្មើនឹង១១.១%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៦នាក់ស្មើនឹង៤.៤%ឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន៤៨.១%បានចំណាយពេលត្រឹមត្រូវតាមនិយាមកំណត់ដើម្បីចូលរួមសកម្មភាពក្រៅថ្នាក់ និងសង្គម។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍ គឺគ្រូបង្រៀនត្រូវប្រើរយៈពេលមួយម៉ោងក្នុងមួយសប្តាហ៍ដើម្បីចូលរួម

សកម្មភាពក្រៅថ្នាក់ និងសង្គម នេះមានន័យថាគ្រូបង្រៀនចំនួន៤៨.៩%មិនបានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវតាមនិយាមកំណត់ដើម្បីចូលរួមសកម្មភាពក្រៅថ្នាក់ និងសង្គមនោះទេ ហើយគ្រូបង្រៀនចំនួន៣%មិនបានចំណាយពេលចូលរួមសកម្មភាពក្រៅថ្នាក់ និងសង្គមទាល់តែសោះ។

### ៤.២.១៤ ចំនួនម៉ោងទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស




យោងតាមរូបភាព៤.២.១៤ ចំនួនម៉ោងទំនាក់ទំនងជាមួយអាណាព្យាបាលសិស្សបានបង្ហាញថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% គឺគ្រូបង្រៀនចំនួន១០នាក់ស្មើនឹង៧.៤%ឆ្លើយថាសូន្យក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៧៥នាក់ស្មើនឹង៥៥.៦%ឆ្លើយថា១ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៣៨នាក់ស្មើនឹង២៨.១%ឆ្លើយថា២ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៩នាក់ស្មើនឹង៦.៧%ឆ្លើយថា៣ម៉ោងក្នុងមួយសប្តាហ៍ គ្រូបង្រៀនចំនួន៣នាក់ស្មើនឹង២.២%បានឆ្លើយថា៤ម៉ោងក្នុងមួយសប្តាហ៍។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀន៥៥.៦%បានចំណាយពេលត្រឹមត្រូវតាមនិយាមកំណត់ដើម្បីទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស។ យោងតាមនិយាមនៃការប្រើប្រាស់ម៉ោងធ្វើការប្រចាំសប្តាហ៍ គឺគ្រូបង្រៀនត្រូវប្រើរយៈពេលមួយម៉ោងក្នុងមួយសប្តាហ៍ដើម្បីទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស នេះមានន័យថាគ្រូបង្រៀនចំនួន៣៧%មិនបានប្រើប្រាស់ចំនួនម៉ោងត្រឹមត្រូវតាមនិយាមកំណត់ដើម្បីទំនាក់ទំនងជាមួយអាណាព្យាបាលសិស្សនោះទេ ហើយគ្រូបង្រៀនចំនួន៧.៤%មិនដែលបានចំណាយពេលទំនាក់ទំនងជាមួយអាណាព្យាបាលសិស្សឡើយ។

**សន្និដ្ឋានរួម៖** ភាគរយគ្រូបង្រៀនដែលបំពេញភារកិច្ចត្រឹមត្រូវតាមចំនួនម៉ោងដែលនិយាមកំណត់តាមរយៈទិន្នន័យលម្អិតខាងលើនេះយើងអាចសន្និដ្ឋានជារួមបានថា គ្រូបង្រៀន(បុគ្គលិកបង្រៀន) យ៉ាងច្រើនលើសលប់បានប្រើប្រាស់ម៉ោងពេលបំពេញភារកិច្ចរបស់ខ្លួន ទៅលើម៉ោងដែលត្រូវឡើងបង្រៀននៅក្នុងថ្នាក់តែប៉ុណ្ណោះសម្រាប់ម៉ោងពេលដែលត្រូវបំពេញភារកិច្ចនៅក្នុងម៉ោងគាំទ្រគឺពួកគាត់មិនសូវយកចិត្ត

ទុកដាក់បំពេញការងារឡើយ។ លទ្ធផលនេះក៏បង្ហាញអោយឃើញផងដែរថាគ្រូបង្រៀនភាគច្រើនមិនបានបំពេញភារកិច្ចរបស់ខ្លួនស្របតាមក្រមសីលធម៌វិជ្ជាជីវៈនោះឡើយដោយសារពួកគាត់បំពេញការងារតាមច្បាប់កំណត់នៅមានកម្រិត។ កត្តានេះក៏អាចជាមូលហេតុមួយដែលនាំឱ្យគុណភាពអប់រំនៅកម្ពុជាបច្ចុប្បន្នបានធ្លាក់ចុះបើធៀបទៅនឹងប្រទេសផ្សេងទៀតទាំងក្នុងតំបន់ និងសាកលលោក។

## ៤. ៣ ការបំពេញភារកិច្ចតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

### ៤.៣.១ ចំណេះដឹងវិជ្ជាជីវៈ

តារាង៤.៣.១ តារាងភាគរយនៃកម្រិតយល់ដឹងអំពី«ចំណេះដឹងវិជ្ជាជីវៈ»

| បំណិនទី១៖ចំណេះដឹងវិជ្ជាជីវៈ | កម្រិតនៃការយល់ដឹង(គិតជាភាគរយ) | | | |
|---|---|---|---|---|
| | ដឹងច្បាស់ | ដឹង | ដឹងតិចតួច | មិនដឹង |
| ការស្គាល់សិស្ស | 20.7% | 54.8% | 23.7% | 0.7% |
| ការដឹងប្រភេទគ្រួសារសិស្ស | 24.4% | 54.1% | 20.7% | 0.7% |
| ការយល់ដឹងគោលនយោបាយអប់រំ | 4.4% | 37.8% | 36.3% | 21.5% |
| ការយល់ដឹងទ្រឹស្តីសរសេរកិច្ចតែងការបង្រៀន | 10.4% | 60% | 17.8% | 11.9% |
| ការយល់ដឹងក្របខណ្ឌកម្មវិធីសិក្សា | 6.7% | 61.5% | 30.4% | 1.5% |

#### ក. ការស្គាល់សិស្ស

យោងតាមតារាង៤.៣.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមអ្នកចូលរួមឆ្លើយចំនួន១៣៥នាក់ ស្មើនឹង ១០០% បានផ្តល់ចម្លើយអំពីការស្គាល់សិស្សដូចតទៅ៖ គ្រូបង្រៀន២៨នាក់ ស្មើនឹង២០.៧%បានស្គាល់ស្ថានភាពសិស្សយ៉ាងច្បាស់លាស់ គ្រូបង្រៀនចំនួន៧៤នាក់ ស្មើនឹង៥៤.៨%បានស្គាល់ស្ថានភាពសិស្សក្នុងកម្រិតធម្មតា គ្រូបង្រៀន៣២នាក់ ស្មើនឹង២៣.៧%ស្គាល់ស្ថានភាពសិស្សបានតិចតួច គ្រូបង្រៀន០១នាក់ ស្មើនឹង០.៧%មិនបានស្គាល់ស្ថានភាពសិស្សទាល់តែសោះ។ តាមរយៈលទ្ធផលនេះ មានន័យថា គ្រូបង្រៀនចំនួន៧៥.៥%បានស្គាល់ស្ថានភាពសិស្សដែលធ្វើឱ្យការបង្រៀនរបស់ពួកគាត់ស្របទៅតាមតម្រូវការរបស់សិស្ស។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ត្រង់ចំណុចទី១ ការស្គាល់សិស្សគឺស្គាល់ពីតម្រូវការសិក្សា សមត្ថភាពសិក្សា ប្រវត្តិសិក្សា និងឥរិយាបថសិក្សារបស់សិស្ស មានន័យថាគ្រូបង្រៀនចំនួន២៤.៥%មិនបានស្គាល់ស្ថានភាពសិស្សច្បាស់លាស់នោះទេ ដែលធ្វើឱ្យការបង្រៀនរបស់ពួកគាត់មិនអាចឆ្លើយតបទៅតាមតម្រូវការរបស់សិស្ស។

## ខ.ការយល់ដឹងច្បាស់ពីប្រភេទគ្រួសារសិស្ស និងកត្តាផ្សេងៗ

យោងតាមតារាង៤.៣.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការដឹងអំពីប្រភេទគ្រួសារសិស្សដូចតទៅៈ គ្រូបង្រៀន៣៣នាក់ស្មើនឹង២៤.៤%ឆ្លើយថាដឹងយ៉ាងច្បាស់លាស់ពីប្រភេទគ្រួសារសិស្ស គ្រូបង្រៀន៧៣នាក់ស្មើនឹង៥៤.១%ឆ្លើយថាដឹងពីប្រភេទគ្រួសារសិស្សក្នុងកម្រិតធម្មតា គ្រូបង្រៀន២៨នាក់ស្មើនឹង២០.៧%ឆ្លើយថាដឹងពីប្រភេទគ្រួសារសិស្សបានតិចតួច គ្រូបង្រៀន០១នាក់ស្មើនឹង០.៧%ឆ្លើយថាមិនបានដឹងពីប្រភេទគ្រួសារសិស្ស និងកត្តាផ្សេងៗទៀតរបស់សិស្សទាល់តែសោះ។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន៧៨.៥%បានយល់ដឹងអំពីប្រភេទគ្រួសារសិស្ស និងកត្តាផ្សេងៗទៀតដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស ធ្វើឱ្យពួកគាត់អាចសម្របសម្រួលការបង្រៀនទៅតាមស្ថានភាពរបស់សិស្សនិងមិនធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍សិស្សក្នុងពេលកំពុងរៀនសូត្រ។ យោងតាមស្តង់វិជ្ជាជីវៈគ្រូបង្រៀន ការដឹងពីប្រភេទគ្រួសារ និងកត្តាផ្សេងៗរបស់សិស្សគឺសំដៅទៅលើការស្គាល់ពី យេនឌ័រ សាវតារសង្គម សេដ្ឋកិច្ច ក្រុមជនជាតិ និងពិការភាពដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស ព្រមទាំងយល់ដឹងពីរបៀបដោះស្រាយបញ្ហាទាំងនោះ។ នេះមានន័យថាគ្រូបង្រៀន២១.៥%មិនបានយល់ដឹងច្បាស់អំពីប្រភេទគ្រួសារសិស្សឡើយ។ កត្តានេះធ្វើឱ្យការបង្រៀនរបស់ពួកគាត់មិនអាចបត់បែនទៅតាមស្ថានភាពរបស់សិស្ស ឬអាចធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍សិស្សនៅពេលពួកគេកំពុងសិក្សាដែលជំរុញសិស្សឱ្យបាក់ទឹកចិត្តចំពោះការសិក្សា។

## គ.ការយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ

យោងតាមតារាង៤.៣.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅដូចតទៅៈគ្រូបង្រៀន៦នាក់ស្មើនឹង៤.៤%ឆ្លើយថាដឹងច្បាស់លាស់ គ្រូបង្រៀន៥១នាក់ស្មើនឹង៣៧.៨%ឆ្លើយថាយល់ដឹងក្នុងកម្រិតធម្មតា គ្រូបង្រៀន៤៩នាក់ស្មើនឹង៣៦.៣%ឆ្លើយថាយល់ដឹងក្នុងកម្រិតតិចតួច គ្រូបង្រៀន២៩នាក់ស្មើនឹង២១.៥%មិនបានយល់ដឹងទាល់តែសោះ។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន៤២.២%បានយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ ដែលធ្វើឱ្យពួកគាត់អនុវត្តការបង្រៀនរបស់ខ្លួនស្របតាមស្តង់ដារបស់ជាតិ។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ការយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅគឺមានគោលបំណងធ្វើឱ្យការបង្រៀនសម្រេចលទ្ធផលស្របទៅនឹងស្តង់ដាកំណត់របស់ជាតិ។ មានន័យថាគ្រូបង្រៀន៥៧.៨%មិនបានធ្វើឱ្យការបង្រៀនរបស់ខ្លួនសម្រេចលទ្ធផលស្របតាមស្តង់ដាកំណត់របស់ជាតិបានពេញលេញនោះទេ។

## ឃ. ការយល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀន

យោងតាមរូបភាព៤.៣.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការយល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀនដូចតទៅៈ គ្រូបង្រៀន១៤នាក់ស្មើនឹង១០.៤%ឆ្លើយថាដឹងយ៉ាងច្បាស់លាស់ គ្រូបង្រៀន៨១នាក់ស្មើនឹង៦០%ឆ្លើយថាយល់ដឹងក្នុងកម្រិតធម្មតា គ្រូបង្រៀន២៤នាក់ស្មើនឹង១៧.៨%ឆ្លើយថាយល់ដឹងក្នុងកម្រិតតិចតួច គ្រូបង្រៀន១៦នាក់ស្មើនឹង១១.៩%ឆ្លើយថាមិនបានយល់ដឹងទាល់សោះ។ នេះមានន័យថាគ្រូបង្រៀន៧០.៤% បានយល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀនដែលជាភារកិច្ចស្នូលនៅក្នុងអាជីពជាគ្រូបង្រៀន។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ការយល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀនគឺផ្តោតសំខាន់ទៅលើ ការកំណត់វត្ថុបំណងមេរៀន ចំណុចសំខាន់នៃការប្រើប្រាស់វិធីសាស្ត្របង្រៀន យុទ្ធសាស្ត្រវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានសមស្រប ការប្រើប្រាស់សម្ភារបង្រៀន និងរៀនស្របតាមខ្លឹមសារមេរៀន។ នេះមានន័យថា គ្រូបង្រៀនរហូតដល់ទៅ២៩.៦%យល់ដឹងបានតិចតួច និងមិនបានយល់ដឹងទាល់តែសោះពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀន គ្រូបង្រៀននៅក្នុងក្រុមនេះប្រហែលជាមិនដែលរៀបចំកិច្ចតែងការបង្រៀនទាល់តែសោះ គឺពួកគាត់មិនយកចិត្តទុកដាក់ចំពោះការងារជាគ្រូបង្រៀនដោយពួកគាត់គ្រាន់តែមកបង្រៀនឱ្យតែគ្រប់ម៉ោងរបស់ខ្លួនប៉ុណ្ណោះ។

## ង. ការយល់ដឹងពីក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងផែនការបង្រៀន

យោងតាមតារាង៤.៣.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនដែលចូលរួមឆ្លើយចំនួន១៣៥នាក់ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការយល់ដឹងពីក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងផែនការបង្រៀនដូចតទៅៈ គ្រូបង្រៀន៩នាក់ស្មើនឹង៦.៧%ឆ្លើយថាដឹងយ៉ាងច្បាស់លាស់ គ្រូបង្រៀន៨៣នាក់ស្មើនឹង៦១.៥%ឆ្លើយថាយល់ដឹងក្នុងកម្រិតធម្មតា គ្រូបង្រៀន៤១នាក់ ស្មើនឹង៣០.៤%ឆ្លើយថាយល់ដឹងក្នុងកម្រិតតិចតួច គ្រូបង្រៀន២នាក់ ស្មើនឹង១.៥%ឆ្លើយថាមិនបានយល់ដឹង។ នេះមានន័យថាគ្រូបង្រៀនប្រហែល៦៨%យល់ដឹងពីក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងផែនការបង្រៀនដែលធ្វើឱ្យការបង្រៀនរបស់ពួកគាត់អាចប្រព្រឹត្តទៅបានស្របតាមកម្មវិធីសិក្សា។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ការយល់ដឹងពីក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងផែនការបង្រៀន គឺផ្តោតសំខាន់ទៅលើសមត្ថភាពនៃការធ្វើបំណែងកម្មវិធីសិក្សាលម្អិតប្រចាំឆ្នាំ និងការរៀបចំផែនការបង្រៀនដើម្បីធានាឱ្យការបង្រៀនមានដំណើរការទាន់កម្មវិធីសិក្សារបស់ក្រសួង។ មានន័យថាគ្រូបង្រៀន៣២%បានបង្រៀនសិស្សដោយគ្មានផែនការច្បាស់លាស់។

### ៤.៣.២ ការប្រតិបត្តិវិជ្ជាជីវៈ

តារាង៤.៣.២៖ តារាងភាគរយនៃ«ការប្រតិបត្តិវិជ្ជាជីវៈ»

| បំណិនទី២៖ការប្រតិបត្តិវិជ្ជាជីវៈ | កម្រិតនៃការប្រតិបត្តិ(គិតជាភាគរយ) | | | |
|---|---|---|---|---|
| | ជាប្រចាំ | ញឹកញាប់ | ម្តងម្កាល | មិនដែល |
| រៀបចំកិច្ចតែងការបង្រៀន | 7.4% | 68.9% | 23.7% | 00% |
| រៀបចំសម្ភារៈបង្រៀន | 11.9% | 65.9% | 22.2% | 0.0% |
| ប្រើប្រាស់វិធីសាស្ត្រចម្រុះដើម្បីវាយតម្លៃសិស្ស | 13.3% | 64.4% | 21.5% | 0.7% |
| ផ្តល់បរិស្ថានសិក្សាមានសុវត្ថិភាពដល់សិស្ស | 22.2% | 65.9% | 11.9% | 0.0% |
| ជួយបង្កើនការសិក្សារបស់សិស្ស | 34.8% | 58.5% | 60.7% | 0.0% |
| ប្រើប្រាស់វិធីសាស្ត្របង្រៀនសម្បូរបែប | 19.3% | 65.2% | 15.5% | 0.0% |
| ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដើម្បីជួយការបង្រៀន | 13.3% | 57.8% | 26.7% | 2.2% |

#### ក. ការរៀបចំកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានត្រឹមត្រូវ និងមានប្រសិទ្ធភាព

យោងតាមតារាង៤.៣.២ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយដូចតទៅ៖ គ្រូបង្រៀន១០នាក់ ស្មើនឹង៧.៤%ឆ្លើយថាបានរៀបចំត្រឹមត្រូវ គ្រូបង្រៀន៩៣នាក់ ស្មើនឹង៦៨.៩%ឆ្លើយថាបានរៀបចំក្នុងកម្រិតធម្មតា គ្រូបង្រៀន៣២នាក់ ស្មើនឹង២៣.៧%ឆ្លើយថាបានរៀបចំតិចតួច។ នេះមានន័យថាគ្រូបង្រៀនជាង៧៦% បានរៀបចំកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។ យោងតាមស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ការរៀបចំកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានត្រឹមត្រូវ និងមានប្រសិទ្ធភាព គឺសំដៅដល់ការរៀបចំកិច្ចតែងការបង្រៀនដែលមានការកំណត់វត្ថុបំណងមេរៀនបានច្បាស់លាស់ របៀបវាយតម្លៃលទ្ធផលសិក្សារបស់សិស្សច្បាស់លាស់ សកម្មភាពគ្រូ សិស្ស និងខ្លឹមសារមេរៀនដើម្បីគាំទ្រវត្ថុបំណងមេរៀនបានច្បាស់លាស់និងត្រឹមត្រូវតាមគោលការណ៍។ នេះមានន័យថាគ្រូបង្រៀន២៣.៧%មិនទាន់បានរៀបចំកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានត្រឹមត្រូវ និងមានប្រសិទ្ធភាពនៅឡើយទេ ហើយវាអាចមានន័យថាគ្រូបង្រៀននៅក្នុងប្រភេទនេះមិនសូវយកចិត្តទុកដាក់ចំពោះភារកិច្ចរបស់ខ្លួន។

### ខ.ការរៀបចំសម្ភារបង្រៀន និងរៀនដើម្បីឱ្យការសិក្សាសម្រេចបានលទ្ធផលល្អ

យោងតាមតារាង៤.៣.២ អ្នកស្រាវជ្រាវបានដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន ១៣៥នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយដូចតទៅនេះ៖ គ្រូបង្រៀន១៦នាក់ ស្មើនឹង១១.៩%ឆ្លើយថាបានរៀបចំជាប្រចាំ គ្រូបង្រៀន៨៩នាក់ ស្មើនឹង៦៥.៩%ឆ្លើយថាបានរៀបចំក្នុងកម្រិតធម្មតា គ្រូបង្រៀន៣០នាក់ ស្មើនឹង២២.២%ឆ្លើយថាបានរៀបចំម្តងម្កាល។ នេះមានន័យថាគ្រូបង្រៀនប្រហែល៧៨% បានរៀបចំសម្ភារបង្រៀន និងរៀនជាប្រចាំដើម្បីធ្វើឱ្យការសិក្សាសម្រេចបានលទ្ធផលល្អ។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ការរៀបចំសម្ភារបង្រៀន និងរៀនដើម្បីការសិក្សាសម្រេចបានលទ្ធផលល្អ គឺផ្តោតទៅការរៀបចំសម្ភារបង្រៀន និងសម្ភាររៀនដើម្បីធ្វើឱ្យការសិក្សារបស់សិស្សសម្រេចបានលទ្ធផលល្អ។ នេះមានន័យថាគ្រូបង្រៀន២២%មិនទាន់បានរៀបចំសម្ភារបង្រៀន និងសម្ភាររៀនបានត្រឹមត្រូវជាប្រចាំដើម្បីធ្វើឱ្យការសិក្សារបស់សិស្សសម្រេចបានលទ្ធផលល្អនៅឡើយ។

### គ. ការប្រើប្រាស់វិធីសាស្ត្រសមស្របសម្បូរបែបសម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស

យោងតាមតារាង៤.៣.២ អ្នកស្រាវជ្រាវបានដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន ១៣៥នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការប្រើប្រាស់វិធីសាស្ត្រសមស្របសម្បូរបែបសម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស គឺគ្រូបង្រៀន១៨នាក់ ស្មើនឹង១៣.៣% ឆ្លើយថាបានប្រើប្រាស់ជាប្រចាំ គ្រូបង្រៀន៨៧នាក់ ស្មើនឹង៦៤.៤% ឆ្លើយថាបានប្រើប្រាស់ក្នុងកម្រិតធម្មតា គ្រូបង្រៀន២៩នាក់ ស្មើនឹង២១.៥% ឆ្លើយថាបានប្រើប្រាស់ម្តងម្កាល គ្រូបង្រៀន០១នាក់ ស្មើនឹង០.៧% ឆ្លើយថាមិនបានប្រើប្រាស់។ នេះមានន័យថាគ្រូបង្រៀនប្រហែល៧៨%បានប្រើប្រាស់វិធីសាស្ត្រសមស្របសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប្រចាំ។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ការប្រើប្រាស់វិធីសាស្ត្រសមស្របសម្បូរបែបសម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស គឺការកសាងសំណួរតេស្តដោយទម្រង់និងរយៈពេលសមស្របសម្រាប់សិស្សឆ្លើយ ការរៀបចំអត្រាកំណែតេស្ត ការកែចម្លើយសិស្សបានត្រឹមត្រូវ និងការកំណត់បានយ៉ាងច្បាស់អំពីលទ្ធផលតេស្តដើម្បីបង្ហាញពីប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស។ នេះមានន័យថាគ្រូបង្រៀន២២%មិនបានកសាងសំណួរតេស្តដោយមានទម្រង់និងរយៈពេលសមស្រប សម្រាប់សិស្សឆ្លើយនោះទេ គឺពួកគាត់បានដាក់សំណួរ ឬលំហាត់ទៅតាមអារម្មណ៍របស់គាត់ដើម្បីឱ្យសិស្សធ្វើ និងផ្តល់ពិន្ទុដល់សិស្សទៅតាមការប៉ាន់ស្មាន។

### ឃ. ការផ្តល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាព

តាមរយៈតារាង៤.៣.២ អ្នកស្រាវជ្រាវបានដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន ១៣៥នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការប្រើប្រាស់វិធីសាស្ត្រសមស្របសម្បូរបែបសម្រាប់វាយ

តម្លៃលទ្ធផលសិក្សារបស់សិស្សដូចតទៅ៖ គ្រូបង្រៀន៣០នាក់ ស្មើនឹង២២.២% ឆ្លើយថាបានផ្ដល់ជាប្រចាំ គ្រូបង្រៀន៨៩នាក់ ស្មើនឹង៦៥.៩% ឆ្លើយថាបានផ្ដល់ក្នុងកម្រិតធម្មតា គ្រូបង្រៀន១៦នាក់ ស្មើនឹង ១១.៩% ឆ្លើយថាបានផ្ដល់ម្ដងម្កាល។ នេះមានន័យថាគ្រូបង្រៀនប្រហែល៨៨% បានផ្ដល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាព។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ការផ្ដល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាពគឺផ្ដោតទៅលើការគ្រប់គ្រងសិស្សមានប្រសិទ្ធភាព ជួយសិស្សឱ្យមានអន្តរកម្មវិជ្ជមានជាមួយសិស្សដទៃទៀត ផ្ដល់បរិស្ថានសិក្សាដែលធ្វើអោយសិស្សពង្រីកបរិស្ថានសិក្សាបានច្រើន។ មានន័យថាគ្រូបង្រៀនចំនួន ១២%មិនបានផ្ដល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាពនៅឡើយទេ។

### ង. ការជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន

តាមរយៈតារាង៤.៣.២ អ្នកស្រាវជ្រាវបានដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន ១៣៥នាក់ ស្មើនឹង១០០% បានផ្ដល់ចម្លើយអំពីការជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួនដូចតទៅ៖ គ្រូបង្រៀន៤៧នាក់ ស្មើនឹង៣៤.៨% ឆ្លើយថាបានជួយសិស្សជាប្រចាំ គ្រូបង្រៀន៧៩នាក់ ស្មើនឹង៥៨.៥% ឆ្លើយថាបានជួយ គ្រូបង្រៀន៩នាក់ ស្មើនឹង៦.៧% ឆ្លើយថាបានជួយម្ដងម្កាល។ នេះមានន័យថាគ្រូបង្រៀនជាង៩៣% បានជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួនជាប្រចាំ។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ការជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន នឹងនាំឱ្យសិស្សកាន់តែមានទំនួលខុសត្រូវលើការសិក្សាពិសេសលើការខិតខំស្វ័យសិក្សាបន្ថែមកាន់តែខ្លាំង។ នេះមានន័យថាគ្រូបង្រៀនចំនួន៧%មិនទាន់បានជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួននៅឡើយ។

### ច. ការប្រើប្រាស់វិធីបង្រៀនផ្សេងៗដើម្បីជួយការសិក្សារបស់សិស្សឱ្យសម្រេចតាមស្តង់ដាកម្មវិធីសិក្សា

តាមរយៈរូបភាព៤.៣.២បង្ហាញថាក្នុងចំណោមអ្នកចូលរួមឆ្លើយចំនួន១៣៥នាក់ ស្មើនឹង១០០% បានផ្ដល់ចម្លើយអំពីការប្រើប្រាស់ជាប្រចាំនូវវិធីបង្រៀនផ្សេងៗដើម្បីជួយសម្រួលដល់ការសិក្សារបស់សិស្សនិងសម្រេចឱ្យបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួង៖ គ្រូបង្រៀន២៦នាក់ ស្មើនឹង១៩.៣%ឆ្លើយថាបានប្រើប្រាស់ជាប្រចាំ គ្រូបង្រៀន៨៨នាក់ ស្មើនឹង៦៥.២%ឆ្លើយថាបានប្រើប្រាស់ គ្រូបង្រៀន២១នាក់ ស្មើនឹង១៥.៥% ឆ្លើយថាបានប្រើប្រាស់ម្ដងម្កាល។ នេះមានន័យថាគ្រូបង្រៀនប្រហែល៨៥% បានប្រើប្រាស់វិធីបង្រៀនផ្សេងៗដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចឱ្យបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួងជាប្រចាំ។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ការប្រើប្រាស់ជាប្រចាំនូវវិធីបង្រៀនផ្សេងៗ

ដើម្បីជួយសម្រួលដល់ការសិក្សារបស់សិស្ស និងសម្រេចឱ្យបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួងគឺសំដៅទៅលើការប្រើប្រាស់វិធីដែលមានប្រសិទ្ធភាពចំពោះមេរៀននីមួយៗជាពិសេសការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានត្រឹមត្រូវ។ ដូច្នេះគ្រូបង្រៀនចំនួន១៥%នៅតែនុវត្តវិធីសាស្ត្របង្រៀនបែបបុរាណនៅក្នុងការបង្រៀនប្រចាំថ្ងៃរបស់ខ្លួន។

### ឆ.ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីធ្វើឱ្យការបង្រៀននិងរៀនកាន់តែមានប្រសិទ្ធភាព

តាមរយៈតារាង៤.៣.២ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមអ្នកចូលរួមឆ្លើយចំនួន១៣៥នាក់ ស្មើនឹង ១០០% បានផ្តល់ចម្លើយអំពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីធ្វើឱ្យការបង្រៀននិងរៀនកាន់តែមានប្រសិទ្ធភាពដូចតទៅ៖ គ្រូបង្រៀន១៨នាក់ ស្មើនឹង១៣.៣% ឆ្លើយថាបានប្រើប្រាស់ជាប្រចាំ គ្រូបង្រៀន៧៨នាក់ ស្មើនឹង៥៧.៨%ឆ្លើយថាបានប្រើប្រាស់ គ្រូបង្រៀន៣៦នាក់ស្មើនឹង ២៦.៧% ឆ្លើយថាបានប្រើប្រាស់ម្តងម្កាល គ្រូបង្រៀន៣នាក់ ស្មើនឹង២.២%ឆ្លើយថាមិនបានប្រើប្រាស់។ ផ្អែកលើលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន៧១%បានប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីធ្វើឱ្យការបង្រៀននិងរៀនកាន់តែមានប្រសិទ្ធភាព។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន «ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីធ្វើឱ្យការបង្រៀននិងរៀនកាន់តែមានប្រសិទ្ធភាព» មានគោលបំណងជួយសិស្សឱ្យចង់រៀន និងធ្វើឱ្យសិស្សរៀនកាន់តែមានប្រសិទ្ធភាព។ នេះមានន័យថាគ្រូបង្រៀនចំនួន២៩%មិនទាន់បានជំរុញសិស្សឱ្យចង់រៀន និងរៀនកាន់តែមានប្រសិទ្ធភាពនៅឡើយទេ។

## ៤.៣.៣ ការសិក្សាវិជ្ជាជីវៈ

តារាង៤.៣.៣ តារាងភាគរយនៃកម្រិត«សិក្សាវិជ្ជាជីវៈ»

| បំណិនទី៣៖ការសិក្សាវិជ្ជាជីវៈ | កម្រិតនៃការសិក្សា(គិតជាភាគរយ) | | | |
|---|---|---|---|---|
| | ជាប្រចាំ | ញឹកញាប់ | ម្តងម្កាល | មិនដែល |
| ស្វ័យវាយតម្លៃលើការបង្រៀន | 13.3% | 60.7% | 25.9% | 0.0% |
| ការអភិវឌ្ឍចំណេះដឹងICT | 12.2% | 60% | 28.1% | 0.7% |
| ការអភិវឌ្ឍបំណិនទំនាក់ទំនង | 8.9% | 60.7% | 28.9% | 1.5% |
| ការស្រាវជ្រាវវិជ្ជាជីវៈគ្រូបង្រៀន | 11.3% | 61.5% | 20.7% | 1.5% |

| | | | | |
|---|---|---|---|---|
| អន្តរកម្មជាមួយគ្រូបង្រៀនផ្សេងទៀតដើម្បីពង្រីកចំណេះដឹង | 5.9% | 58.5% | 34.1% | 1.5% |

### ក. ស្វ័យវាយតម្លៃលើការបង្រៀនរបស់ខ្លួនដើម្បីអភិវឌ្ឍសមត្ថភាពនៃការបង្រៀន

តាមរយៈតារាង៤.៣.៣ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការវាយតម្លៃលើការបង្រៀនរបស់ខ្លួនដើម្បីអភិវឌ្ឍសមត្ថភាពនៃការបង្រៀនដូចតទៅ៖ គ្រូបង្រៀន១៨នាក់ ស្មើនឹង១៣.៣% ឆ្លើយថាបានធ្វើការវាយតម្លៃជាប្រចាំ គ្រូបង្រៀន៨២នាក់ ស្មើនឹង៦០.៧% ឆ្លើយថាបានធ្វើការវាយតម្លៃ គ្រូបង្រៀន៣៥នាក់ ស្មើនឹង២៥.៩% ឆ្លើយថាបានធ្វើការវាយតម្លៃម្តងម្កាល។ នេះមានន័យថាគ្រូបង្រៀនចំនួន៧៤% បានធ្វើការវាយតម្លៃលើការបង្រៀនរបស់ខ្លួនដើម្បីអភិវឌ្ឍសមត្ថភាពនៃការបង្រៀន។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន «ការវាយតម្លៃលើការបង្រៀនរបស់ខ្លួនដើម្បីអភិវឌ្ឍសមត្ថភាពនៃការបង្រៀន» គឺត្រូវកំណត់ចំណុចខ្លាំង ចំណុចគួរកែលម្អ និងតម្រូវការក្នុងមុខវិជ្ជាជីវៈរបស់ខ្លួន ការរៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស្វែងយល់ពីសៀវភៅកំណត់ត្រាប្រចាំថ្ងៃដើម្បីឆ្លុះបញ្ចាំងការងាររបស់ខ្លួន។ ដូចនេះគ្រូបង្រៀនចំនួន២៦%មិនទាន់បានវាយតម្លៃលើការបង្រៀនរបស់ខ្លួនដើម្បីអភិវឌ្ឍសមត្ថភាពនៃការបង្រៀននៅឡើយទេ។

### ខ. ការអភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មានវិទ្យា និងបំណិនសម្រាប់អនុវត្តក្នុងការបង្រៀន

តាមរយៈតារាង៤.៣.៣ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនចូលរួមឆ្លើយចំនួន១៣៥នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការអភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មានវិទ្យា សារគមនាគមន៍ និងបំណិនសម្រាប់អនុវត្តក្នុងការបង្រៀនដូចតទៅ៖ គ្រូបង្រៀន១៤នាក់ស្មើនឹង១០.៤% ឆ្លើយថាបានអភិវឌ្ឍជាប្រចាំ គ្រូបង្រៀន៨១នាក់ស្មើនឹង៦០% ឆ្លើយថាបានអភិវឌ្ឍ គ្រូបង្រៀន៣៨នាក់ស្មើនឹង២៨.១% ឆ្លើយថាបានអភិវឌ្ឍម្តងម្កាល គ្រូបង្រៀន០១នាក់ ស្មើនឹង០.៧% ឆ្លើយថាមិនបានអភិវឌ្ឍទាល់តែសោះ។ តាមរយៈលទ្ធផលនេះ មានន័យថាគ្រូបង្រៀនចំនួន៧១% បានអភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មានវិទ្យា សារគមនាគមន៍ និងបំណិនសម្រាប់ការអនុវត្តក្នុងការបង្រៀន។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន «ការអភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មានវិទ្យា សារគមនាគមន៍ និងបំណិនសម្រាប់អនុវត្តក្នុងការបង្រៀន» សំដៅយកការបៀបប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍សម្រាប់ស្រាវជ្រាវនិងរៀនដោយខ្លួនឯង។ គ្រូបង្រៀន២៩%មិនទាន់មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍សម្រាប់ការស្រាវជ្រាវដោយខ្លួនឯងនៅឡើយទេ។

**គ. ការអភិវឌ្ឍបំណិនទំនាក់ទំនងជាមួយមាតាបិតាសិស្ស មិត្តរួមអាជីព និងសហគមន៍**

តាមរយៈតារាង៤.៣.៣ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥ នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការអភិវឌ្ឍបំណិនទំនាក់ទំនងជាមួយមាតាបិតាសិស្ស មិត្តរួមអាជីព និងសហគមន៍ដូចតទៅ៖ គ្រូបង្រៀន១២នាក់ស្មើនឹង៨.៩% ឆ្លើយថាបានអភិវឌ្ឍជាប្រចាំ គ្រូបង្រៀន៨២នាក់ ស្មើនឹង៦០.៧% ឆ្លើយថាបានអភិវឌ្ឍ គ្រូបង្រៀន៣៩នាក់ ស្មើនឹង២៨.៩% ឆ្លើយថាបានអភិវឌ្ឍម្តងម្កាល គ្រូបង្រៀន០២នាក់ ស្មើនឹង១.៥% ឆ្លើយថាមិនបានអភិវឌ្ឍទាល់តែសោះ។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន៧០% បានអភិវឌ្ឍបំណិនទំនាក់ទំនងជាមួយមាតាបិតាសិស្ស មិត្តរួមអាជីព និងសគមន៍។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន «ការអភិវឌ្ឍបំណិនទំនាក់ទំនងជាមួយមាតាបិតាសិស្ស មិត្តរួមអាជីព និងសហគមន៍» សំដៅលើបំណិនទំនាក់ទំនងជាមួយសិស្ស សហការី និងអាណាព្យាបាលសិស្សឬសហគមន៍។ គ្រូបង្រៀនចំនួន៣០%មិនទាន់បានអភិវឌ្ឍបំណិននេះនៅឡើយទេ។

**ឃ.ការស្រាវជ្រាវបន្ថែមអំពីវិជ្ជាជីវៈគ្រូបង្រៀនដើម្បីពង្រីកចំណេះដឹងឱ្យទូលំទូលាយ**

តាមរយៈតារាង៤.៣.៣ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥ នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការស្រាវជ្រាវបន្ថែមលើវិជ្ជាជីវៈគ្រូបង្រៀនដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយ៖ គ្រូបង្រៀន២៦នាក់ ស្មើនឹង១១.៣% ឆ្លើយថាបានស្រាវជ្រាវបន្ថែមជាប្រចាំ គ្រូបង្រៀន៨៣នាក់ ស្មើនឹង៦១.៥% ឆ្លើយថាបានស្រាវជ្រាវបន្ថែម គ្រូបង្រៀន២៨នាក់ ស្មើនឹង២០.៧% ឆ្លើយថាបានស្រាវជ្រាវបន្ថែមម្តងម្កាល គ្រូបង្រៀន០២នាក់ ស្មើនឹង១.៥% ឆ្លើយថាមិនបានស្រាវជ្រាវបន្ថែម។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន៧៨% បានស្រាវជ្រាវបន្ថែមអំពីវិជ្ជាជីវៈគ្រូបង្រៀនដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យធ្វើឱ្យការបង្រៀនកាន់តែប្រសើរឡើង។ គ្រូបង្រៀនចំនួន២២%មិនបានស្រាវជ្រាវបន្ថែមអំពីវិជ្ជាជីវៈគ្រូបង្រៀនដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យធ្វើឱ្យការបង្រៀនកាន់តែប្រសើរឡើងនៅឡើយទេ គឺពួកគាត់បង្រៀនទៅតាមចំណេះដឹងរបស់ខ្លួនដែលមានពីមុនមកតែប៉ុណ្ណោះ។

**ង. ការធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈ**

តាមរយៈតារាង៤.៣.៣ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥ នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈដូចតទៅ៖ គ្រូបង្រៀន០៨នាក់ ស្មើនឹង៥.៩%ឆ្លើយថាបានធ្វើអន្តរកម្មជាប្រចាំ គ្រូបង្រៀន៧៩នាក់ ស្មើនឹង៥៨.៥% ឆ្លើយថាបានធ្វើអន្តរកម្ម គ្រូបង្រៀន៤៦នាក់ ស្មើនឹង៣៤.១% ឆ្លើយថាបានធ្វើអន្តរកម្មម្តង

ម្តាល គ្រូបង្រៀន០២នាក់ ស្មើនឹង១.៥% ឆ្លើយថាមិនបានធ្វើអន្តរកម្ម។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនប្រហែល៦៤% បានធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈដើម្បីអឱ្យការបង្រៀនកាន់តែប្រសើរឡើង។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន «ការធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈ» គឺជាការផ្លាស់ប្តូរបទពិសោធន៍ល្អៗអំពីការបង្រៀន និងរៀនតាមរយៈការចូលរួមប្រជុំ ឬចូលរួមសិក្ខាសាលា។ នេះមានន័យថាគ្រូបង្រៀនចំនួន៣៦%មិនបានធ្វើអន្តរកម្មជាមួយគ្រូបង្រៀនដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈនោះទេ។

### ៤.៣.៤ សីលធម៌វិជ្ជាជីវៈ

តារាង៤.៣.៤ តារាងភាគរយនៃកម្រិត«សិក្សាវិជ្ជាជីវៈ»

| បំណិនទី៣៖សីលធម៌វិជ្ជាជីវៈ | កម្រិតនៃការប្រតិបត្តិ(គិតជាភាគរយ) | | | |
|---|---|---|---|---|
| | ជាប្រចាំ | ញឹកញាប់ |ម្តងម្កាល | មិនដែល |
| ការយកចិត្តទុកដាក់ចំពោះប្រយោជន៍សិស្សជាធំ | 33.3% | 59.3% | 7.4% | 0.0% |
| ការចូលរួមចំណែកក្នុងវិជ្ជាជីវៈដោយទទួលខុសត្រូវ | 29.6% | 62.2% | 8.2% | 0.0% |
| អាកប្បកិរិយាវិជ្ជមានជាគំរូចំពោះសិស្ស/សហគមន៍ | 34.8% | 60% | 5.2% | 0.0% |
| ប្រកាន់យុត្តិធម៌ តម្លាភាពជាមួយសិស្ស | 34.8% | 58.5% | 6.7% | 0.0% |

### ក. ការបង្ហាញពីការយកចិត្តទុកដាក់ចំពោះប្រយោជន៍សិស្សជាធំ

តាមរយៈតារាង៣.៣.៤ អ្នកស្រាវជ្រាវដឹងថា ក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពី «ការបង្ហាញពីការយកចិត្តទុកដាក់ចំពោះប្រយោជន៍សិស្សជាធំ»ដូចតទៅ៖ គ្រូបង្រៀន៤៥នាក់ ស្មើនឹង៣៣.៣% ឆ្លើយថាបានបង្ហាញជាប្រចាំ គ្រូបង្រៀន៨០នាក់ ស្មើនឹង៥៩.៣% ឆ្លើយថាបានបង្ហាញ គ្រូបង្រៀន១០នាក់ ស្មើនឹង៧.៤% ឆ្លើយថាបានបង្ហាញម្តងម្កាល។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនប្រហែល៩៣% បានបង្ហាញពីការយកចិត្តទុកដាក់ចំពោះប្រយោជន៍សិស្សជាធំ។ គ្រូបង្រៀនចំនួន០៧%មិនសូវបង្ហាញពីការយកចិត្តទុកដាក់ចំពោះប្រយោជន៍សិស្សជាធំ។

### ខ. ការបង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈប្រកបដោយស្មារតីទទួលខុសត្រូវ

តាមរយៈតារាង៤.៣.៤ អ្នកស្រាវជ្រាវដឹងថា ក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការបង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូ

បង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចតទៅៈ គ្រូបង្រៀន៤០នាក់ ស្មើនឹង២៩.៦% ឆ្លើយថាបានបង្ហាញជាប្រចាំ គ្រូបង្រៀន៨៤នាក់ ស្មើនឹង៦២.២% ឆ្លើយថាបានបង្ហាញ គ្រូបង្រៀន១១នាក់ ស្មើនឹង៨.១% ឆ្លើយថាបានបង្ហាញម្តងម្កាល។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនប្រហែល៩២% បានបង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់នៅពេលពួកគាត់បង្រៀនសិស្ស។ គ្រូបង្រៀនចំនួន០៨%បានបង្ហាញម្តងម្កាលពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់នៅពេលពួកគាត់បង្រៀនសិស្ស។

### គ. ការបង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ជាមួយសិស្ស និងសហគមន៍

តាមរយៈតារាង៤.៣.៤ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនដែលចូលរួមឆ្លើយចំនួន១៣៥នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការបង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ និងមានទំនាក់ទំនងដោយសុខុដុមជាមួយសិស្ស និងសហគមន៍ដូចតទៅៈ គ្រូបង្រៀន៤៧នាក់ ស្មើនឹង៣៤.៨% ឆ្លើយថាបានបង្ហាញជាប្រចាំ គ្រូបង្រៀន៨១នាក់ ស្មើនឹង៦០%ឆ្លើយថាបានបង្ហាញ គ្រូបង្រៀន០៧នាក់ ស្មើនឹង៥.២%ឆ្លើយថាបានបង្ហាញម្តងម្កាល។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនចំនួន៩៥% បានបង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ និងមានទំនាក់ទំនងដោយសុខុដុមជាមួយសិស្ស និងសហគមន៍។ គ្រូបង្រៀនចំនួន០៥%បានបង្ហាញម្តងម្កាលអំពីអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ និងមានទំនាក់ទំនងដោយសុខុដុមជាមួយសិស្ស និងសហគមន៍។

### ឃ. ការប្រើប្រាស់ភាពយុត្តិធម៌ តម្លាភាពជាមួយសិស្ស និងសហសេវិក

តាមរយៈតារាង ៤.៣.៤ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមឆ្លើយចំនួន១៣៥នាក់ ស្មើនឹង១០០% បានផ្តល់ចម្លើយអំពីការបង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ និងមានទំនាក់ទំនងដោយសុខុដុមជាមួយសិស្ស និងសហគមន៍ដូចតទៅៈ គ្រូបង្រៀន៤៧នាក់ ស្មើនឹង៣៤.៨%ឆ្លើយថាបានប្រើប្រាស់ជាប្រចាំ គ្រូបង្រៀន៧៩នាក់ ស្មើនឹង៥៨.៥%ឆ្លើយថាបានប្រើប្រាស់ គ្រូបង្រៀន០៩នាក់ស្មើនឹង៦.៧%ឆ្លើយថាបានប្រើប្រាស់ម្តងម្កាល។ តាមរយៈលទ្ធផលនេះមានន័យថាគ្រូបង្រៀនប្រហែល៩៣% បានប្រើប្រាស់ភាពយុត្តិធម៌ និងតម្លាភាពក្នុងការប្រព្រឹត្តជាមួយសិស្ស សហសេវិក និងសហគមន៍។ គ្រូបង្រៀនចំនួន០៧%បានប្រើប្រាស់ម្តងម្កាលនូវភាពយុត្តិធម៌ និងតម្លាភាពក្នុងការប្រព្រឹត្តជាមួយសិស្ស សហសេវិក និងសហគមន៍។

**សន្និដ្ឋានរួម**

យោងតាមទិន្នន័យលម្អិតក្នុងចំណុចនីមួយៗខាងលើ ក្នុងចំណោមគ្រូបង្រៀន១៣៥នាក់ស្មើនឹង១០០% យើងឃើញថាមានគ្រូបង្រៀនចន្លោះពី៩០%ទៅ៩៥% បានខិតខំបំពេញភារកិច្ចតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ នេះមានន័យថាក្នុងអាជីពជាគ្រូបង្រៀន បុគ្គលិកបង្រៀនគ្រប់រូបបានខិតខំអភិវឌ្ឍខ្លួនដើម្បីរក្សាតម្លៃជាបុគ្គលគំរូសម្រាប់សង្គមជាតិទាំងមូល។

**៤.៤ ទស្សនៈអំពីការកំណត់អាទិភាពដើម្បីបង្កើតយុទ្ធសាស្ត្រជំរុញគ្រូបង្រៀនឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ**

នៅក្នុងការកំណត់អាទិភាពនៃយុទ្ធសាស្ត្រជំរុញគ្រូបង្រៀនឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ គឺយើងបានសម្ភាសន៍មុខសញ្ញាសំខាន់ៗចំនួនប្រាំមួយគឺ (១) ថ្នាក់ដឹកនាំមន្ទីរ (២)ថ្នាក់ដឹកនាំការិយាល័យមធ្យមសិក្សាចំណេះទូទៅ (៣)ថ្នាក់ដឹកនាំការិយាល័យបុគ្គលិក (៤)ថ្នាក់ដឹកនាំការិយាល័យអធិការកិច្ច (៥)គណៈគ្រប់គ្រងសាលារៀន និង(៦)បុគ្គលិកបង្រៀន។ ទស្សនៈយល់ឃើញរបស់ក្រុមគោលដៅទាំងអស់ត្រូវបានយកមកវិភាគដោយធ្វើការប្រៀបធៀបទៅលើតំបន់(ទីប្រជុំជន និងជនបទ) តួនាទី ភេទ និងបទពិសោធន៍ការងារក្នុងវិស័យអប់រំ។ ក្នុងការកំណត់យុទ្ធសាស្ត្រជំរុញគ្រូបង្រៀនឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈគឺអ្នកស្រាវជ្រាវផ្តោតទៅលើ យុទ្ធសាស្ត្រចំនួនប្រាំដែលមានអាទិភាពជាងគេបំផុតក្នុងចំណោមសូចនាករទាំងដប់មួយដែលមាននៅក្នុងកម្រងសំណួរ។

**៤.៤.១ ទស្សនៈរួមរបស់បុគ្គលិកអប់រំ**

តារាង៤.៤.១៖ ភាគរយមតិគាំទ្ររបស់បុគ្គលិកអប់រំ

| ល.រ | បរិយាយ | អ.ភ.១ | | អ.ភ២ | | អ.ភ៣ | | អ.ភ៤ | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួន /នាក់ | ភាគរយ% | ចំនួន /នាក់ | ភាគរយ% | ចំនួន /នាក់ | ភាគរយ% | ចំនួន /នាក់ | ភាគរយ% |
| ១ | គ្រប់គ្រងវត្តមានគ្រូ | 151 | **88.8** | 13 | **7.6** | 06 | **3.5** | 00 | **00** |
| ២ | គ្រូត្រូវធ្វើកិច្ចសន្យា | 60 | **35.3** | 45 | **26.5** | 41 | **24.1** | 24 | **14.1** |
| ៣ | ពង្រឹងការប្រជុំបច្ចេកទេស | 99 | **58.2** | 49 | **28.8** | 19 | **11.2** | 03 | **02** |
| ៤ | ពង្រឹងថ្នាក់និទស្សន៍ | 36 | **21.2** | 58 | **50** | 46 | **27** | 03 | **02** |
| ៥ | ពង្រឹងអធិការកិច្ច | 19 | **11.2** | 86 | **50.6** | 47 | **27.6** | 18 | **11** |
| ៦ | លើកទឹកចិត្តគ្រូ | 13 | **7.6** | 57 | **33.5** | 62 | **36.5** | 38 | **22** |
| ៧ | ពិនិត្យស្នាដៃការងារ | 22 | **12.9** | 55 | **32.4** | 77 | **45.3** | 16 | **9.4** |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៨ | ផ្តល់ស្វ័យភាពដល់នាយក | 18 | **10.6** | 31 | **18.2** | 81 | **47.6** | 40 | **24** |
| ៩ | ដំឡើងឋានន្តរស័ក្តិឱ្យគ្រូ | 32 | **18.8** | 44 | **25.9** | 67 | **39.4** | 27 | **16** |
| ១០ | ប្តូរប្រព័ន្ធមកជានិយោជ | 33 | **19.4** | 12 | **7.1** | 27 | **15.9** | 98 | **58** |
| ១១ | ឱ្យគ្រូបំប៉នសមត្ថភាព | 26 | **15** | 30 | **18** | 37 | **22** | 75 | **45** |

ក. គ្រប់គ្រងវត្តមាន ម៉ោងចូល និងម៉ោងចេញរបស់បង្រៀនតាមថ្នាក់នីមួយៗឱ្យបានច្បាស់លាស់ ម៉ឺងម៉ាត់ និងជាប្រចាំ

តាមរយៈតារាង៤.៤.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមបុគ្គលិកអប់រំដែលបានចូលរួមឆ្លើយចំនួន១៧០នាក់ ស្មើនឹង១០០% បានផ្តល់មតិគាំទ្រអំពី«ការគ្រប់គ្រងវត្តមាន ម៉ោងចូល និងម៉ោងចេញរបស់គ្រូបង្រៀនតាមថ្នាក់នីមួយៗបានច្បាស់លាស់ ម៉ឺងម៉ាត់ និងជាប្រចាំ» ដូចតទៅ៖ បុគ្គលិកអប់រំចំនួន១៥១នាក់ ស្មើនឹង៨៨.៨%បានផ្តល់អាទិភាពទី១ បុគ្គលិកអប់រំចំនួន១៣នាក់ ស្មើនឹង៧.៦%បានផ្តល់អាទិភាពទី២ បុគ្គលិកអប់រំចំនួន០៦នាក់ ស្មើនឹង៣.៥%បានផ្តល់អាទិភាពទី៣ ហើយមិនមានបុគ្គលិកអប់រំចំនួនណាម្នាក់បានផ្តល់អាទិភាពទី៤អំពីចំណុចនេះទេ។ តាមរយៈលទ្ធផលនេះមានន័យ «ការគ្រប់គ្រងវត្តមានម៉ោងចូល និងម៉ោងចេញរបស់គ្រូបង្រៀនតាមថ្នាក់នីមួយៗបានច្បាស់លាស់ ម៉ឺងម៉ាត់ និងជាប្រចាំ» ស្ថិតក្នុងចំណុចអាទិភាពចាំបាច់បំផុតដើម្បីដាក់បញ្ចូលជាយុទ្ធសាស្រ្តជំរុញគ្រូបង្រៀនបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

ខ.គ្រូបង្រៀនតាមមុខវិជ្ជាត្រូវធ្វើកិច្ចសន្យាជាមួយនាយកដើម្បីធានាលទ្ធផលសិក្សារបស់សិស្សចំពោះមុខវិជ្ជារបស់ខ្លួន

តាមរយៈតារាង៤.៤.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមបុគ្គលិកអប់រំដែលបានចូលរួមឆ្លើយចំនួន១៧០នាក់ ស្មើនឹង១០០% បានផ្តល់មតិគាំទ្រអំពី«គ្រូបង្រៀនតាមមុខវិជ្ជាត្រូវធ្វើកិច្ចសន្យាជាមួយនាយកដើម្បីធានាលទ្ធផលសិក្សារបស់សិស្សចំពោះមុខវិជ្ជារបស់ខ្លួន» ដូចតទៅ៖ បុគ្គលិកអប់រំចំនួន៦០នាក់ ស្មើនឹង៣៥.៣%បានផ្តល់អាទិភាពទី១ បុគ្គលិកអប់រំចំនួន៤៥នាក់ ស្មើនឹង២៦.៥%បានផ្តល់អាទិភាពទី២ បុគ្គលិកអប់រំចំនួន៤១នាក់ ស្មើនឹង២៤.១%បានផ្តល់អាទិភាពទី៣ បុគ្គលិកអប់រំចំនួន២៤នាក់ ស្មើនឹង១៤.១%បានផ្តល់អាទិភាពទី៤អំពីចំណុចនេះ។ តាមរយៈលទ្ធផលនេះមានន័យថា «គ្រូបង្រៀនតាមមុខវិជ្ជាត្រូវធ្វើកិច្ចសន្យាជាមួយនាយកដើម្បីធានាលទ្ធផលសិក្សារបស់សិស្សចំពោះមុខវិជ្ជារបស់ខ្លួន»ស្ថិតក្នុងចំណុចអាទិភាព ដើម្បីដាក់បញ្ចូលជាយុទ្ធសាស្រ្តជំរុញគ្រូបង្រៀនបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

គ.ពង្រឹងការប្រជុំបច្ចេកទេស

តាមរយៈតារាង៤.៤.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមបុគ្គលិកអប់រំដែលបានចូលរួមឆ្លើយចំនួន១៧០ នាក់ ស្មើនឹង១០០% បានផ្តល់មតិគាំទ្រអំពី«ពង្រឹងការប្រជុំបច្ចេកទេស» ដូចតទៅ៖ បុគ្គលិកអប់រំចំនួន ៩៩នាក់ ស្មើនឹង៥៨.២%បានផ្តល់អាទិភាពទី១ បុគ្គលិកអប់រំចំនួន៤៩នាក់ ស្មើនឹង២៨.៨%បានផ្តល់ អាទិភាពទី២ បុគ្គលិកអប់រំចំនួន១៩នាក់ ស្មើនឹង១១.២%បានផ្តល់អាទិភាពទី៣ បុគ្គលិកអប់រំចំនួន០៣ នាក់ ស្មើនឹង២%បានផ្តល់អាទិភាពទី៤អំពីចំណុចនេះ។ តាមរយៈលទ្ធផលនេះមានន័យថា «ការពង្រឹង ការប្រជុំបច្ចេកទេស»ស្ថិតក្នុងចំណុចអាទិភាពចាំបាច់ ដើម្បីដាក់បញ្ចូលជាយុទ្ធសាស្ត្រជំរុញគ្រូបង្រៀន បំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

ឃ. ពង្រឹងការធ្វើថ្នាក់និទស្សន៍

តាមរយៈតារាង៤.៤.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមបុគ្គលិកអប់រំដែលបានចូលរួមឆ្លើយចំនួន១៧០ នាក់ ស្មើនឹង១០០% បានផ្តល់មតិគាំទ្រអំពី អំពី«ពង្រឹងការធ្វើថ្នាក់និទស្សន៍» ដូចតទៅ៖ បុគ្គលិកអប់រំ ចំនួន៣៦នាក់ ស្មើនឹង២១.២%បានផ្តល់អាទិភាពទី១ បុគ្គលិកអប់រំចំនួន៨៥នាក់ ស្មើនឹង៥០%បានផ្តល់ អាទិភាពទី២ បុគ្គលិកអប់រំចំនួន៤៦នាក់ ស្មើនឹង២៧%បានផ្តល់អាទិភាពទី៣ បុគ្គលិកអប់រំចំនួន០៣ នាក់ ស្មើនឹង២%បានផ្តល់អាទិភាពទី៤អំពីចំណុចនេះ។ តាមរយៈលទ្ធផលនេះមានន័យថា «ការពង្រឹង ការធ្វើថ្នាក់និទស្សន៍»ស្ថិតក្នុងចំណុចអាទិភាពបន្ទាប់បន្សំ ដើម្បីដាក់បញ្ចូលជាយុទ្ធសាស្ត្រជំរុញគ្រូបង្រៀន បំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

ង. ពង្រឹងការធ្វើអធិការកិច្ច

តាមរយៈតារាង៤.៤.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមបុគ្គលិកអប់រំដែលបានចូលរួមឆ្លើយចំនួន១៧០ នាក់ ស្មើនឹង១០០% បានផ្តល់មតិគាំទ្រអំពី«ពង្រឹងការធ្វើអធិការកិច្ច» ដូចតទៅ៖ បុគ្គលិកអប់រំចំនួន១៩ នាក់ ស្មើនឹង១១.២%បានផ្តល់អាទិភាពទី១ បុគ្គលិកអប់រំចំនួន៨៦នាក់ ស្មើនឹង៥០.៦%បានផ្តល់អាទិ ភាពទី២ បុគ្គលិកអប់រំចំនួន៤៧នាក់ ស្មើនឹង២៧.៦%បានផ្តល់អាទិភាពទី៣ បុគ្គលិកអប់រំចំនួន១៨នាក់ ស្មើនឹង១១%បានផ្តល់អាទិភាពទី៤អំពីចំណុចនេះ។ តាមរយៈលទ្ធផលនេះមានន័យថា «ការពង្រឹងការ ធ្វើអធិការកិច្ច»ស្ថិតក្នុងចំណុចអាទិភាពបន្ទាប់បន្សំ ដើម្បីដាក់បញ្ចូលជាយុទ្ធសាស្ត្រជំរុញគ្រូបង្រៀន បំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

ច. ការលើកទឹកចិត្ត និងដាក់ទណ្ឌកម្មបុគ្គលិកអប់រំជាប្រចាំនិងម៉ត់ចត់

តាមរយៈតារាង៤.៤.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមបុគ្គលិកអប់រំដែលបានចូលរួមឆ្លើយចំនួន១៧០ នាក់ ស្មើនឹង១០០% បានផ្ដល់មតិគាំទ្រអំពី«ការលើកទឹកចិត្ត និងដាក់ទណ្ឌកម្មបុគ្គលិកអប់រំជាប្រចាំនិងម៉ត់ចត់» ដូចតទៅៈ បុគ្គលិកអប់រំចំនួន១៣នាក់ ស្មើនឹង៧.៦%បានផ្ដល់អាទិភាពទី១ បុគ្គលិកអប់រំចំនួន៥៧នាក់ ស្មើនឹង៣៣.៥%បានផ្ដល់អាទិភាពទី២ បុគ្គលិកអប់រំចំនួន៦២នាក់ ស្មើនឹង៣៦.៥%បានផ្ដល់អាទិភាពទី៣ បុគ្គលិកអប់រំចំនួន៣៨នាក់ ស្មើនឹង២២%បានផ្ដល់អាទិភាពទី៤អំពីចំណុចនេះ។ តាមរយៈលទ្ធផលនេះមានន័យថា «ការលើកទឹកចិត្ត និងដាក់ទណ្ឌកម្មបុគ្គលិកអប់រំជាប្រចាំនិងម៉ត់ចត់»ស្ថិតក្នុងចំណុចអាទិភាពមិនសូវចាំបាច់ ដើម្បីដាក់បញ្ចូលជាយុទ្ធសាស្ត្រជំរុញគ្រូបង្រៀនបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

ឆ. ការពិនិត្យមើលស្នាដៃការងាររបស់គ្រូបង្រៀន

តាមរយៈតារាង៤.៤.១ អ្នកស្រាវជ្រាវដឹងថាក្នុងចំណោមបុគ្គលិកអប់រំដែលបានចូលរួមឆ្លើយចំនួន១៧០ នាក់ ស្មើនឹង១០០% បានផ្ដល់មតិគាំទ្រអំពី«ការពិនិត្យមើលស្នាដៃការងារ» ដូចតទៅៈ បុគ្គលិកអប់រំចំនួន២២នាក់ ស្មើនឹង១២.៩%បានផ្ដល់អាទិភាពទី១ បុគ្គលិកអប់រំចំនួន៥៥នាក់ ស្មើនឹង៣២.៤%បានផ្ដល់អាទិភាពទី២ បុគ្គលិកអប់រំចំនួន៧៧នាក់ ស្មើនឹង៤៥.៣%បានផ្ដល់អាទិភាពទី៣ បុគ្គលិកអប់រំចំនួន១៦ នាក់ ស្មើនឹង៩.៤%បានផ្ដល់អាទិភាពទី៤អំពីចំណុចនេះ។ តាមរយៈលទ្ធផលនេះមានន័យថា «ការពិនិត្យមើលស្នាដៃការងាររបស់គ្រូបង្រៀន»ស្ថិតក្នុងចំណុចអាទិភាពមិនសូវចាំបាច់ ដើម្បីដាក់បញ្ចូលជាយុទ្ធសាស្ត្រជំរុញគ្រូបង្រៀនបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

ជ. ផ្ដល់ស្វ័យភាពដល់នាយកសាលាដើម្បីអនុវត្តច្បាប់ឬវិន័យទៅលើគ្រូបង្រៀន

